# ពាក្យពិត ហើយមានប្រយោជន៍



ប្រមូលរៀបរៀងដោយ

ភិក្ខុ បញ្ញាបជ្ជោតោ **ទេព បញ្ញា**

# ពាក្យប្រារព្ធ

កាលពីព្រះពុទ្ធសករាជ ២៥៥៤ ខ្ញុំព្រះករុណាមាន ឱកាស សិក្សាព្រះធម៌ ស្តាប់ព្រះធម៌ដែលលោកគ្រូ **អគ្គបណ្ឌិតធម្មាចារ្យ ប៊ុត សាវង្ស** សម្តែងហើយ បង្រៀនហើយតាមសម្លេងព្រះធម៌ ខ្ញុំព្រះករុណាក៏បានសរសេរមេរៀនទាំងអស់ តាមការហៅរបស់ លោកគ្រូធ្វើជាសៀវភៅមួយច្បាប់ ទុកជាធម្មានុស្សរណៈដែរ ឥឡូវនេះ ឱកាសនោះ នៅមានសម្រាប់ ខ្ញុំព្រះករុណាដដែល ហើយការសិក្សាព្រះធម៌ ស្តាប់ព្រះធម៌នេះ គឺបានសិក្សាដោយ ផ្ទាល់ ស្តាប់ដោយផ្ទាល់អំពី លោកគ្រូទៀតផង ។ ហេតុនេះហើយ ខ្ញុំព្រះករុណា មានសេចក្តីសោមនស្សសប្បាយ រីករាយណាស់ ដែលបានសេពគប់សប្បុរស ស្តាប់ធម៌សប្បុរស សិក្សាធម៌ របស់ សប្បុរសពោលគឺបុណ្យនាំឱ្យបានចូលជិតលោកគ្រូអគ្គបណ្ឌិតដែល ជាសប្បុរស ជាបណ្ឌិតដែលប្រកបដោយគុណធម៌គួរជាទីគោរព។ នៅក្នុងព្រះ ពុទ្ធសករាជ ២៥៥៤ ដល់ ២៥៥៦នេះ ក៏មានមេរៀន ជា ច្រើនដែលលោកគ្រូបានហៅឱ្យសរសេរ នៅវត្ត ឧណ្ណាលោម

និងវត្តសំពៅមាស ខ្ញុំព្រះករុណាបានសិក្សា ហើយក៏មានសេចក្តីជ្រះថ្លា នឹងធ្វើជាសៀវភៅមួយទៀតដោយស្រង់យកមេរៀនតាំងពី ព.ស.២៥៤៦ មកខ្លះទៀតផង, មិនតែប៉ុណ្ណោះក្នុងសៀវភៅនេះ ខ្ញុំព្រះករុណាបានដកស្រង់សេចក្តីខ្លះក្នុងព្រះសូត្ររួមដោយកងធម៌ អង្គរបស់សិក្ខាបទ ៥ សិក្ខាបទ ៨ និងផលានិសង្សនៃការ រក្សាសិក្ខាបទនីមួយៗទៀតផង ក៏ដើម្បីជាធម្មានុស្សរណៈ បុញ្ញានុស្សរណៈនោះឯង ហើយក៏ដើម្បីបាននូវបុណ្យកុសលដែលកើតពីការសិក្សាព្រះធម៌ និងការធ្វើជាធម្មទាននេះបូជាចំពោះគុណរបស់លោកគ្រូផង ។

ខ្ញុំព្រះករុណា អាត្មាភាព សូមធ្វើការអភ័យទោសផងដែរក្នុងការរៀបរៀងសៀវភៅនេះព្រោះសេចក្តីទាំងអស់ក្នុងសៀវភៅនេះគឺ មួយចំណែកធំជាមេរៀនដែលបានសិក្សាហើយ ។ ដោយផលានិសង្សនៃបុណ្យទាំងអស់ ដែលខ្ញុំព្រះករុណាបានធ្វើហើយបំពេញហើយក្នុងកាលទាំងពួង ខ្ញុំព្រះករុណាសូមលើកបុណ្យទាំងអស់នោះៗប្រគេននិងជូនចំពោះ

-ព្រះគ្រូ ឧបជ្ឈាយ៍ អាចារ្យគ្រប់ព្រះអង្គរបស់ខ្ញុំ ដែលបាន ផ្តល់នូវ បព្វជ្ជា ឧបសម្បទា និង ចំណេះដឹង ដល់ខ្ញុំព្រះករុណា ។

-**ញោមប្រុស ញោមស្រី** ដែលបានផ្តល់កំណើត និង ផ្តល់ការរក្សាខ្ញុំ ដោយព្រហ្មវិហារធម៌ ។

-លោកគ្រូ **អគ្គបណ្ឌិត ធម្មាចារ្យ ម៉ុត សាវឌ្ឍ** ជា ឧត្តមសប្បុរស ។

-លោកគ្រូ **ធម្មបណ្ឌិត រស់ សុផាត** ។

-លោកគ្រូ **វិនយាចារ្យ គាំ អ៊ីវ** ។

-លោកគ្រូ **ធម្មាចារ្យ ជិម ជំនិត** ។

និងលោកគ្រូ ធម្មាចារ្យគ្រប់រូប ទាំងអស់ដែលជាអ្នក ជួយទ្រទ្រង់ រក្សាព្រះពុទ្ធសាសនារក្សាព្រះបាវចនៈ របស់ព្រះបរមសាស្តាចារ្យ សម្មាសម្ពុទ្ធ ជាអម្ចាស់ ។

-ញាតិញោមជាពុទ្ធបរិសទ្យទាំងអស់ ដែលជាអ្នកមាន ឧបការគុណជួយ ទំនុកបម្រុង ផ្តល់នូវកម្លាំងចិត្តក្នុងការសិក្សា ព្រះធម្មវិន័យព្រះពុទ្ធសាសនា។

-សព្វសត្វទាំងអស់ ដែលនៅក្នុងត្រៃភពនេះ គឺថាសូម បុណ្យកុសលនេះ ជាបច្ច័យឱ្យបានសម្រេច ដូចសេចក្តីប្រាថ្នា ទទួលនូវការត្រាស់ដឹង សច្ចធម៌ រួចផុតចាកទុក្ខទាំងពួងគ្រប់ៗ ព្រះអង្គ គ្រប់ៗគ្នាកុំបីឃ្លាតឆ្ងាយទៅជាប្រការដទៃឡើយ ។

វត្តកល្យាណមិត្ត ជ្រោយម្ទេស ថ្ងៃ ១៥កើត ខែមាឃ ព.ស.២៥៥៦

ខ្ញុំព្រះករុណា អាត្មាភាព **ភិក្ខុ បញ្ញាបជ្ជោតោ ទេព បញ្ញា**

ជីវិតមានធម៌ល្អដូចដួងច័ន្ទ
ជីវិតសំខាន់បានអប់រំចិត្ត
ជីវិតឧត្តមព្រោះស្គាល់ការពិត
សុខកាយសុខចិត្តវិសិដ្ឋថ្លៃថ្លា ។
លោកគ្រូឧត្តមដោយបុញ្ញឫទ្ធិ
អគ្គបណ្ឌិតពិតពេញមេត្តា
សម្តែងព្រះធម៌ឱវាទសាស្តា
ដោយចិត្តករុណាដូចបុត្តព្រះពុទ្ធ ។



# ឈ្មោះអត្ថបទ


១_មេរៀនវត្តសំពៅមាសព.ស.២៥៥៥_៥៦............... ៩

២_មេរៀនវត្តឧណ្ណាលោមព.ស.២៥៥៥_៥៦.............២៨

៣_ចក្កវត្តិសូត្រ.......................................៥៣

៤_មេរៀនវត្តឧណ្ណាលោមព.ស.២៥៤៨_៤៩.............៦៣

៥_បិដកលេខ៤៦ ទំព័រ ៦ ................................៧៨

៦_ឧបមាព្រះរតនៈមេរៀនវត្តឧណ្ណាលោមព.ស.២៥៤៩..៤២

៧_បិដកលេខ៤៦ ទំព័រ ២១...............................៤៦

៨_បិដកលេខ ៥៤ ទំព័រ ១១៦.............................៤៨

៩_គាថាក្នុងកលហវិវាទសូត្រ...........................៥២

១០_បិដកលេខ ៤៧.......................................៥៤

១១_មេរៀនវត្តឧណ្ណាលោម ព.ស.២៥៤៧................៥៦

១២_បិដកលេខ ៥២ ទំព័រ ៨១............................៦០

១៣_មេរៀនវត្តឧណ្ណាលោម ព.ស.២៥៤៧...............៦៣

១៤_បិដកលេខ ៥២ ទំព័រ ៣២០.........................៦៥

១៥_សិក្សាអរិយសច្ច មានទុក្ខអរិយសច្ចជាដើម............៧០
១៦_ថេរសូត្រ បិដកលេខ ៤៤..............................៨០
១៧_កងធម៌សង្ខេប....................................៨១
១៨_អង្គនៃសិក្ខាបទ..................................៨៦
១៩_ប្រយោជន៍នៃការស្តាប់ព្រះធម៌.......................៩៩
២០_សេចក្តីក្នុងព្រះអដ្ឋកថាអដ្ឋសាលិនី..................១០០

**សន្សំបុណ្យយកបុណ្យទៅបាន**
**អប់រំសន្ដានបានសេចក្ដីសុខ**

# ជីវិតមានន័យ ជីវិតជោគជ័យ

# ព្រោះអប់រំចិត្ត !

-ដឹងគុណ តបគុណ ជាបុណ្យឧត្តម

-មនុស្សគ្រប់រូបធ្វើការខុសគ្នា តែសេចក្តីប្រាថ្នាដូចគ្នា គឺចង់បានសេចក្តីសុខក្សេមក្សាន្ត !

-មាសប្រាក់មិនសំខាន់ណាស់ណាទេ ដែលជាហេតុនៃសេចក្តីសុខ !

-បុណ្យធំណាស់ដែលកើតជាមនុស្សហើយទាន់ ព្រះពុទ្ធ-សាសនា !

-មិនមែនមានប្រាក់ច្រើន ហើយមានសេចក្តីសុខនោះទេ !

## មិនឈ្នះការពិតឡើយ !

## មិនឈ្នះការពិតឡើយ !

## មិនឈ្នះការពិតឡើយ !

# អធិមុត្តត្ថេរគាថា

ព្រះថេរៈអង្គនេះបានបំពេញនូវបុញ្ញាធិការ ទុកមកក្នុងព្រះពុទ្ធអង្គមុនៗសន្សំបុណ្យ ទុកក្នុងភពនោះៗ ។

ក្នុងកាលនៃព្រះដ៏មានព្រះភាគអត្ថទស្សី បានកើតក្នុងត្រកូលមានទ្រព្យសម្បត្តិច្រើន ពេលដែលព្រះសម្មាសម្ពុទ្ធបរិនិព្វានហើយក៏បានទំនុកបម្រុងព្រះភិក្ខុសង្ឃ ។

ក្នុងគម្ពីរអបទាន លោកបានពោលថា ក្នុងកប្បទី១៨ យើងបានឱ្យទានណាទុកក្នុងកាលនោះ ដោយផលនៃទាននោះ យើងមិនស្គាល់នូវទុគ្គតិឡើយ នេះជាផលនៃការថ្វាយទឹកអំពៅ ។ គុណវិសេសទាំងនេះគឺ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ យើងបានធ្វើឱ្យជាក់ច្បាស់ហើយ ។

ក្នុងពុទ្ធុប្បាទនេះ លោកកើតជាក្មួយរបស់ព្រះសង្កិច្ចត្ថេរ មាន-

នាមថាអធិមុត្តៈ បួសក្នុងសម្នាក់លោកម្ចាស់អ៊ិបំពេញវិបស្សនាកម្មដ្ឋានសម្រេចព្រះអរហត្តផលទាំងដែលនៅជាសាមណេរ ។

លោកបានសម្រេចព្រះអរហត្តផលហើយ បានញ៉ាំងកាលឱ្យប្រព្រឹត្តកន្លងទៅដោយសេចក្តីសុខក្នុងសមាបត្តិ ។ នៅពេលលោកនិមន្តជម្រាបមាតា ដើម្បីឧបសម្បទាជាភិក្ខុ ត្រូវពួកចោរ ៥០០នាក់ស្ទាក់ចាប់ដើម្បីធ្វើពលិកម្មដល់ទេវតា ។ កាលដែលលោកមិនតក់ស្លុត ព្រះភក្ត្រនៅតែស្រស់បស់ ទើបមេចោរកើតសេចក្តីអស្ចារ្យក្នុងចិត្តសាកសួរអំពីមូលហេតុថា ក្នុងកាលមុនពួកយើងទាំងឡាយសម្លាប់ពួកសត្វណាដើម្បីយកយញ្ញ ឬ ដើម្បីទ្រព្យ ភ័យក៏កើតមានដល់ពួកសត្វនោះ ឥតមានសេសសល់ឡើយ ។ សត្វទាំងនោះរមែងញាប់ញ័រផង សោកសៅផង ។ ឥឡូវនេះ សេចក្តីភិតភ័យនៃលោកម្ចាស់មិនមាន ទាំងសម្បុរមុខរបស់លោកម្ចាស់ក៏ស្រស់បស់ក្រៃលែង ហេតុអ្វីក៏លោកម្ចាស់ មិនខ្សឹកខ្សួលព្រោះភ័យធំដែលមានសភាពយ៉ាងនេះ ។

ព្រះអធិមុត្តត្ថេរសាមណេរបានពោល ថាៈ

**នត្ថិ ចេតសិកំ ទុក្ខំ អនបេក្ខស្ស គាមណិ**

**អតិក្កន្តា ភយា សព្វេ ខីណសំយោជនស្សវេ ។**

ម្នាលអ្នកជាធំសេចក្តីទុក្ខប្រព្រឹត្តទៅក្នុងចិត្ត នៃបុគ្គលអ្នកមិនមានសេចក្តីអាឡោះអាល័យមិនមានទេបុគ្គលអ្នកមានសំយោជនៈអស់ហើយបានកន្លងផុតនូវភ័យទាំងពួង។

**ខីណាយ ភវនេត្តិយា ទិដ្ឋេ ធម្មេ យថា តថា**

**ន ភយំ មរណេ ហោតិ ភារនិក្ខេបនេ យថា ។**

កាលបើតណ្ហាជាគ្រឿងនាំសត្វទៅកាន់ភពអស់ហើយ ព្រោះបានឃើញធម៌ តាមសេចក្តីពិត ភ័យចំពោះសេចក្តីស្លាប់រមែងមិនមានឡើយ ដូចការមិនមានភ័យ ក្នុងកិរិយាដាក់ចុះនូវភារៈគឺគ្រឿងធ្ងន់អំពីលើក្បាល ។

**សុចិណ្ណំ ព្រហ្មចរិយំ មេ មគ្គោ ចាបិ សុភាវិតោ**

**មរណេ មេ ភយំ នត្ថិ រោគានមិវ សង្ខយេ ។**

ព្រហ្មចរិយធម៌ អាត្មាបានសន្សំល្អហើយ ទាំងមគ្គអាត្មាក៏បានចម្រើនល្អហើយដែរ ភ័យចំពោះសេចក្តីស្លាប់នៃអាត្មាមិនមានទេដូចការមិនមានភ័យក្នុងកិរិយាអស់ទៅនៃរោគទាំងឡាយ ។

**សុចិណ្ណំ ព្រហ្មចរិយំ មេ មគ្គោ ចាបិ សុភាវិតោ**

**និរស្សាទា គតា ទិដ្ឋា វិសំ បិត្វាវ ឆឌ្ឌិតំ ។**

ព្រហ្មចរិយធម៌ អាត្មាបានសន្សំល្អហើយទាំងមគ្គអាត្មាក៏បានចម្រើនល្អហើយ ដែរភពទាំងឡាយដែលមិនមានសេចក្ដីត្រេកអរ អាត្មាក៏បានឃើញហើយដែរ ដូចបុគ្គលផឹកថ្នាំពិស ហើយខ្ជាក់ចោលវិញដូច្នោះឯង ។

**បារគូ អនុបាទានោ កតកិច្ចោ អនាសវោ**
**តុដ្ឋោ អាយុក្ខយា ហោតិ មុត្តោ អាឃាតនា យថា ។**

បុគ្គលអ្នកដល់នូវត្រើយ គឺព្រះនិព្វានមិនមានសេចក្ដីប្រកាន់ មានសោឡសកិច្ចធ្វើហើយ មិនមានអាសវៈ រមែងជាអ្នកត្រេកអរក្នុងកិរិយាអស់ទៅនៃអាយុដូចបុគ្គលរួចហើយចាកការសម្លាប់។

**ឧត្តមំ ធម្មតំ បត្តោ សព្វលោកេ អនត្ថិកោ**
**អាទិត្តា វ ឃរា មុត្តោ មរណស្មិំ ន សោចតិ ។**

បុគ្គលបានដល់នូវធម៌ដ៏ឧត្តមជាអ្នកមិនត្រូវការអ្វីក្នុងលោកទាំងអស់រមែងមិនសោកសៅព្រោះសេចក្ដីស្លាប់ឡើយ ដូចបុគ្គលដែលស្ទុះចេញអំពីផ្ទះដែលភ្លើងកំពុងឆេះ ។

**យទត្ថិ សង្ខតំ កិញ្ចិ ភវោ ច យត្ថ លព្ភតិ**

សព្វំ អនិស្សរំ ឯតំ ឥធំ វុត្តំ មហេសិនា ។

ការជួបជុំដោយសត្វនិងសង្ខារឯណានិមួយក្ដី ការកើតមានក្នុងសត្វឯណាក្ដី ទាំងអស់នោះមិនមែនជាឥស្សរៈឡើយ ពាក្យនេះព្រះសម្មាសម្ពុទ្ធអ្នកស្វែងរកនូវគុណដ៏ធំបានសម្ដែងហើយ ។

យោ តំ តថាបជានាតិ យថា ពុទ្ធេន ទេសិតំ

ន គណ្ហាតិ ភវំ កិញ្ចិ សុតត្តំ វ អយោគុឡំ ។

បុគ្គលណាបានដឹងច្បាស់នូវធម៌នោះ តាមដែលព្រះពុទ្ធអង្គទ្រង់សម្ដែងហើយបុគ្គលនោះរមែងមិនប្រកាន់ នូវភពឯណានិមួយឡើយ ដូចបុគ្គលមិនចាប់កាន់នូវ ដុំដែកដែលក្ដៅព្រោះដុតដោយភ្លើងពេញមួយថ្ងៃហើយ ។

ន មេ ហោតិ អហោសិន្តិ ភវិស្សន្តិ ន ហោតិ មេ

សង្ខារា វិភវិស្សន្តិ តត្ថ កា បរិទេវនា ។

អាត្មាមិនមានសេចក្ដីត្រិះរិះថា ខ្លួនអញបានមានហើយទេ អាត្មាក៏មិនបានគិតថា ខ្លួនអញនឹងមានតទៅទៀតដែរ ព្រោះថាសង្ខារទាំងឡាយ ទៀងតែវិនាសទៅវិញ ហេតុនោះសេចក្ដីខ្សឹកខ្សួលក្នុងសង្ខារទាំងឡាយនោះ ដូចម្ដេចកើត ។

**សុទ្ធំ ធម្មសមុប្បាទំ សុទ្ធំ សង្ខារសន្តតឹ**

**បសន្តស្ស យថាភូតំ ន ភយំ ហោតិ គាមណិ ។**

ម្នាលមេចោរ ភ័យរមែងមិនមានឡើយចំពោះ បុគ្គលដែលឃើញច្បាស់តាមសេចក្តីពិតនូវ ការកើតឡើងព្រមនៃធម៌ដ៏បរិសុទ្ធ និង ដំណើរនៃសង្ខារបរិសុទ្ធ ។

**តិណកដ្ឋសមំលោកំ យទា បញ្ញាយ បស្សតិ**

**មមត្តំ សោ អសំវិន្ទំ នត្ថិ មេតិ ន សោចតិ ។**

បុគ្គលកាលឃើញច្បាស់ដោយបញ្ញា នូវសង្ខារលោកប្រាកដស្មើដោយស្មៅ និង កំណាត់ឈើក្នុងកាលនោះ បុគ្គលនោះឯងរមែងមិនមាននូវការប្រកាន់ថាជារបស់អញ និងមិនសោកសៅថា របស់នោះមិនមានដល់អញ ដូច្នេះឡើយ ។

**ឧកណ្ឋាមិ សរីរេន ភវេនម្ហិ អនត្ថិកោ**

**សោយំ ភិជ្ជិស្សតិ កាយោ អញ្ញោ ច ន ភវិស្សតិ ។**

អាត្មាភាពធុញទ្រាន់នឹងសរីរៈ ជាអ្នកមិនត្រូវការដោយភព ព្រោះថាកាយនេះនឹងបែកធ្លាយទៅ ទាំងកាយដទៃទៀតនឹងមិនមានឡើយ ។

**យំ ဟော កិច្ចំ សរីរេន តំ ករោថ យទិច្ឆថ**
**ន មេ តប្បច្ចយា តត្ថ ខោសោ បេមំ ច ហេហីតិ ។**

កិច្ចណាដោយសរីរៈមានដល់ពួកអ្នក ពួកអ្នកប្រាថ្នានូវកិច្ចណា ចូរធ្វើនូវកិច្ចនោះចុះ ការស្រឡាញ់ និងការស្អប់របស់អាត្មាក្នុងអំពើទាំងនោះ ព្រោះបច្ច័យនៃដែលអ្នកបាន ធ្វើចំពោះសរីរៈនៃអាត្មាភាពមិនមានឡើយ ។

ពួកចោរបានស្តាប់នូវពាក្យនៃព្រះអធិមុត្តៈនោះ ជាពាក្យចំឡែកអស្ចារ្យ គួរឱ្យព្រឺរោម ហើយក៏ទម្លាក់ចោលនូវគ្រឿងសស្ត្រាទាំងឡាយ បានពោលពាក្យនេះថា បពិត្រលោកម្ចាស់ដ៏ចម្រើន តើលោកម្ចាស់បានធ្វើនូវតបោកម្មដូចម្តេច ឬអ្នកណាជាអាចារ្យរបស់លោកម្ចាស់ ម្យ៉ាងទៀត លោកម្ចាស់បាននូវការមិនសោកសៅនេះ ព្រោះអាស្រ័យពាក្យប្រដៅរបស់បុគ្គលណា ។

ព្រះអធិមុត្តៈបានឆ្លើយថា:

**សព្វញ្ញូ សព្វទស្សាវី ជិនោ អាចរិយោ មម**
**មហាការុណិកោ សត្ថា សព្វលោកតិកិច្ឆកោ ។**

ព្រះជិនស្រី ព្រះអង្គជាសព្វញ្ញូ ទ្រង់ឃើញនូវធម៌ទាំងពួងជាសាស្តាប្រកបដោយមហាករុណា ទ្រង់រក្សានូវសត្វលោកទាំងអស់ជាអាចារ្យរបស់អាត្មាភាព ។

**តេនាយំ ទេសិតោ ធម្មោ ខយគាមី អនុត្តរោ**

**តស្ស សាសនមាគម្ម លព្ភតេ តំ អសោកតា ។**

ព្រះធម៌នេះជាធម៌ដល់នូវកិរិយាអស់ទៅនៃកិលេស ជាធម៌ដ៏ប្រសើរ ព្រះជិនស្រីនោះបានសម្តែងហើយ សេចក្តីមិនសោកសៅដែលអាត្មាភាពបាន ព្រោះអាស្រ័យនូវពាក្យប្រៀនប្រដៅរបស់ព្រះជិនស្រីនោះឯង ។

ចោរទាំងឡាយបានស្តាប់នូវភាសិតនៃឥសីអធិមុត្តៈ ក៏ទម្លាក់ចោលនូវគ្រឿងសស្ត្រាទាំងឡាយផង ពួកខ្លះក៏វៀរចាកចោរកម្មនោះ ពួកខ្លះក៏ពេញចិត្តនឹងបព្វជ្ជា ។

ចោរទាំងនោះក៏ចូលទៅបួសក្នុងសាសនានៃព្រះសុគតចម្រើន-នូវពោជ្ឈង្គៈនិងពលៈទាំងឡាយ ជាបណ្ឌិត មានចិត្តខ្ពស់ឡើង មានចិត្តល្អ មានឥន្ទ្រិយចម្រើនឡើងហើយ ក៏បានពាល់ត្រូវនិព្វានបទ ជាអសង្ខតធម៌ ។

# អាយតនវិភង្គ

## ១.វិនិច្ឆ័យដោយធាតុធម៌គប្បីឃើញ

1.បណ្ឌិតគប្បីឃើញអាយតនៈទាំងអស់នោះឯង ដោយ **អនាគមនតោ** គឺនៅមិនទាន់មកដល់និងដោយ **អនិគ្គមនតោ** ការមិនចេញទៅ ។

ពិតណាស់អាយតនៈទាំងនោះ កាលដែលមុននឹងកើតឡើង រមែងមកអំពីទីណាៗ នោះមិនមានឡើយ ។ លុះដល់បែកធ្លាយទៅហើយ នឹងទៅទីណាៗក៏ទេដែរ ។ អធិប្បាយថាមុននឹងកើតឡើង អាយតនៈទាំងនេះ មិនមានភាវៈនៃខ្លួនដោយចំពោះ ដល់ក្រោយពីការបែកធ្លាយទៅ ភាវៈនៃអាយតនៈទាំងនេះឯងក៏បែកធ្លាយអស់។ ហេតុដែលវាប្រព្រឹត្តទៅបានក្នុងខាងដើម ខាងចុង និងកណ្ដាល គឺព្រោះបច្ច័យ ព្រោះហេតុដូច្នោះ គប្បីឃើញអាយតនៈទាំងឡាយ ដោយការនៅមិនទាន់មកដល់ និងដោយការមិនចេញទៅ ។

2-គប្បីឃើញអាយតនៈទាំងនេះដោយ **និរីហកតោ** គឺការមិនកម្រើក និងដោយ **អព្យាបារតោ** មិនមានការព្យាយាម ។

-ពិតណាស់ អាយតនៈទាំងឡាយ មានចក្ខុ និងរូបជាដើម មិនបានគិតថា ឱហ្ន៎! វិញ្ញាណគប្បីកើតឡើង ព្រោះពួកយើងជួបដូច្នេះឡើយ ។ ដោយសេចក្តីថា អាយតនៈទាំងនេះមិនខ្វល់ខ្វាយដើម្បីការកើតឡើងនៃវិញ្ញាណ ដោយខ្លួនឯងជាទ្វារ ឬជាវត្ថុ និង ដោយភាពជាអារម្មណ៍នោះទេ គឺ វាគ្រាន់តែជាធម្មតានៃបច្ច័យប៉ុណ្ណោះ។ ព្រោះហេតុដូច្នោះបណ្ឌិតគប្បីឃើញអាយតនៈទាំងឡាយ ដោយការមិនកម្រើកនិងដោយការមិនព្យាយាម ។

3-គប្បីឃើញអាយតនៈខាងក្នុង ដូចផ្ទះស្ងាត់ ព្រោះស្ងាត់ចាកភាពទៀងទាត់ ភាពស្អាត ភាពសុខ និងស្ងាត់ចាកអត្តាតួខ្លួន ។

គប្បីឃើញអាយតនៈខាងក្រៅ ដូចពួកចោរប្លន់អ្នកស្រុក ព្រោះដោយការប៉ះពាល់ត្រូវនូវអាយតនៈខាងក្នុង ។ ចំណុចនេះដូចព្រះពុទ្ធអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ចក្ខុត្រូវ

រូបដែលពេញចិត្ត និង មិនពេញចិត្តដែលប៉ះពាល់ត្រូវ ។ល។ បណ្ឌិត គប្បីឱ្យពិស្តារក្នុងអាសីវិសូបមសូត្រ បិដកលេខ៣៥។

4.គប្បីឃើញអាយតនៈខាងក្នុង ដូចសត្វ៦មុខ និង គប្បីឃើញអាយតនៈខាងក្រៅដូចទីត្រេចទៅរកស៊ីនៃសត្វទាំងនោះ ។

## .អធិប្បាយអាយតនៈដោយត្រៃលក្ខណ៍

.ព្រះដ៏មានព្រះភាគមានព្រះបំណង នឹងសម្តែងនូវអាការៈនៃអាយតនៈទាំងនោះដែលបណ្ឌិតគប្បីឃើញតាមសេចក្តីពិតទើបផ្តើមពាក្យមានជាអាទិ៍ថា **ចក្ខុំ អនិច្ចំ** ។

.បណ្តាអាយតនៈទាំងនោះបណ្ឌិត គប្បីជ្រាបថាចក្ខុឈ្មោះថាមិនទៀង ដោយអត្ថថា មានហើយរកមានមិនបាន ។ ឈ្មោះថាមិនទៀងដោយលក្ខណៈ៤យ៉ាងដទៃទៀតគឺ ដោយមានការកើតឡើងហើយ មានការវិនាសទៅជាទីបំផុត១ ដោយការប្រែប្រួលទៅ១ ដោយភាពជារបស់មួយគ្រា១ ដោយបដិសេធនូវភាពទៀង១ ។

.ចក្ខុនោះឯង ឈ្មោះថាចក្ខុ ព្រោះដោយអត្ថថា បៀតបៀនម្យ៉ាងទៀតចក្ខុនេះកើតឡើងហើយរមែងដល់នូវការតាំងនៅ **ឋិតិ**

កាលដែលតាំងនៅហើយរមែងលំបាក ដោយជរា ដល់ជរាហើយរមែងបែកធ្លាយទៅដោយពិត ព្រោះដូច្នោះទើប ឈ្មោះថា ជាទុក្ខ **ឈ្មោះថាទុក្ខដោយអត្ថ ៤ យ៉ាងគឺ** ដោយការបៀតបៀនរឿយៗ ១ ដោយការលំបាកទ្រាំ ១ ដោយជាទីតាំងនៃទុក្ខ ១ ដោយបដិសេធនូវសេចក្ដីសុខ ១ ។

-ចក្ខុនោះឈ្មោះថាជា **អនត្តា** ដោយអត្ថថា មិនប្រព្រឹត្តទៅតាមអំណាចបង្គាប់បញ្ជា ដូចជាបង្គាប់ថាចក្ខុកើតឡើងហើយកុំឱ្យតាំងនៅ បើតាំងនៅហើយកុំឱ្យចាស់ បើចាស់ហើយកុំឱ្យបែកធ្លាយ ដូច្នេះជាដើមមិនបានឡើយ ។ ឈ្មោះថាជា **អនត្តា** ដោយ **អត្ថមានលក្ខណៈ ៤ យ៉ាងគឺ** ដោយភាពជារបស់សូន្យ១ ដោយមិនមានម្ចាស់ ១ ដោយមិនប្រព្រឹត្តទៅតាមការពេញចិត្ត ឬការទាមទារ ១ ដោយបដិសេធនូវអត្តា ១ ។

## ២-វិនិច្ឆ័យដោយមានត្រឹមតែប៉ុណ្ណោះ

ប្រសិនបើមានអ្នកសង្ស័យថា ក៏អាយតនៈមានភ្នែកជាដើមនេះគឺជាធម៌ហ្នឹង កាលបើដូច្នេះហេតុដូចម្ដេចបានជាព្រះដ៏មានព្រះភាគ មិនត្រាស់ថាសុទ្ធតែជាធម្មាយតនៈប៉ុណ្ណោះ ប៉ុន្តែទ្រង់

ត្រាស់ថា អាយតនៈមាន១២យ៉ាង ។ ត្រូវដោះស្រាយ ការសង្ស័យ ថាដែលទ្រង់ត្រាស់អាយតនៈ១២យ៉ាង ព្រោះត្រង់កំណត់ទ្វារ និង អារម្មណ៍ជាទីកើតឡើង នៃវិញ្ញាណកាយ៦ (មានចក្ខុវិញ្ញាណ ជាដើម) ។

## ៣_វិនិច្ឆ័យដោយអត្ថ

1_ដោយអត្ថមិនប្លែកគ្នាគប្បីជ្រាបថាដែលឈ្មោះថា អាយ_ តនៈព្រោះជាគ្រឿងត **អាយតនតោ១** ព្រោះការផ្សាយធម៌ ដែលជាអណ្តូងកើតនៃអាសវៈទាំងឡាយ **អាយានំតននតោ១** ព្រោះនាំទៅកាន់សង្សារទុក្ខ **អាយតស្ស ច នយនតោ១** ។

## អធិប្បាយ

**អាយតនតោ** ព្រោះជាគ្រឿងត មានសេចក្តីអធិប្បាយថា ធម៌ទាំងឡាយគឺចិត្ត និង ចេតសិកមានអារម្មណ៍តាមទ្វារនោះ រមែងចម្រើនឡើង រមែងតាំងឡើង រមែងបន្តធ្វើកិច្ចរបស់ខ្លួន មានការសោយអារម្មណ៍ជាដើម ។

**អាយានំតននតោ** ព្រោះការផ្សាយធម៌ ដែលជាអណ្តូងកើតនៃអាសវៈទាំងឡាយ មានសេចក្តីអធិប្បាយថា ធម៌ដែលជា **អាយៈ** គឺជាអណ្តូងកើតនៃអាសវៈគឺចិត្តនិងចេតសិករមែងផ្សាយទៅរមែងជាអណ្តូងកើតនៃអាសវៈទាំងឡាយនោះៗឱ្យទូលំទូលាយ ។

**អាយតស្ស ច នយនតោ** ព្រោះនាំទៅកាន់សង្សារទុក្ខ មានសេចក្តីអធិប្បាយថាអាយតនៈទាំងនេះរមែងនាំទៅកាន់សង្សារទុក្ខដ៏វែងឆ្ងាយ ដែលមានទីបំផុតខាងដើមមិនមាន មិនអាចដឹងបាននិងឱ្យវិលត្រឡប់មិនបាន ។

ម្យ៉ាងទៀតបណ្ឌិតគប្បីជ្រាបថាឈ្មោះថាអាយតនៈព្រោះអត្ថថា **និវាសដ្ឋាន** ព្រោះអត្ថថា **អាករដ្ឋាន** ព្រោះអត្ថថា **សមោសរណដ្ឋាន** ព្រោះអត្ថថា **ភវនៈ** និងព្រោះអត្ថថា **ការណៈ** ។

## សេចក្តីអធិប្បាយ

**និវាសដ្ឋាន** គឺចិត្តនិងចេតសិកនោះ រមែងអាស្រ័យនៅក្នុងអាយតនៈទាំងឡាយមានចក្ខុជាដើម ព្រោះហេតុនោះអាយតនៈ

ទើបឈ្មោះថា **និវាសដ្ឋាន** គឺថាជាទីនៅ អាស្រ័យនៃចិត្តនិងចេតសិកទាំងនោះ ។

**អាករដ្ឋាន** គឺចិត្តនិងចេតសិកទាំងនោះកើតឡើង ចម្រើនឡើងក្នុងអាយតនៈទាំងឡាយ ដូចជារ៉ែក្នុងអណ្តូងរ៉ែ ព្រោះហេតុនោះអាយតនៈនេះទើបឈ្មោះថា **អាករដ្ឋាន** គឺជាអណ្តូងកើតនៃចិត្តនិងចេតសិកទាំងឡាយនោះៗ ។

**សមោសរណដ្ឋាន** គឺជាទីប្រជុំនៃចិត្តនិងចេតសិកទាំងនោះដោយអំណាចនៃវត្ថុ ទ្វារ និងអារម្មណ៍ ។ ចិត្តជាមនាយតនៈ ចេតសិកជាធម្មាយតនៈ វត្ថុទ្វារ និង អារម្មណ៍ក៏ជាអាយតនៈទាំងអស់កើតឡើងជុំគ្នាហើយក៏រលត់អស់ទៅ ។

**ភវនៈ** គឺអាយតនៈជាដែនកើតនៃចិត្តនិងចេតសិកដោយភាពជាទីអាស្រ័យ ពោលគឺអាយតនៈខាងក្នុងជានិស្សយប្បច្ច័យ ចំណែកអាយតនៈខាងក្រៅជាអារម្មណប្បច្ច័យ។

**ការណៈ** អាយតនៈ មានចក្ខុជាដើមជាការណៈគឺជាហេតុនៃចិត្ត និង ចេតសិកទាំងនោះឯង ព្រោះបើមិនមានអាយតនៈមានចក្ខុជាដើមទេ ចិត្តនិងចេតសិកក៏មិនមានដែរ ។

# ដោយអត្ថផ្សេងគ្នា

-**ចក្ខតីតិ ចក្ខុ** ឈ្មោះថាចក្ខុព្រោះអត្ថថា រមែងឃើញ អធិប្បាយថា ធ្វើរូបឱ្យប្រាកដ។

-**រូបយតីតិ រូបំ** ឈ្មោះថារូបរមែងឱ្យប្រាកដ អធិប្បាយថា វណ្ណរូបប្រាកដឱ្យឃើញ ។

-**សុណាតីតិ សោតំ** ឈ្មោះសោតៈព្រោះអត្ថថាបានស្តាប់ឮ។

-**សប្បតីតិ សទ្ទោ** ឈ្មោះថាសទ្ទៈព្រោះអត្ថថាផ្សាយចេញទៅ។

-**ឃាយតីតិ ឃានំ** ឈ្មោះថាឃានៈព្រោះអត្ថថាស្រូបហិតក្លិន

-**គន្ធយតីតិ គន្ធោ** ឈ្មោះគន្ធៈព្រោះអត្ថថាផ្សាយក្លិន គឺសម្តែង ទីនៅរបស់ខ្លួនឱ្យប្រាកដ ។

-**ជីវិតំ អវ្ហាយតីតិ ជិវ្ហា** ឈ្មោះថាជិវ្ហាព្រោះអត្ថថានាំមកនូវជីវិត ។

-**រសន្តិតំ សត្តាតិ រសោ** ឈ្មោះរសព្រោះអត្ថថាជាទីត្រេកអរ គឺជាទីពេញចិត្តនៃសត្វទាំងឡាយ ។

-**កុច្ឆិតានំ សាសវធម្មានំ អាយោតិ ករយោ** ឈ្មោះ ថាកាយ ព្រោះអត្ថថា ជាអណ្តូងកើតនៃសាសវធម៌ទាំងឡាយ ដែល បណ្ឌិតខ្ពើម ពាក្យថា **អាយោ** គឺទីកើត ។

-**ផុស្សិយតីតិ ផោដ្ឋព្វំ** ឈ្មោះថាផោដ្ឋព្វៈ ព្រោះអត្ថថារមែង ប៉ះពាល់បានដោយកាយ

-**មនុយតីតិ មនោ** ឈ្មោះថាមនៈព្រោះអត្ថថារមែងដឹង ។

-**អត្តនោ លក្ខណំ ធារយតីតិ ធម្មា** ឈ្មោះថាធម៌ព្រោះអត្ថថា រមែងទ្រទ្រង់ទុកនូវ លក្ខណៈរបស់ខ្លួន ។

## បដិច្ចសមុប្បាទវិភង្គ

១-វិនិច្ឆ័យដោយលក្ខណៈជាដើម

1-អវិជ្ជាជាបច្ច័យនៃសង្ខារ

-**អញ្ញាណលក្ខណា** មានការមិនដឹងឬជាបដិបក្ខចំពោះបញ្ញា ជាលក្ខណៈ

-**សម្មោហនរសា** មានការវង្វេងជាកិច្ច

-**ឆាទនបច្ចុប្បដ្ឋានា** មានការបិទនូវសភាវៈនៃអារម្មណ៍ជាផល

**-អាសវបទដ្ឋានា** មានអាសវៈជាបទដ្ឋាន ជាហេតុជិត ។

2-អភិសង្ខារជាបច្ច័យនៃវិញ្ញាណ

**-អភិសង្ខរណលក្ខណា** សង្ខារទាំងឡាយមានការតាក់តែង ជាលក្ខណៈ

**-អាយូហនរសា** មានការខ្វល់ខ្វាយឱ្យបដិសន្ធិវិញ្ញាណកើតឡើងជាកិច្ច

**-ចេតនាបច្ចុប្បដ្ឋានា** មានចេតនាជាផលឬជាអាការៈប្រាកដ

**-អវិជ្ជាបទដ្ឋានា** មានអវិជ្ជាបទដ្ឋាន ។

3-វិញ្ញាណជាបច្ច័យនៃនាមរូប

**-វិជានលក្ខណំ** វិញ្ញាណមានការដឹងអារម្មណ៍ជាលក្ខណៈ

**-បុព្វង្គមរសំ** មានការដល់មុនគឺជាធំជាប្រធាននៃចេតសិកជាកិច្ច

**-បដិសន្ធិបច្ចុប្បដ្ឋានំ** មានការកើតបន្តពីភពចាស់ទៅភពថ្មីជាផល

**-សង្ខារបទដ្ឋានំ** មានសង្ខារជាបទដ្ឋាន ឬ **វត្ថារម្មណបទដ្ឋានំ** មានវត្ថុនិងអារម្មណ៍ ជាបទដ្ឋាន ។

4_នាមរូបជាបច្ច័យនៃសឡាយតនៈ

**_នមនលក្ខណំ** នាមមានការបង្អោនទៅជាលក្ខណៈ

**_សម្បយោគរសំ** មានការប្រកបព្រមគ្នាជាកិច្ច

**_អវិនិព្ភោគបច្ចុប្បដ្ឋានំ** មានការមិនបែកគ្នាពីចិត្តជាផល

**_វិញ្ញាណបទដ្ឋានំ** មានវិញ្ញាណជាបទដ្ឋាន ។

**_រុបនលក្ខណំ** រូបមានការប្រែប្រួលជាលក្ខណៈ

**_វិកិរណរសំ** មានការខ្ចាត់ខ្ចាយជាកិច្ច

**_អព្យាកតបច្ចុប្បដ្ឋានំ** មានភាពជាអព្យាកតៈជាផល

**_វិញ្ញាណបទដ្ឋានំ** មានវិញ្ញាណជាបទដ្ឋាន ។

៥_សឡាយតនៈជាបច្ច័យនៃផស្សៈ

**_អាយតនលក្ខណំ** សឡាយតនៈមានការជាប់តគ្នានឹងអាយតនៈខាងក្រៅ និង ធ្វើវដ្តៈ ឱ្យវែងឆ្ងាយ ជាលក្ខណៈ។

**_ទស្សនាតិរសំ** មានការធ្វើឱ្យឃើញរូបជាដើមជាកិច្ច

**_វត្ថុទ្វារភាវបច្ចុប្បដ្ឋានំ** មានភាវៈជាវត្ថុនិងទ្វារជាផល

**_នាមរូបបទដ្ឋានំ** មាននាមរូបជាបទដ្ឋាន ។

បិដកលេខ២៩ទំព័រ១០៣ៈ ព្រះដ៏មានព្រះភាគទ្រង់ត្រាស់ឆ្លើយតបពាក្យទេវតាថា :

**នន្ទិ សញ្ញោជនោ លោកោ   វិតក្កស្ស វិចារណំ**

**តណ្ហាយ វិប្បហានេន   និព្វានំ ឥតិ វុច្ចតីតិ ។**

ប្រែថាៈ សត្វលោកមានសេចក្តីរីករាយ ជាគ្រឿងចងទុក វិតក្កៈ ជាគ្រឿងត្រេចទៅ របស់សត្វលោកនោះ ព្រោះលះបង់តណ្ហា ទើបហៅថា ព្រះនិព្វាន ។

*កំណត់ចំណាំៈការសិក្សានៅវត្តសំពៅមាសដើម ព.ស.២៥៥៦ ចុង ព.ស.២៥៥៥ នេះសិក្សាបាន៦៤ថ្ងៃគត់ ថ្ងៃសិក្សាចុង ក្រោយ គឺថ្ងៃ ព្រហស្បតិ៍ ៨កើត ខែទុតិយាសាធ ឆ្នាំរោង ចត្វាស័ក ព.ស.២៥៥៦ត្រូវថ្ងៃទី ២៦ កក្កដា ២០១២ ។*

## មេរៀនវត្តខ្មុណ្ណាលោម

*បរវេសនកាលថ្ងៃសៅរ៍ ២រោច ខែកត្តិក ឆ្នាំថោះត្រីស័ក ព.ស.២៥៥៥*

**គាថារបស់ព្រះអស្សជិត្ថេរ : ព្រះអស្សជិដ៏មានអាយុ** បានពោលនូវធម្មបរិយាយនេះដល់ បរិព្វាជកឈ្មោះសារីបុត្តថាៈ

**យេ ធម្មា ហេតុប្បភវា តេសំ ហេតុំ តថាគតោ** (អាហ)

**តេសញ្ច យោ និរោធោ ច ឯវំ វាទី មហាសមណោតិ ។**

ធម៌ទាំងឡាយណាកើតអំពីហេតុ ព្រះតថាគតទ្រង់សម្តែងហេតុនៃធម៌ទាំងឡាយនោះ ព្រមជាមួយគ្នានោះ ព្រះអង្គទ្រង់ត្រាស់អំពីការរលត់នូវធម៌ទាំងនោះ ព្រះមហាសមណៈទ្រង់សម្តែង យ៉ាងនេះ ។ (នេះជាគោលនៃអរិយសច្ចធម៌) ។

អដ្ឋកថា: បាទគាថា ថា **យេ ធម្មា ហេតុប្បភវា** មានសេចក្តីថា បញ្ចក្ខន្ធឈ្មោះថា ធម៌មានហេតុជាដែនកើត ។ព្រះថេរៈសម្តែងទុក្ខសច្ចៈ ដល់សារីបុត្តដោយពាក្យនេះ ។ បាទគាថា ថា **តេសំ ហេតុំ តថាគតោ** មានសេចក្តីថា សមុទយសច្ចៈ ឈ្មោះថា ហេតុនៃបញ្ចក្ខន្ធនោះ ។ ព្រះថេរៈសម្តែងថា ព្រះតថាគតត្រាស់សមុទយៈនោះឯង បាទគាថា ថា **តេសញ្ច យោ និរោធោ ច** នេះ ជាសច្ចៈ២ដែលព្រះថេរៈ សម្តែងហើយយ៉ាងនេះថា ការរលត់នៃសច្ចៈទាំងពីរនោះឯងនិងឧបាយ នៃការរលត់នូវសច្ចៈទាំងពីរនោះ ដូច្នោះឯង។ រួចហើយព្រះថេរៈបានញុំាងសេចក្តីនោះឱ្យទទួលគ្នាទើបពោលថា ព្រះមហាសមណៈមានប្រក្រតីពោលយ៉ាងនេះ ។

បិដកលេខ៥៣ឥតិវុត្តកៈទំព័រ៦២

**យោ សុខំ ទុក្ខតោ ទក្ខិ ទុក្ខមទ្ទក្ខិ សល្លតោ**
**អទុក្ខមសុខំ សន្តំ អទក្ខិ នំ អនិច្ចតោ**
**សវេ សម្មទ្ទសោ ភិក្ខុ យតោតត្ថ វិមុច្ចតិ**
**អភិញ្ញាវោសិតោ សន្តោ សវេ យោគាតិគោ មុនីតិ ។**

ភិក្ខុណាបានឃើញសុខវេទនាថាជាទុក្ខ បានឃើញទុក្ខវេទនាថាជាព្រួញ បានឃើញអទុក្ខមសុខវេទនា ដ៏ស្ងប់ល្អិតនោះថាជាធម៌មិនទៀង ភិក្ខុនោះឯងឈ្មោះថា ឃើញវេទនាទាំង៣ដោយប្រពៃ រមែងរួចស្រឡះក្នុងវេទនានោះ ដោយការសង្រួមកាយ វាចា ចិត្ត ភិក្ខុនោះឯងមាន ព្រហ្មចរិយៈ ប្រព្រឹត្តរួចហើយជាអ្នកស្ងប់រម្ងាប់ ជាមុនីកន្លងផុតចាកយោគៈ ។

## ប្រយោជន៍នៃការកំណត់ដឹងវេទនាទាំង៣

១_សុខវេទនាត្រូវឃើញថាជាទុក្ខព្រះដ៏មានព្រះភាគទ្រង់សម្តែងដល់ឧបាយសម្រាប់ដកនូវរាគៈ ព្រោះថារាគានុស័យដេកសម្ងំក្នុងសុខវេទនា ។

២_ទុក្ខវេទនាត្រូវឃើញថាជាសរ ព្រះដ៏មានព្រះភាគ ទ្រង់សម្តែងដល់ឧបាយសម្រាប់ដកនូវទោសៈព្រោះថា បដិឃានុស័យដេកសម្ងំក្នុងទុក្ខវេទនា ។

៣_អទុក្ខមសុខវេទនា ត្រូវឃើញថាមិនទៀង ព្រះដ៏មានព្រះភាគទ្រង់សម្តែងដល់ឧបាយសម្រាប់ដកនូវមោហៈ ព្រោះថា អវិជ្ជានុស័យដេកសម្ងំនៅក្នុងអទុក្ខមសុខវេទនា ។ អ្នកសិក្សាគប្បីចាប់ទិដ្ឋានុស័យនិងមានានុស័យ ដែលជាចំណែកនៃរាគៈ ចូលក្នុងរាគានុស័យផង ព្រោះបុគ្គលដែលមានទិដ្ឋិទាំងឡាយ រមែងប្រកាន់មាំក្នុងសក្កាយដោយន័យ មានជាអាទិ៍ថា ជារបស់យើនយូរហើយភ្លើតភ្លើនជាមួយសេចក្តីសុខ ។ ចំណែកបុគ្គលដែលមានមានៈក្នុងជាតិកំណើតជាដើមថា យើងជាបុគ្គលប្រសើរបំផុត ។

វិចិកិច្ឆានុស័យប្រព្រឹត្តទៅក្នុងពួកអវិជ្ជា ក៏ត្រូវចាត់ចូលក្នុងអវិជ្ជានុស័យផងដែរ។ ដូចក្នុងបដិច្ចសមុប្បាទវិភង្គថា ព្រោះវេទនាជាបច្ច័យ វិចិកិច្ឆាទើបកើតមានឡើង ។

អនុស័យទាំងឡាយ កាលដែលមានហេតុសមគួរ រាគៈជាដើមកើតឡើង ទើបដូចជាដេកក្នុងសន្តាននោះព្រោះលះនៅមិនទាន់_

បានដោយអរិយមគ្គ ។

១_ព្រះដ៏មានព្រះភាគទ្រង់សម្តែងការលះ សង្កិលេស គឺតណ្ហាដោយព្រះពុទ្ធដីកាចំណុចទី១ ព្រោះសង្កិលេស គឺតណ្ហា នោះជាហេតុឱ្យពេញចិត្តក្នុងសេចក្តីសុខ។

២_ទ្រង់សម្តែងការលះសង្កិលេស គឺទុច្ចរិត ដោយព្រះពុទ្ធដីកាចំណុចទី២ ព្រោះសង្កិលេសសត្វទាំងឡាយមិនស្គាល់សេចក្តីទុក្ខតាមសេចក្តីពិត ទើបប្រព្រឹត្តទុច្ចរិតដើម្បីដោះស្រាយនូវសេចក្តីទុក្ខនោះ ។

៣_ទ្រង់សម្តែងការលះសង្កិលេស គឺទិដ្ឋិដោយព្រះពុទ្ធដីកាចំណុចទី៣ ព្រោះបុគ្គល ដែលឃើញអទុក្ខមសុខវេទនា មានសភាពមិនទៀងតាមពិតរមែងមិនមាននូវសង្កិលេសគឺទិដ្ឋិឡើយ ។ ចំណុចនេះទ្រង់សម្តែងទិដ្ឋិថាជាគ្រឿងសម្គាល់នៃអវិជ្ជា ។

១_ដោយព្រះពុទ្ធដីកាចំណុចទី ១ ទ្រង់សម្តែងដល់ការកំណត់ដឹងនូវវិបរិណាមទុក្ខ ។

ដោយព្រះអង្គទ្រង់ត្រាស់ថា **សុខា ភិក្ខវេ វេទនា ទុក្ខតោ ទដ្ឋព្វា** ម្នាលភិក្ខុទាំងឡាយ សុខវេទនាគប្បីឃើញថាជាទុក្ខគឺ

ឃើញដោយញាណចក្ខុថាជាទុក្ខ របស់ណាមិនទៀងរបស់នោះជាទុក្ខ ។

២-ដោយព្រះពុទ្ធដីកាចំណុចទី២ ទ្រង់សម្ដែងដល់ការកំណត់ដឹងនូវទុក្ខទុក្ខ ដោយព្រះ អង្គទ្រង់ត្រាស់ថា **ទុក្ខា វេទនា សល្លតោ ទដ្ឋព្វា** គប្បីឃើញទុក្ខវេទនាថាជាសរ ព្រោះដោយអត្ថថា នាំចេញទៅបានដោយលំបាកដោយអត្ថថា បៀតបៀនខាងក្នុងនិងដោយ អត្ថថា លំបាកទ្រាំ ។

៣-ដោយព្រះពុទ្ធដីកាចំណុចទី ៣ ទ្រង់សម្ដែងដល់ការកំណត់ដឹងនូវសង្ខារទុក្ខ ដោយព្រះអង្គទ្រង់ត្រាស់ថា **អទុក្ខមសុខា វេទនា អនិច្ចតោ ទដ្ឋព្វា** គប្បីឃើញអទុក្ខមសុខវេទនាថាមិនទៀងព្រោះដោយអត្ថថា មានហើយត្រឡប់រកមានមិនបានព្រោះកើតហើយ វិនាសទៅជាទីបំផុត ព្រោះជាសភាវៈមួយពេលមួយគ្រា និងព្រោះជាសភាវៈបដិបក្ខ ជាមួយនឹងភាពទៀង ។

# ព្រះអដ្ឋកថាសច្ចវិភង្គ

## ១-វិនិច្ឆ័យដោយសុញ្ញតា

ទុក្ខមេវ ហិ ន កោចិ ទុក្ខិតោ   ការកោ នកិរិយាវ វិជ្ជតិ
អត្ថិ និព្វុតិ ន និព្វុតោ បុមា      មគ្គមត្ថិ គមកោ ន វិជ្ជតិ ។

សេចក្តីពិត គឺមានតែទុក្ខប៉ុណ្ណោះ បុគ្គលណាៗជាអ្នកទុក្ខមិនមានឡើយ ការធ្វើមាន តែបុគ្គលអ្នកធ្វើមិនមាន ការរលត់មាន តែបុគ្គលអ្នករលត់មិនមាន ផ្លូវមាន តែបុគ្គល អ្នកដើរមិនមាន ។

១_សុញ្ញតាម្យ៉ាងទៀត នៅក្នុងសច្ចៈទាំង៤គប្បីជ្រាប នូវសច្ចៈ២ខាងដើមថា សូន្យចាក ភាពទៀង ភាពស្អាត ភាពសុខ និងភាពជាអត្តា ។ អមតបទសូន្យចាកអត្តា ចំណែកមគ្គសច្ចសូន្យចាកភាពទៀង ភាពសុខនិងភាពជាអត្តា។

២_សច្ចៈ៣សូន្យចាកនិរោធរីឯនិរោធសូន្យចាកសច្ចៈ៣

៣_សច្ចៈដែលជាហេតុសូន្យចាកសច្ចៈដែលជាផល សូម្បីសច្ចៈដែលជាផលនោះក៏សូន្យចាកសច្ចៈដែលជាផលដែរ ។

## ២_វិនិច្ឆ័យដោយកិច្ចនៃញាណ

១-**អនុពោធញ្ញាណ**=ញាណដែលដឹងដោយលំដាប់

២-**បដិវេធញ្ញាណ**=ញាណដែលចាក់ធ្លុះ បណ្តាញាណទាំង២នេះអនុពោធញ្ញាណ គឺជាលោកិយៈរមែងប្រព្រឹត្តទៅក្នុងនិរោធ មគ្គដោយអំណាចនៃការស្តាប់ជាដើម ។ បដិវេធញ្ញាណគឺជាលោកុត្តរៈធ្វើនិរោធឱ្យជាអារម្មណ៍ហើយចាក់ធ្លុះសច្ចៈទាំង ៤ ដោយកិច្ចដូចដែលព្រះដ៏មានព្រះភាគទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ បុគ្គលណាឃើញទុក្ខ បុគ្គលនោះរមែងឃើញទុក្ខសមុទយៈផង ឃើញទុក្ខនិរោធផង ឃើញទុក្ខនិរោធគាមិនីបដិបទាផងដូច្នេះជាដើម។ម្យ៉ាងទៀតសច្ចញ្ញាណដែលជាលោកិយៈនេះទុក្ខញ្ញាណ រមែងហាមនូវសក្កាយទិដ្ឋិដែលកំពុងប្រព្រឹត្តទៅជាបរិយុដ្ឋានដោយអំណាចនៃការគ្របសង្កត់។ សមុទយញ្ញាណរមែងហាមនូវឧច្ឆេទទិដ្ឋិ។និរោធញ្ញាណរមែងហាមនូវសស្សតទិដ្ឋិមគ្គញ្ញាណរមែងហាមនូវអកិរិយទិដ្ឋិ ។

ម្យ៉ាងទៀត **ទុក្ខញ្ញាណ** រមែងហាមការបដិបត្តិខុសក្នុងផលគឺការដែលបានសម្គាល់ ខុសក្នុងបញ្ចក្ខន្ធថាទៀង ថាស្អាត ថាសុខ និងថាមានអត្តាតួខ្លួន ។ សមុទយញ្ញាណហាមការបដិបត្តិ

ខុសក្នុងហេតុគឺការដែលប្រព្រឹត្តទៅ ក្នុងការរាប់អានចំពោះអ្វីដែលមិនមែនជាហេតុ ថាជាហេតុ ដូចជាយល់ថា លោកនេះរមែងប្រព្រឹត្តទៅដោយព្រះជាម្ចាស់ ព្រះព្រហ្ម ព្រះសិវៈឬ ព្រះដទៃទៀត ប្រព្រឹត្តទៅដោយខ្លួនឯងជាដើម ។ និរោធញ្ញាណហាមការប្រតិបត្តិខុសក្នុងនិរោធ គឺប្រកាន់ក្នុងអរូបលោក ឬក្នុងភូមិដែលជាកំពូលនៃភពជាដើមថាជាព្រះនិព្វាន។

មគ្គញ្ញាណហាមការបដិបត្តិខុសក្នុងឧបាយ គឺមានការប្រកាន់ក្នុងផ្លូវដែលមិនបរិសុទ្ធ ដូចជា កាមសុខល្លិកានុយោគ និង អត្តកិលមថានុយោគជាដើមថាជាមគ្គដ៏បរិសុទ្ធ។ព្រោះហេតុនោះទើបបណ្ឌិតចងគាថានេះទុកថា:

**លោកេ លោកប្បភវេ លោកត្ថគមេ សិវេ ច តទុបាយេ សម្មុយ្ហតិ តាវ នរោ ន វិជានាតិ យាវ សច្ចានិ** ។ ប្រែថា នរជន មិនទាន់បានត្រាស់ដឹង នូវសច្ចៈទាំងឡាយដរាបណា គេរមែងវង្វេងក្នុងលោក ក្នុងហេតុដែលនាំឱ្យកើតលោក ក្នុងព្រះនិព្វានដែលជាការរលត់ទៅនៃលោក និងក្នុងឧបាយនៃការរលត់លោកនោះ ដរាបនោះឯង។

## ៣-វិនិច្ឆ័យដោយឧបមា

**១-ឧបមាដូចរបស់ធ្ងន់:** គប្បីឃើញទុក្ខសច្ចដូចរបស់ធ្ងន់ សមុទយ-សច្ចដូចការលើករបស់ធ្ងន់ និរោធសច្ចៈដូចការដាក់ចុះហើយនូវរបស់ធ្ងន់,មគ្គសច្ចដូចឧបាយនៃការដាក់ចុះនូវរបស់ធ្ងន់នោះឯង

**២-ឧបមាដូចរោគ:** គប្បីឃើញទុក្ខសច្ចៈដូចរោគ សមុទយសច្ចៈដូចសមុដ្ឋាននៃរោគ និរោធសច្ចដូចការស្ងប់នៃរោគ មគ្គសច្ចដូចភេសជ្ជៈដូចថ្នាំកែរោគ ។

**៣-ឧបមាដូចស្រុកកើតទុរ្ភិក្ស** : គប្បីឃើញទុក្ខសច្ចៈដូចស្រុកកើតទុរ្ភិក្ស សមុទយសច្ចៈដូចភ្លៀងមិនល្អ និរោធសច្ចដូចស្រុកសម្បូរបាយ មគ្គសច្ចដូចភ្លៀង ការមានភ្លៀងធ្លាក់ល្អ ។

**៤-ឧបមាដូចពៀរវេរា**.....

**៥-ឧបមាដូចដើមឈើមានពិស**.....

**៦-ឧបមាដូចភ័យ**.............

**៧-ឧបមាដូចត្រើយអាយ** : គប្បីឃើញទុក្ខសច្ចៈដូចត្រើយអាយ សមុទយសច្ចៈដូចអន្លង់ទឹកធំ និរោធសច្ចដូចត្រើយនាយ មគ្គសច្ច-ដូចការព្យាយាមហែលឱ្យដល់ត្រើយនាយដូច្នោះឯង។

## ៤_វិនិច្ឆ័យដោយសភាគៈនិងវិសភាគៈ

១_សច្ចៈទាំង៤ជាសភាគៈគឺមានចំណែកស្មើគ្នា ដោយជារបស់ពិត ដោយជារបស់សូន្យចាកខ្លួន និងដោយជារបស់ចាក់ធ្លុះបានដោយលំបាក។ ជាវិសភាគៈគឺមានចំណែកមិនស្មើគ្នា ដោយកំណត់លក្ខណៈរបស់ខ្លួន។

២_សច្ចៈ២ដំបូង គឺទុក្ខសច្ចៈនិងសមុទយសច្ចៈជាសភាគៈព្រោះជាធម៌ជ្រៅ ដោយអត្ថថាចូលដល់បានដោយក្រ និងព្រោះជាលោកិយៈឬជាសាសវធម៌បានដល់ធម៌ជាអារម្មណ៍នៃអាសវៈជាវិសភាគ ព្រោះចែកចេញជាផលនិងហេតុម្យ៉ាងទៀតព្រោះជាធម៌គួរកំណត់ដឹង និងគួរលះ **បរិញ្ញេយ្យបហាតព្វកិច្ច**។ សច្ចៈពីរខាងក្រោយគឺនិរោធសច្ចៈនិងមគ្គសច្ចៈជាសភាគៈព្រោះជាធម៌ជ្រៅនិងព្រោះជាលោកុត្តរៈ ឬ ជាអនាសវធម៌បានដល់ធម៌ មិនជាអារម្មណ៍នៃអាសវៈ។ ជាវិសភាគៈព្រោះជាវិសយៈ និងវិសយី និរោធជាវិសយៈ ព្រោះជាអារម្មណ៍របស់មគ្គ ឯចំណែកមគ្គជាវិសយីព្រោះមាននិរោធគឺព្រះនិព្វានជាអារម្មណ៍ ម្យ៉ាងទៀត ព្រោះជាធម៌គួរធ្វើឱ្យជាក់ច្បាស់ សច្ឆិកាតព្វនិងព្រោះជាធម៌គួរចម្រើនភាវេតព្វៈ។

៣_សច្ចៈទី១និងសច្ចៈទី៣ ជាសភាគៈព្រោះជាផល ជាវិសភាគៈព្រោះជាសង្ខតៈ និងអសង្ខតៈ។ សច្ចៈទី២ និងទី៤ជាសភាគៈជាព្រោះជាហេតុ ជាវិសភាគៈព្រោះជាអកុសលនិងព្រោះជាកុសល។

៤_សច្ចៈទី១និងសច្ចៈទី៤ជាសភាគៈព្រោះជាសង្ខតៈ ជាវិសភាគៈព្រោះជាលោកិយៈ និង លោកុត្តរៈ ។

_សច្ចៈទី២និងសច្ចៈទី៣ជាសភាគៈ ព្រោះជានេវសេក្ខានាសេក្ខា ជាវិសភាគៈព្រោះជាសារម្មណៈ និង អនារម្មណៈ។

## ៥_វិនិច្ឆ័យដោយចតុក្កៈ

១_ក្នុងចតុក្កៈនេះធម៌ទាំងឡាយដែលសម្បយុត្តដោយមគ្គ និងសមញ្ញផលទាំងឡាយឈ្មោះថាជាទុក្ខ ព្រោះជាសង្ខារទុក្ខដោយព្រះបាឡីថា **យទនិច្ចំ តំ ទុក្ខំ** របស់ណាមិនទៀង របស់នោះជាទុក្ខ ប៉ុន្តែទុក្ខនេះមិនមែនអរិយសច្ចៈ សច្ចវិមុត្តិ ។ និរោធជាអរិយសច្ច តែមិនមែនជាទុក្ខ ។ ចំណែកអរិយសច្ចពីរបានដល់សមុទយសច្ច និងមគ្គសច្ចគឺជាទុក្ខ ព្រោះការមិនទៀង តែមិនមែនទុក្ខអរិយសច្ច ដែលកុលបុត្តអ្នកប្រព្រឹត្តព្រហ្មចរិយធម៌ក្នុងសម្នាក់ព្រះដ៏មានព្រះភាគ គប្បីកំណត់ដឹងនោះឡើយ។

-ចំណែកឧបាទានក្ខន្ធ៥ វៀរតណ្ហាចេញហើយ គឺទាំងជាទុក្ខ ព្រោះមិនទៀង ទាំងជាទុក្ខអរិយសច្ច ។

-ធម៌ដែលសម្បយុត្តដោយមគ្គនិងសាមញ្ញផល មិនមែនជាទុក្ខ ដែលកុលបុត្តអ្នកប្រព្រឹត្តព្រហ្មចរិយធម៌ក្នុងសម្នាក់ ព្រះដ៏មានព្រះ-ភាគ គប្បីកំណត់ដឹងឡើយ ទាំងមិនមែនជាអរិយសច្ច ។

២-កិលេសដែលជាសមុទយសច្ចក្រៅពីតណ្ហា ជាសមុទយសច្ច ព្រោះអត្ថថា ធ្វើឱ្យកើតទុក្ខ តែមិនមែនជាសមុទយសច្ច ។ និរោធជាអរិយសច្ចៈ តែមិនមែនជាសមុទយសច្ចៈ។ ទុក្ខសច្ចៈ និង មគ្គសច្ចៈជាសមុទយៈក៏បានព្រោះជាហេតុនៃផលរបស់ខ្លួន តែមិន មែនជាសមុទយ ដែលជាបហាតព្វធម៌ឡើយ។ តណ្ហាទាំងជា សមុទយៈទាំងជាអរិយសច្ចដែលជាបហាតព្វធម៌។ ធម៌ដែលសម្ប-យុត្តដោយមគ្គ និងសាមញ្ញផលមិនមែនសមុទយផង ទាំងមិន មែនជាអរិយសច្ចផង។ មិនមែនជាសមុទយៈដែលគប្បីលះ ។

៣-សង្ខារនិរោធ និង និរោធសមាបត្តិ ជានិរោធ តែមិនមែន ជានិរោធអរិយសច្ច ។ សមុទយៈ ជាអរិយសច្ច តែមិនមែនជា និរោធសច្ច ។ ទុក្ខសច្ច និងមគ្គសច្ចជានិរោធក៏បានដែរ គឺខណ-

និរោធ តែមិនមែនជានិរោធអរិយសច្ច ។

អសង្ខតធាតុ ទាំងជានិរោធ ទាំងជាអរិយសច្ច ។ ធម៌ដែលសម្បយុត្តដោយមគ្គ និងសាមញ្ញផលមិនមែនជានិរោធដែលគប្បីជាក់ច្បាស់ ទាំងមិនមែនជាអរិយសច្ច ។

៤-អង្គមគ្គដទៃ ក្រៅអំពីអរិយមគ្គ ជាមគ្គ តែមិនមែនជាមគ្គអរិយសច្ចៈ។ និរោធជាអរិយសច្ច តែមិនមែនជាមគ្គ។ ទុក្ខនិងសមុទយៈ ជាមគ្គក៏បានដែរ ព្រោះជាផ្លូវទៅកាន់ភព តែមិនមែនជាអរិយមគ្គដែលគួរចម្រើនដើម្បីនិរោធឡើយ។ និរោធគាមិនីបដិបទា ទាំងជាមគ្គ ទាំងជាអរិយសច្ចៈដោយប្រការទាំងពួង ។ ធម៌ដែលសម្បយុត្តដោយមគ្គ និង សាមញ្ញផលមិនមែន ជាមគ្គដែលគប្បីចម្រើន និងមិនមែនជាអរិយសច្ច ។

## ៦-វិនិច្ឆ័យដោយអត្ថ

-ប្រសិនបើមានពាក្យសួរថា អ្វីដែលជាអត្ថរបស់សច្ចៈនោះ នឹងមានពាក្យតបយ៉ាងពិស្ដារថាភាវៈណា សច្ចៈទាំង៤កាលដែលបុគ្គលសម្លឹងមើលដោយបញ្ញាចក្ខុ ភាវៈនោះរមែងមិនវិបរិត ដូចជាកលមាយា មិនបញ្ឆោតភ្នែកដូចជាថ្ងៃបណ្ដើរកូន និង មិនជា

សភាវៈដែលអ្នកណាៗ រកមិនបានដូចអត្ថារបស់ពួកអន្យតិរ្ថិយឡើយ។ដោយពិត សច្ចៈគឺជាគោចរ អារម្មណ៍នៃអរិយញ្ញាណជារបស់ពិតប្រាកដមិនវិបរិត ដូចជាលក្ខណៈភ្លើង និង ដូចជាធម្មតារបស់សត្វលោក សត្វលោកត្រូវកើតចាស់ ឈឺ ស្លាប់ជាធម្មតា ដូច្នោះឯង។ បណ្ឌិតគប្បីជ្រាបថា នេះជា អត្ថរបស់សច្ចៈដូចដែលព្រះពុទ្ធអង្គទ្រង់ត្រាស់ថា **ឥទំ ទុក្ខន្តិ ខោ ភិក្ខវេ តថមេតំ អវិតថមេតំ អនញ្ញថមេតំ** ម្នាលភិក្ខុទាំងឡាយពាក្យថានេះទុក្ខនោះឯងគឺជារបស់ពិតនោះឯង គឺជារបស់មិនខុសនោះឯងគឺជារបស់មិនទៅជាប្រការដទៃឡើយ ។ ម្យ៉ាងទៀតព្រះអង្គទ្រង់ត្រាស់ថាៈ

**នាពាធកំ យតោ ទុក្ខំ ទុក្ខា អញ្ញំ នាពាធកំ**
**ពាធកត្តនិយាមេន តតោ សច្ចមិទំ មតំ ។**

ប្រែថាៈ មិនមានការបៀតបៀន មានទុក្ខអំពីណាគឺថាក្រៅអំពីទុក្ខមិនមានការបៀតបៀនឡើយ ព្រោះដូច្នោះទុក្ខនេះឯងបណ្ឌិតគប្បីដឹងថាជាសច្ចៈដោយកំណត់អត្ថថាជាតួបៀតបៀន។

### ៧_វិនិច្ឆ័យដោយជាធម៌តែម្យ៉ាងជាដើម

១_ទុក្ខសច្ចៈទាំងអស់ឈ្មោះថា តែម្យ៉ាង ព្រោះជា **បវត្តិ** គឺជាធម៌ប្រព្រឹត្តទៅក្នុងវដ្តៈ។ជាពីរយ៉ាង គឺនាម១និងរូប១។ ជា៣ យ៉ាងគឺ កាមភព១ រូបភព១ និងអរូបភព១។ ជា៤យ៉ាង គឺ អាហារ៤ គឺ កវឡិង្ការាហារ ផស្សាហារ មនោសញ្ចេតនាហារ វិញ្ញាណាហារ។ ជា៥យ៉ាងគឺ ឧបាទានក្ខន្ធ៥។

២_សមុទយសច្ចៈតែម្យ៉ាង ព្រោះជាសភាវៈញ៉ាំងវដ្តៈឱ្យប្រព្រឹត្ត ។ ជាពីរយ៉ាងគឺ ជាធម៌សម្បយុត្តដោយទិដ្ឋិ និងមិនសម្បយុត្តដោយទិដ្ឋិ។ជាបីយ៉ាងដោយចែកជាកាមតណ្ហា ភវតណ្ហា និង វិភវតណ្ហា ។ជា៤យ៉ាងគឺជាទោសដែលមគ្គ៤គប្បីលះ។ជា៥យ៉ាង ដោយចែកតាមអារម្មណ៍មានសេចក្តីត្រេកអរក្រៃលែងក្នុងរូបជាដើម។

ជា៦យ៉ាងគឺ ដោយប្រភេទនៃកងតណ្ហា៦។

៣_និរោធសច្ចៈ តែម្យ៉ាង ព្រោះជាអសង្ខតធាតុ។ តែដោយបរិយាយគឺអម និរោធ មានពីរយ៉ាងបានដល់ **សឧបាទិសេសនិព្វាន** និង **អនុបាទិសេសនិព្វាន** ។ជាបីយ៉ាង ព្រោះស្ងប់នូវភពទាំង៣។ជា៤យ៉ាង ព្រោះជាអារម្មណ៍ឱ្យមគ្គ៤បានសម្រេច។ ជា

៥យ៉ាង ព្រោះស្ងប់សេចក្តី ត្រេកអរក្រៃលែងក្នុងរូបជាដើម។ ជា៦ យ៉ាងដោយប្រភេទនៃការអស់កងតណ្ហា៦ ។

៤_មគ្គសច្ចៈ តែម្យ៉ាង ព្រោះជាធម៌គួរចម្រើន ។ជាពីរយ៉ាង ដោយចែកជា សមថៈនិង វិបស្សនា ឬម្យ៉ាងទៀត ជាពីរយ៉ាង ដោយប្រភេទនៃទស្សនៈ និង ភាវនា ។

_សច្ចៈទាំងបួនមានតែម្យ៉ាង ព្រោះជាធម៌ដែលមានពិត ឬព្រោះ ជាអភិញ្ញេយ្យធម៌ គឺធម៌ ដែលគប្បីដឹងដ៏ក្រៃលែង។ ពីរយ៉ាង ដោយលោកិយៈនិងលោកុត្តរៈ ម្យ៉ាងទៀតពីរយ៉ាងដោយសង្ខតៈ និងអសង្ខតៈ។

## ៨_វិនិច្ឆ័យដោយលំដាប់

១_អរិយសច្ច៤ ពោលដោយលំដាប់នៃទេសនា គឺទុក្ខសច្ចជា សច្ចៈដែលដឹងបានងាយជាង ព្រោះជាធម៌គ្រោតគ្រាត និង ព្រោះ ជាធម៌ទូទៅដល់សត្វទាំងអស់ ព្រោះហេតុដូច្នោះទើបទ្រង់ត្រាស់ សម្តែងមុន។ សមុទយសច្ច ត្រាស់ក្នុងលំដាប់នៃទុក្ខសច្ច ដើម្បី សម្តែងហេតុនៃទុក្ខសច្ចនោះឯង ។ និរោធសច្ច ត្រាស់ទុក ដោយលំដាប់នៃសមុទយសច្ចៈនោះ ដើម្បីសម្តែងឱ្យដឹងថា ព្រោះ

ហេតុរលត់ ផលទើបរលត់។មគ្គសច្ចៈទ្រង់ត្រាស់សម្តែងក្នុងទីបំផុតដើម្បីសម្តែងឧបាយជាគ្រឿងសម្រេចនូវនិរោធសច្ចៈនោះ។

២.ព្រះដ៏មានព្រះភាគ ទ្រង់ត្រាស់ទុក្ខសច្ចៈមុន ដើម្បីឱ្យកើតសេចក្តីសង្វេគដល់ពួកសត្វដែល ជាអ្នកត្រេកអរនឹងប្រាថ្នា សេចក្តីសុខក្នុងភព។ត្រាស់សមុទយសច្ចៈក្នុងលំដាប់នៃទុក្ខសច្ចនោះដើម្បីឱ្យដឹងថា ទុក្ខនោះឯងមិនមានឡើយ បើមិនមានតណ្ហាជាតួសាងទេនោះ មិនមែនព្រោះហេតុខាងក្រៅមាន ព្រះជាម្ចាស់ជាដើមជាអ្នកបណ្តាលឡើយគឺដោយពិត ទុក្ខមានព្រោះមានតណ្ហា។

## អរិយមគ្គក្នុងព្រះពុទ្ធសាសនា

១.មគ្គក្នុងឋានៈជាមជ្ឈិមប្បដិបទា

២.មគ្គក្នុងឋានៈជាផ្លូវនៃជីវិតទាំងបព្វជិតទាំងគ្រហស្ថ

៣.មគ្គក្នុងឋានៈជាប្រក្រតីអាស្រ័យកល្យាណមិត្ត

៤.មគ្គក្នុងឋានៈជាផ្លូវនាំទៅរកការអស់កម្ម

៥.មគ្គក្នុងឋានៈជាក្បួន គ្រាន់តែជាឧបករណ៏សម្រាប់

ប្រើប៉ុណ្ណោះ មិនមែនសម្រាប់ប្រកាន់ឡើយ ។

៦_មគ្គក្នុងឋានៈជាព្រហ្មចរិយធម៌

៧_មគ្គក្នុងឋានៈជាត្រៃសិក្ខា ។

## _សិក្សាតាមព្រះត្រៃបិដក

**១_មគ្គក្នុងឋានៈជាមជ្ឈិមប្បដិបទា** ក្នុងវិន័យបិដកលេខ៦ ទំព័រ ២៨ ព្រះដ៏មានព្រះភាគ ទ្រង់ត្រាស់ហៅបញ្ចវគ្គិយភិក្ខុទាំងឡាយមក-ហើយត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ធម៌អមខាងទាំងពីរប្រការនេះគឺបព្វជិតមិនគួរសេពគប់ឡើយ ធម៌អមខាងទាំងពីរប្រការនោះគឺ ការប្រកបរឿយៗនូវសេចក្ដីជាប់ជំពាក់កាមសុខក្នុងកាមទាំងឡាយណាដែលជាធម៌ថោកទាប ជារបស់អ្នកស្រុកជារបស់បុថុជ្ជន មិនមែនជារបស់អរិយបុគ្គល មិនប្រកបដោយប្រយោជន៍ មួយទៀត ការប្រកបរឿយៗនូវ សេចក្ដីព្យាយាមធ្វើខ្លួនឯងឱ្យលំបាកតែងនាំមកនូវសេចក្ដីទុក្ខ មិនមែនជារបស់អរិយបុគ្គលមិនប្រកបដោយប្រយោជន៍ឡើយ។ ម្នាលភិក្ខុទាំង-ឡាយមជ្ឈិមាបដិបទាគឺសេចក្ដីប្រតិបត្តិយ៉ាងកណ្ដាលមិនប៉ះពាល់

នឹងធម៌អមខាងទាំងពីរនោះ តថាគតបាន ត្រាស់ដឹងហើយជាសេចក្តីប្រតិបត្តិធ្វើឱ្យកើតបញ្ញាចក្ខុ ប្រព្រឹត្ត ទៅដើម្បីសេចក្តីរំងាប់នូវកិលេស ដើម្បីស្គាល់នូវអរិយសច្ចៈ ដើម្បីត្រាស់នូវអរិយសច្ចៈ ដើម្បីនិព្វាន។ ម្នាលភិក្ខុទាំងឡាយ ក៏មជ្ឈិមាបដិបទានោះដូចម្តេច ដែលតថាគតត្រាស់ដឹងហើយ គឺអរិយមគ្គប្រកបដោយអង្គ៨នោះឯង ។ ល ។

**២.មគ្គក្នុងឋានៈជាផ្លូវនៃជីវិតទាំងបព្វជិតទាំងគ្រហស្ថ** ក្នុងបិដកលេខ ៣៧ ទំព័រ ៤១ ព្រះដ៏ មានព្រះភាគទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតសរសើរតែបដិបទាត្រូវ របស់គ្រហស្ថក្តី របស់បព្វជិតក្តី។ម្នាលភិក្ខុទាំងឡាយ គ្រហស្ថក្តីបព្វជិតក្តីកាលប្រតិបត្តិត្រូវហើយរមែងញ៉ាំងធម៌ដែលបណ្ឌិតគប្បីដឹង គឺអរិយមគ្គ៨ជាកុសលនេះឱ្យសម្រេចទៅបានព្រោះការប្រតិបត្តិត្រូវជាអធិករណ-ហេតុ។ ម្នាលភិក្ខុទាំងឡាយ បដិបទាត្រូវ តើដូចម្តេច? អ្វីខ្លះ? គឺសម្មាទិដ្ឋិ ។ល។សម្មាសមាធិ។ ក្នុងបិដកលេខ២៤ ទំព័រ៣៧វច្ឆ-គោត្តបរិព្វាជក បានពោលថាបពិត្រព្រះគោតមដ៏ចម្រើន ដូចទន្លេគង្គាតែងមានទំនាប ទៅរកសមុទ្រជម្រាលទៅរកសមុទ្រ ទេរ

ទៅរកសមុទ្រ ទល់នឹងសមុទ្រ ទើបឈប់នៅយ៉ាងណា បរិស័ទរបស់ព្រះគោតមដ៏ចម្រើននេះទាំងគ្រហស្ថ ទាំងបព្វជិត តែងមានទំនោបទៅរកព្រះនិព្វាន ជម្រាលទៅរកព្រះនិព្វាន ទេរទៅរកព្រះនិព្វាន ដរាបទល់នឹងព្រះនិព្វាន ទើបឈប់ ក៏យ៉ាងនោះដែរ។

**៣-មគ្គក្នុងឋានៈជាព្រហ្មចរិយធម៌អាស្រ័យនឹងកល្យាណមិត្ត**

ក្នុងបិដកលេខ៣៧ ទំព័រ៦៣ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំង-ឡាយ ការរះឡើយនៃអរុណ នេះជាប្រធាន នេះជាបុព្វនិមិត្តនៃព្រះអាទិត្យដែលរះឡើង។ម្នាលភិក្ខុទាំងឡាយ ការមានមិត្តល្អ នេះជាប្រធាននេះជាបុព្វនិមិត្តប្រព្រឹត្តទៅ ដើម្បីញ៉ាំងអរិយមគ្គប្រកបដោយអង្គ៨ឱ្យកើតឡើងដល់ភិក្ខុដោយប្រការយ៉ាងនេះ ។ ម្នាលភិក្ខុទាំងឡាយដំណើរនេះជាទីសង្ឃឹម នៃភិក្ខុដែលមានមិត្រល្អភិក្ខុនោះនឹងចម្រើនអរិយមគ្គប្រកបដោយអង្គ៨ធ្វើអរិយមគ្គប្រកបដោយអង្គ៨ឱ្យចម្រើនឡើង ។

**៤-មគ្គក្នុងឋានៈជាផ្លូវឱ្យដល់នូវការអស់កម្ម** ក្នុងបិដកលេខ ៣៥ ទំព័រ ៣០៦ ព្រះដ៏មានព្រះភាគទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ចុះបដិបទាជាដំណើរទៅកាន់ទីរលត់កម្មតើដូចម្តេច គឺមគ្គប្រកប-

ដោយអង្គ ៨ ប្រការដ៏ប្រសើរនេះឯង ។

**៥-មគ្គក្នុងឋានៈជាក្បូន** ក្នុងបិដកលេខ ២២ ទំព័រ ១៦៣ ទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ បើអ្នកទាំងឡាយមិនជាប់ជំពាក់ មិនរីករាយ មិនកួចកាន់ មិនរាប់អាននូវទិដ្ឋិដែលបរិសុទ្ធយ៉ាងនេះ ផូរផង់យ៉ាងនេះ ដោយអំណាចតណ្ហានិងទិដ្ឋិទេ ម្នាលភិក្ខុ-ទាំងឡាយ តើអ្នកទាំងឡាយយល់ច្បាស់នូវធម៌ ដែលមានឧបមាដូចជាក្បូនដែលតថាគតសម្ដែងហើយ ដើម្បីនឹងរើខ្លួនចេញចាកអំពីឱឃៈទាំង៤ មិនប្រព្រឹត្តទៅដើម្បីសេចក្ដីប្រកាន់ដែរ ឬទេ ? ព្រះករុណាព្រះអង្គ ។

**៦-មគ្គក្នុងឋានៈជាព្រហ្មចរិយធម៌ ដើម្បីប្រយោជន៍សុខដល់ពពួកជនច្រើន** ក្នុងបិដកលេខ ៦ ទំព័រ ៦៦ គ្រានោះព្រះមានព្រះភាគទ្រង់ត្រាស់ហៅភិក្ខុទាំងឡាយមកហើយ ទើបត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតរួចហើយអំពីអន្ទាក់ទាំងអស់ ទោះបីជារបស់ទេវតាក្ដី ទោះបីជារបស់មនុស្សក្ដី ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយសោតក៏បានរួចហើយអំពីអន្ទាក់ទាំងអស់ដែរ ទោះបីជារបស់ទេវតាក្ដី ទោះបីជារបស់មនុស្សក្ដី ។ ម្នាលភិក្ខុទាំង

ឡាយអ្នកទាំងឡាយចូរត្រេចទៅកាន់ចារិក គឺស្រុក និងនិគម រាជធានី ហើយសម្តែងធម៌ ដើម្បីជាប្រយោជន៍ និង សេចក្តីសុខដល់ជនជាច្រើន ដើម្បីអនុគ្រោះដល់សត្វលោក ដើម្បីជាប្រយោជន៍ ដើម្បីជាគុណ ដើម្បីសេចក្តីសុខដល់ទេវតានិងមនុស្សទាំងឡាយ អ្នកទាំងឡាយកុំទៅពីរអង្គ តាមផ្លូវមួយជាមួយគ្នាឡើយ ។ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយចូរសម្តែងធម៌ឱ្យពិរោះបទដើម បទកណ្តាល និងបទចុង អ្នកទាំងឡាយចូរប្រកាសនូវព្រហ្មចរិយធម៌ដ៏បរិសុទ្ធប្រកបដោយអត្ថ និង ព្យញ្ជនៈដ៏ពេញបរិបូណ៌ទាំងអស់សត្វទាំងឡាយដែលមានធូលីគឺរាគាទិក្កិលេសតិចក្នុងភ្នែក ក៏មានដែរ សត្វទាំងនោះនឹងសាបសូន្យចាកមគ្គផលព្រោះមិនបានស្តាប់ធម៌ សត្វទាំងឡាយ អ្នកបំរុងត្រាស់ដឹងធម៌គង់នឹងមាន ។ ម្នាលភិក្ខុទាំងឡាយ ចំណែកតថាគត នឹងចូលទៅកាន់សេនានិគមក្នុងឧរុវេលាប្រទេសសម្តែងធម៌ដែរ ។

**៧-មគ្គក្នុងបវនៈ ជាព្រហ្មចរិយធម៌ ដើម្បីអកុប្បាចេតោវិមុត្តិ**

ក្នុងបិដកលេខ ២១ ទំព័រ ២៣៥ ព្រះដ៏មានព្រះភាគទ្រង់ត្រាស់សម្តែងខាងចុងនៃមហាសារោបមសូត្រថា ម្នាលភិក្ខុទាំងឡាយ

ព្រហ្មចរិយធម៌នេះ មិនមែនមានលាភសក្ការៈនិងសេចក្តីសរសើរជាអានិសង្ស មិនមែនមានសីលសម្បទាជាអានិសង្ស មិនមែនមានសមាធិសម្បទាជាអានិសង្ស មិនមែនមានញាណទស្សនទិព្វ-ចក្ខុជាអានិសង្សតែប៉ុណ្ណោះទេ។ ម្នាលភិក្ខុទាំងឡាយ ចេតោ-វិមុត្តិ គឺការរួចចាកកិលេសនៃចិត្ត បានដល់អរហត្តផលដែលជាធម្មជាតមិនកម្រើកណា ម្នាលភិក្ខុទាំងឡាយ ព្រហ្មចរិយធម៌នេះមានអរហត្តផលនោះជាប្រយោជន៍ មានអរហត្តផលនោះជាខ្លឹម មានអរហត្តផលនោះជាទីបំផុត។

**៨-មគ្គក្នុងឋានៈជាព្រហ្មយាននាំទៅរកជោគជ័យតែម្យ៉ាងប៉ុណ្ណោះ**

ក្នុងបិដកលេខ ៣៧ ទំព័រ ១៣ ព្រះអង្គទ្រង់ត្រាស់ថា ព្រហ្មយាននេះ រកគុណជាតដទៃក្រៃលែងជាងគ្មាន កើតព្រមក្នុងខ្លួននៃបុគ្គលណា បុគ្គលនោះជាអ្នកប្រាជ្ញ រមែងចេញចាកលោកបានដោយពិតប្រាកដ មានតែជ័យជម្នះម្យ៉ាងប៉ុណ្ណោះ។

**៩-មគ្គក្នុងឋានៈជាត្រៃសិក្ខា** ក្នុងបិដកលេខ ២២ ទំព័រ ២៩៣ ព្រះនាងធម្មទិន្នាភិក្ខុនីបាន ឆ្លើយតបបញ្ហាថា ម្នាលអាវុសោវិសាខៈ ខន្ធទាំង៣ប្រការ លោកមិនបានសង្គ្រោះចូលក្នុង អដ្ឋង្គិក

មគ្គដ៏ប្រសើរទេ ម្នាលអាវុសោវិសាខៈ ប៉ុន្តែអដ្ឋង្គិកមគ្គដ៏ប្រសើរ លោកសង្គ្រោះចូលក្នុងខន្ធទាំង៣ប្រការវិញ ។ ម្នាលអាវុសោវិសាខៈ សម្មាវាចា១សម្មាកម្មន្តៈ១សម្មាអាជីវៈ១ ធម៌ទាំង៣នេះ លោកសង្គ្រោះចូលក្នុងសីលក្ខន្ធ។ សម្មាវាយាមៈ១ សម្មាសតិ ១ សម្មាសមាធិ១ ធម៌ទាំង៣នេះលោកសង្គ្រោះចូលក្នុងសមាធិក្ខន្ធ។ សម្មាទិដ្ឋិ១សម្មាសង្កប្បៈ១ ធម៌ទាំង២ នេះលោកសង្គ្រោះចូលក្នុងបញ្ញាខន្ធ។

*សេចក្ដីបញ្ជាក់:ក្នុងឆ្នាំសិក្សានេះសិក្សានៅវត្តឧណ្ណាលោម បាន៦២ថ្ងៃ ថ្ងៃសិក្សាចុង ក្រោយគឺថ្ងៃអាទិត្យ ១១កើត ខែទុតិយាសាឍ ឆ្នាំរោង ចត្វាស័កព.ស.២៥៥៦ជាឆ្នាំសិក្សាទី១៥ ម្យ៉ាងទៀតការដែលលោកគ្រូហៅមេរៀនឲ្យសរសេរបានប៉ុណ្ណេះ ។*

**ចក្កវត្តិសូត្រ បិដកលេខ ១៨ ទំព័រ ១១៥_១១៦**

(៣៣) _ខ្ញុំបានស្ដាប់មកយ៉ាងនេះ ។ សម័យមួយព្រះមានព្រះភាគទ្រង់គង់នៅក្នុងដងព្រៃជិតមាតុលានគរ ក្នុងដែនមគធៈ។ ព្រះមានព្រះភាគទ្រង់ត្រាស់នឹងភិក្ខុទាំងឡាយ ក្នុងទីនោះថា

ម្នាលភិក្ខុទាំងឡាយ ។ ភិក្ខុទាំងនោះ ទទួលព្រះពុទ្ធដីកា ព្រះមានព្រះភាគថា ព្រះករុណាព្រះអង្គ ។ ព្រះមានព្រះភាគទ្រង់ត្រាស់ដូច្នេះថា: **អត្តទីបា ភិក្ខវេ វិហរថ អត្តសរណា អនញ្ញសរណា ធម្មទីបា ធម្មសរណា អនញ្ញសរណា** ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយចូរមានខ្លួនជាទីពឹង មានខ្លួនជាទីពំនាក់ កុំមានអ្នកដទៃ ជាទីពឹងពំនាក់ឡើយ ចូរមានធម៌ជាទីពឹង មានធម៌ជាទីពំនាក់ កុំមានរបស់ដទៃជាទីពឹងពំនាក់ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុមានខ្លួនជាទីពឹង មានខ្លួនជាទីពំនាក់ មិនមានរបស់ដទៃជាទីពឹងពំនាក់ មានធម៌-ជាទីពឹង មានធម៌ជាទីពំនាក់ មិនមានរបស់ដទៃជាទីពឹងពំនាក់ តើដូចម្តេច។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះពិចារណានូវកាយក្នុងកាយ ជាប្រក្រតី មានព្យាយាមជាគ្រឿងដុតកំដៅនូវកិលេស មានប្រាជ្ញាដឹងសព្វ មានស្មារតីកំចាត់បង់នូវអភិជ្ឈា និង ទោមនស្សក្នុងលោកបាន ។ ពិចារណានូវវេទនា ក្នុងវេទនា ទាំងឡាយជាប្រក្រតី។ ពិចារណានូវចិត្តក្នុងចិត្តជាប្រក្រតី។ ពិចារណានូវធម៌ក្នុងធម៌ទាំងឡាយ

ជាប្រក្រតី មានព្យាយាម ជាគ្រឿងដុតកំដៅនូវកិលេសមាន ប្រាជ្ញាដឹងសព្វ មានស្មារតី កំចាត់បង់នូវអភិជ្ឈានិង ទោមនស្ស ក្នុងលោកបាន។ **ឯវំ ខោ ភិក្ខវេ ភិក្ខុ អត្តទីបោ វិហរតិ អត្តសរណោ អនញ្ញសរណោ ធម្មទីបោ ធម្មសរណោ អនញ្ញសរណោ** ម្នាលភិក្ខុទាំងឡាយយ៉ាងនេះហៅថា ភិក្ខុមាន ខ្លួនជាទីពឹង មានខ្លួនជាទីពំនាក់ មិនមានរបស់ដទៃ ជាទីពឹង ពំនាក់ មានធម៌ជាទីពឹង មានធម៌ជាទីពំនាក់ មិនមានរបស់ដទៃ ជាទីពឹងជាទីពំនាក់។

**គោចរេ ភិក្ខវេ ចរថ សកេ បេត្តិកេ វិសយេ** ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយ ចូរប្រព្រឹត្តក្នុងគោចរជា វិស័យ ដែលមានមកអំពីបិតារបស់ខ្លួន។ ម្នាលភិក្ខុទាំងឡាយ បើអ្នកទាំងឡាយប្រព្រឹត្ត ក្នុងគោចរជាវិស័យ ដែលមានមកអំពី បិតារបស់ខ្លួន មារ ក៏មិនបាននូវចន្លោះ មិនបាននូវអារម្មណ៍ ឡើយ ។ **កុសលានំ ភិក្ខវេ ធម្មានំ សមាទានហេតុ ឯវមិទំ បុញ្ញំ បវឌ្ឍតិ** ម្នាលភិក្ខុទាំងឡាយ បុណ្យនេះរមែង ចម្រើនឡើងព្រោះហេតុសមាទាននូវកុសលទាំងឡាយយ៉ាងនេះ។

# ព្រះអដ្ឋកថាចក្កវត្តិសូត្រ

ក្នុងចក្កវត្តិសូត្រនេះ មានពាក្យផ្តើមថា ខ្ញុំបានស្តាប់មកយ៉ាងនេះក្នុងព្រះសូត្រនោះ មានការពណ៌នាបទដែលលំបាក ដូចតទៅៈ បទថា **មាតុលាយំ** បានដល់ក្នុងព្រះនគរដែលមានឈ្មោះ យ៉ាងនោះ។ ព្រះមានព្រះភាគទ្រង់ធ្វើព្រះនគរនោះឱ្យជាគោចរគ្រាមប្រថាប់នៅក្នុងព្រៃស្រោងមិនឆ្ងាយ។ ក្នុង បទថា **តត្រ ខោ ភគវា ភិក្ខូ អាមន្តេសិ** នេះមានអនុបុព្វិកថាដូចតទៅៈ

បានឮថា ក្នុងសម័យដែលព្រះសូត្រនេះកើតឡើង ព្រះមានព្រះភាគចេញចាក មហាករុណាសមាបត្តិក្នុងពេលទៀបភ្លឺ ទ្រង់ប្រមើលមើលសត្វលោក ទ្រង់ឃើញការត្រាស់ដឹងធម៌របស់សត្វ ៨៤០០០ អ្នកនៅក្នុងមាតុលនគរ ដោយការសម្តែងព្រះសូត្រដែលសម្តែងដល់អនាគតវង្សនេះ។ ព្រះមានព្រះភាគ ព្រមដោយភិក្ខុ ២០០០០ រូប ស្តេចយាងទៅកាន់មាតុលនគរ ពីព្រឹកព្រលឹម។ ស្តេចមាតុលនគរ បានឮដំណឹងថា ព្រះមានព្រះភាគទ្រង់យាង

មក ទើបទូលអារាធនា ព្រះទសពលឱ្យស្តេចចូលកាន់ព្រះនគរ ដោយគ្រឿងសក្ការៈដ៏ច្រើន ទ្រង់រៀបចំទីកន្លែងប្រថាប់គង់ អារាធនាឱ្យព្រះមានព្រះភាគប្រថាប់គង់លើបល្ល័ង្កដ៏មានតម្លៃ ។ បានថ្វាយមហាទានចំពោះភិក្ខុសង្ឃ ដែលមានព្រះពុទ្ធជាប្រធាន ព្រះមានព្រះភាគទ្រង់ធ្វើភត្ត កិច្ចស្រេចហើយ ទ្រង់ ត្រិះរិះថា បើតថាគតនឹងសម្តែងធម៌ដល់ ពួកមនុស្សទាំងនេះក្នុងទីនេះ សោតជាទីចង្អៀត ពួកមនុស្សមិនមានឱកាសនឹងឈរ នឹងអង្គុយ តែសមាគមធំគប្បីមាន។

លំដាប់នោះ ព្រះមានព្រះភាគទ្រង់មិនធ្វើនូវភត្តានុមោទនា ដល់ពួករាជត្រកូលឡើយ ព្រះអង្គទ្រង់កាន់បាត្រ ស្តេចចេញចាក ព្រះនគរទៅ ។ ពួកមនុស្សគិតថា ព្រះសាស្តាទ្រង់មិនធ្វើ អនុ-មោទនាដល់ពួកយើង ស្តេចចេញទៅ អាហារមានរសដ៏ប្រសើរ គង់មិនសព្វព្រះទ័យឈ្មោះថាព្រះពុទ្ធ ទាំងឡាយនរណាៗមិនអាច ផ្គាប់ព្រះទ័យត្រូវបាន ធម្មតាថាការធ្វើសេចក្តីស្និទ្ធស្នាលនឹង ព្រះពុទ្ធទាំងឡាយ ក៏ដូចជាការចាប់កអាសិរពិស ដែលកំពុងបើក ពពារ មកចុះលោកដ៏ចម្រើនទាំងឡាយ ពួកយើងនឹងសូមខមា

ទោសចំពោះព្រះតថាគត ។ ពួកអ្នកនគរទាំង អស់ម្នាក់ៗ នាំគ្នាចេញទៅ តាមព្រះមានព្រះភាគ ។ ព្រះមានព្រះភាគខណៈ ស្តេចយាងចេញទៅនោះឯង ទ្រង់ទតឃើញដើមមាតុលៈដើមស្វាក់មួយដើមដុះនៅក្នុងស្រែ របស់អ្នកនគរមគធៈបរិបូណ៌ដោយម្លប់ត្រឈឹងត្រឈៃ តាំងនៅក្នុងភូមិភាគប្រមាណមួយករីសៈ ទ្រង់ត្រិះរិះថាតថាគត នឹងអង្គុយ ត្រង់គល់ឈើនេះកាលតថាគតសម្តែងធម៌ មហាជននឹងមានឱកាសឈរ និងអង្គុយបានព្រះអង្គទើបស្តេចចៀសចេញពីផ្លូវ ចូលរកគល់ឈើ ទតឡៀងព្រះនេត្រមើល ព្រះអានន្ទដែលជាធម្មភណ្ឌាគារិក ឃ្លាំងព្រះធម៌ ព្រះថេរៈជ្រាបថា ព្រះសាស្តា បំណងនឹងប្រថាប់គង់ ដោយន័យដែល ព្រះអង្គទ្រង់ឡៀងព្រះនេត្រប៉ុណ្ណោះទើបក្រាលចីវរថ្វាយព្រះសុគត ។ ព្រះមានព្រះភាគ ប្រថាប់លើអាសនៈ ដែលព្រះអានន្ទ ក្រាលថ្វាយ ។ លំដាប់នោះពួក មនុស្សនាំគ្នាអង្គុយ ខាងមុខព្រះភក្ត្រព្រះតថាគត។ ពួកភិក្ខុអង្គុយសងខាង និងផ្នែកខាងក្រោយពួកទេវតាឈរក្នុងអាកាស ។ ព្រះមាន ព្រះភាគ ប្រថាប់ត្រង់កណ្តាលបរិស័ទធំនោះឯង ដោយអាការៈយ៉ាងនេះ ទើបបាន

ត្រាស់ហៅភិក្ខុទាំងឡាយ ។ បទថា **តេ ភិក្ខូ** សេចក្តី ថាភិក្ខុជាធម្មបដិគ្គាហក អ្នកទទួលធម៌ចូលទៅក្នុងសមាគមនោះ។ បទថា **អត្តទីបា** សេចក្តីថា ពួកអ្នកចូរធ្វើ ខ្លួនឱ្យជា កោះ ជាទីពំនាក់ ជាទីពួន ជាគតិ ជាទីទៅខាងមុខ ជាទីពឹងចុះ។

ពាក្យថា **អត្តសរណា** នេះជាវេវចនៈរបស់ពាក្យថា **អត្តទីបា** នុ៎ះឯង។

ពាក្យថា **អនញ្ញសរណា** ជាពាក្យបដិសេធទីពឹងយ៉ាងដទៃ។ សេចក្តីពិតបុគ្គលដទៃនឹងជាទីពឹងដល់បុគ្គលដទៃមិនបាន ព្រោះបុគ្គល ដទៃនឹងបរិសុទ្ធដោយសេចក្តី ព្យាយាមរបស់បុគ្គលដទៃមិនបាន។

សមដូចព្រះមានព្រះភាគត្រាស់ថា ខ្លួនជាទីពឹងរបស់ខ្លួនអ្នកដទៃជាទីពឹងដូចម្តេចបាន ។ ព្រោះហេតុនោះ ព្រះមាន ព្រះភាគទើបត្រាស់ថា **អនញ្ញសរណា**។ សួរថា ក៏ក្នុងពាក្យថា **អត្តទីបា** នេះអ្វីហ្ន៎ឈ្មោះថាខ្លួន។ ឆ្លើយថា លោកិយធម៌ និង លោកុត្តធម៌។ ដោយហេតុនោះ ព្រះមានព្រះភាគ ទើបត្រាស់ថា **ធម្មទីបា**

**ធម្មសរណា អនញ្ញសរណា** មានធម៌ជាកោះ មានធម៌ជាទីពឹង មិនមានវត្ថុដទៃជាទីពឹងដូច្នេះ។

ពាក្យថា **ភាយេ ភាយានុបស្សី** ជាដើមបានពោល ពិស្តារ ហើយក្នុងមហាសតិប្បដ្ឋានសូត្រ ។ បទថា **គោចរេ** បានដល់ស្ថានទីគួរត្រេចទៅ។ បទថា **សកេ** គឺកន្លែងដែលជារបស់មាននៅនៃខ្លួន។បទថា **បេត្តិកេ វិសយេ** គឺក្នុងទីដែលមកពីវិស័យរបស់បិតា។ បទថា **ចរតំ** គឺត្រេចទៅហើយ បាឡីថា **ចរន្តំ** ដូច្នេះក៏មាន។ សេចក្តីក៏ដូច្នោះឯង។ បទថា **ន លច្ឆតិ** សេចក្តីថានឹងមិនបានគឺនឹងមិនឃើញ។

បទថា **មារោ** បានដល់ទេវបុត្តមារខ្លះកិលេសមារខ្លះ។ បទថា **ឱតារំ** បានដល់ស្នាមគឺចន្លោះផ្លូវបើក។ ក៏សេចក្តីនេះបណ្ឌិតគប្បីសម្តែងដោយរឿងសត្វខ្លែង ដែលឆាបយកសត្វប្រចៀចហើរចេញពីដីអាចម៍បំណេះហើរឡើងទៅទំលើសសរខឿន សសរ-បន្ទាយ នៅក្រោមកំដៅថ្ងៃស្រទន់។ សមដូចពាក្យ ដែលព្រះមានព្រះមានព្រះភាគ ទ្រង់ត្រាស់ថា:

ម្នាលភិក្ខុទាំងឡាយ ធ្លាប់មានរឿងពីដើមមកថា មានសត្វខ្លែងបានឆាបសត្វប្រចៀចដោយរហ័ស ។ ម្នាលភិក្ខុទាំងឡាយ គ្រានោះឯង សត្វប្រចៀច កាលសត្វខ្លែងកំពុងនាំទៅ ក៏ស្រែកបម្រះនរៀលយ៉ាងនេះថា ពួកយើងនោះឯងត្រេចទៅក្នុងទីអគោចរ ដែលជាដែនរបស់បរបក្ខ រាប់ថាមិនមានបុណ្យ មានបុណ្យតិច ប្រសិនបើថ្ងៃនេះយើងត្រេចទៅក្នុងទីគោចរ ជាដែនរបស់បិតាសោត សត្វខ្លែងនឹងមិនអាចចាប់យើងបាន ។ សត្វ-ខ្លែងសួរថានែប្រចៀច ចុះទីណាជាទីគោចររបស់អ្នកឯង ដែលជាដែនដីនៃបិតារបស់អ្នកឯង? សត្វប្រចៀចឆ្លើយថា គឺទីមានដីអាចម៍បំណះ ដែលគេទើបនឹងភ្ជួរដោយនង្គ័ល។ ម្នាលភិក្ខុទាំង-ឡាយ គ្រានោះឯង សត្វខ្លែងមិនប្រមាណក្នុងកម្លាំងរបស់ខ្លួន ក៏លែងសត្វប្រចៀចទៅ ដោយពោលថា នែ! ឯងចូរទៅចុះទោះឯងទៅក្នុងទីនោះ ក៏មិនរួចពីអញដែរ ។ គ្រានោះឯង សត្វប្រចៀច ក៏ហើរទៅកាន់ទីដីអាចម៍បំណះ ហើយទំលើដីអាចម៍បំណះ និយាយនឹងសត្វខ្លែងថា នែ! ខ្លែង ឯងចូរមករកយើងក្នុងកាលឥឡូវនេះចុះ នែ!ខ្លែងឯងចូរមករកយើងក្នុងកាលឥឡូវនេះ

ចុះ។ ម្នាលភិក្ខុទាំងឡាយ គ្រានោះសត្វខ្លែងមិនប្រមាណក្នុងកម្លាំងខ្លួន ជឿជាក់ក្នុងកម្លាំងខ្លួនហើយសម្លបស្លាបទាំងពីរបោះពួយតម្រង់សត្វប្រចៀច។ ម្នាលភិក្ខុទាំងឡាយ សត្វប្រចៀចបានដឹងថា សត្វខ្លែងនេះបោះពួយចុះមកហើយ គ្រានោះឯង សត្វ-ប្រចៀចក៏ចូលពួនត្រង់ចន្លោះ ដីអាចម៍បំណះនោះឯង។ ម្នាលភិក្ខុទាំងឡាយ គ្រានោះឯង សត្វខ្លែងក៏ទង្គិចទ្រូងនឹងដី អាចម៍បំណះនោះឯង។ម្នាលភិក្ខុទាំងឡាយ ប្រការនោះ ក៏ដូចគ្នានឹងភិក្ខុដែលត្រេចទៅ ក្នុងទីដែលមិនមែនជាគោចរ ដែលជាដែនរបស់បរបក្ខ។ ម្នាលភិក្ខុ ទាំងឡាយ ព្រោះហេតុនោះ ពួកអ្នកចូរកុំត្រេចទៅក្នុងទីមិនមែនជាគោចរ ដែលជាដែនរបស់បរបក្ខ ។ កាលបើអ្នក ត្រេចទៅក្នុងទីមិនមែនជាគោចរ ដែលជាដែនរបស់បរបក្ខ មារតែងបាននូវចន្លោះមារតែងបាននូវអារម្មណ៍។

ម្នាលភិក្ខុទាំងឡាយក៏អ្វី គឺ អគោចរ ដែលជាដែនបរបក្ខចំពោះភិក្ខុ គឺ កាមគុណ ៥ ។កាមគុណ ៥ តើដូចម្តេច បានដល់រូប ដែលគប្បីដឹងបានដោយចក្ខុ ដែលគួរប្រាថ្នា គួរស្រឡាញ់គួរពេញចិត្ត ប្រកបដោយសេចក្តីស្រឡាញ់ ជាទីតាំងនៃតម្រេក

។ល។ ផោដ្ឋព្វៈដែលគប្បីដឹងដោយកាយ ។ល។ ដែលជាទីតាំងនៃតម្រេក។ ម្នាលភិក្ខុទាំងឡាយនេះគឺ អគោចរ ដែលជាដែនរបស់បរបក្ខសម្រាប់ភិក្ខុ។ ម្នាលភិក្ខុទាំងឡាយពួកអ្នកទាំងឡាយចូរត្រេចទៅក្នុងទីជាគោចរ។ល។ មាររមែងមិនបាននូវអារម្មណ៍។ ម្នាលភិក្ខុទាំងឡាយ អ្វីគឺជា គោចរៈរបស់ភិក្ខុដែលជាដែននៃបិតារបស់ខ្លួន គឺ សតិប្បដ្ឋាន ទាំង ៤ ។ សតិប្បដ្ឋាន ៤ តើដូចម្ដេច? ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងធម្មវិន័យនេះ ពិចារណាឃើញនូវកាយក្នុងកាយ។ល។ ធម៌ដែលជាដែននៃបិតាខ្លួន។

បទថា **កុសលានំ** គឺ ធម៌ដែលមិនមានទោសជាលក្ខណៈ។ បទថា **សមាទានហេតុ** គឺព្រោះហេតុសមាទានហើយប្រព្រឹត្ត ។ បទថា **ឯវមិទំ បុញ្ញំ បវឌ្ឍតិ** សេចក្ដីថា ផលបុណ្យដែលជាលោកិយៈ និង លោកុត្តរៈនេះ រមែងចម្រើន យ៉ាងនេះ ។ មួយទៀត ពាក្យថា ផលបុណ្យនោះ គប្បីជ្រាបថា បានដល់ទាំងបុណ្យទាំងផលរបស់បុណ្យជាន់ខ្ពស់ៗ។

**មេរៀនវត្តខ្ទណ្ឌាលោម ឆ្នាំទី៩ ព.ស.២៥៤៨-៤៩**

## អាហាររបស់សតិសម្ពោជ្ឈង្គៈមាន ៥

១.ការអប់រំចម្រើននូវសតិសម្បជញ្ញៈ រឿយៗគ្រប់ឥរិយាបថ

២.វៀរចាកបុគ្គលដែលមិនអប់រំសតិ

៣.សេពគប់បុគ្គលដែលអប់រំសតិ

៤.សេពគប់នឹងបុគ្គលមានសតិសម្បជញ្ញៈ

៥.មានចិត្តបង្អោនទៅរកសតិសម្បជញ្ញៈ

## អាហាររបស់ធម្មវិចយសម្ពោជ្ឈង្គៈមាន ៧

១.មានការសាកសួរធម៌មានកុសលធម៌ អកុសលធម៌ជាដើម

២.ធ្វើវត្ថុទាំងខាងក្នុងទាំងខាងក្រៅឱ្យស្អាតបរិសុទ្ធ

៣.ធ្វើឥន្ទ្រីយ៍ឱ្យស្មើគ្នា មានសទ្ធិន្ទ្រីយ៍ជាដើម

៤.វៀរចាកនូវបុគ្គលដែលមិនចម្រើនបញ្ញា

៥.សេពគប់បុគ្គលដែលចម្រើនបញ្ញា

៦.ពិចារណានូវសេចក្តីនូវអត្ថដ៏ជ្រាលជ្រៅនៃខន្ធធាតុអាយតនៈ

៧.មានចិត្តបង្អោនទៅរកធម្មវិចយសម្ពោជ្ឈង្គៈ

## អាហាររបស់វីរិយសម្ពោជ្ឈង្គៈមាន ១១

១.ពិចារណាអបាយភូមិ ៤ ដែលមិនមានឱកាសប្រារព្ធនូវសេចក្តីព្យាយាម ។

២.ពិចារណាឃើញអានិសង្សនៃសេចក្តីព្យាយាម

៣.ពិចារណានូវផ្លូវដែលព្រះសម្មាសម្ពុទ្ធ អគ្គសាវ័កលោកទ្រង់យាងទៅ យើងរីករាយទៅតាម។

៤.ពិចារណាពីបិណ្ឌបាត មានសេចក្តីសង្វេគ ថាអាត្មាអញជាអ្នកបួស ត្រូវតែប្រឹងប្រែងក្នុងព្រហ្មចរិយធម៌ មិនប្រមាទ ។

៥.ពិចារណាក្នុងមត៌កដោយសេចក្តីគោរពក្នុងមត៌កនោះថាអាត្មាអញត្រូវតែមានសេចក្តីព្យាយាម ទើបបានទទួលមត៌កពីព្រះបិតាគឺព្រះធម៌ ព្រះពុទ្ធវចនៈដើម្បីបដិបត្តិតាម ។

៦.ពិចារណាដល់ព្រះសាស្តាសម្មាសម្ពុទ្ធ ជាបុគ្គលអស្ចារ្យមិនមានអ្នកណា ប្រៀបប្រដូចបាន ។

៧.ពិចារណាដល់ជាតិដែលខ្លួនឯងនៅក្នុងវង្សរបស់ព្រះសម្មាសម្ពុទ្ធ។

៨.ពិចារណាឃើញភាពឧត្តមរបស់សព្រហ្មចារី

៩.វៀរចាកបុគ្គលដែលខ្ជិលច្រអូស

១០_សេពគប់នូវបុគ្គលដែលមានសេចក្តីព្យាយាម

១១_មានចិត្តបង្អោនទៅរកសេចក្តីព្យាយាម។

## អាហាររបស់បីតិសម្ពោជ្ឈង្គៈមាន ១១

១_ពុទ្ធានុស្សតិ ២_ធម្មានុស្សតិ ៣_សង្ឃានុស្សតិ

៤_សីលានុស្សតិ ៥_ចាគានុស្សតិ

៦_ទេវានុស្សតិ ៧_ឧបសមានុស្សតិ

៨_វៀរចាកបុគ្គលដែលសៅហ្មង មិនមានសទ្ធា

៩_គប់រកនូវបុគ្គលដែលទន់ភ្លន់រៀបរយមានជំនឿក្នុងហេតុ ផល

១០_ពិចារណានូវព្រះសូត្រដែលជាហេតុនាំឱ្យមានសេចក្តី ជ្រះថ្លា ។

១១_មានចិត្តបង្អោនទៅរកបីតិសម្ពោជ្ឈង្គៈ។

## អាហាររបស់បស្សទ្ធិសម្ពោជ្ឈង្គៈមាន៧

១_បរិភោគនូវអាហារដែលប្រណីតៗជាអាហារប្រាសចាក ទោស

២_អាស្រ័យនៅក្នុងឧតុជាសុខ

៣_មានឥរិយាបថប្រព្រឹត្តទៅជាសុខ

៤_មានសេចក្តីព្យាយាមជាកណ្តាលពិចារណាឃើញសត្វលោកប្រព្រឹត្តទៅតាមកម្ម។

៥.វៀរចាកអំពីបុគ្គលដែលមិនមានសេចក្តីស្ងប់

៦.គប់រកបុគ្គលដែលមានសេចក្តីស្ងប់

៧.បង្អោនចិត្តទៅដើម្បីសេចក្តីស្ងប់នោះ។

## អាហាររបស់សមាធិសម្ពោជ្ឈង្គៈមាន ១១

១.ធ្វើវត្ថុទាំងខាងក្នុងទាំងខាងក្រៅឱ្យស្អាត

២.ធ្វើឥន្ទ្រីយ៍ឱ្យស្មើ មានសទ្ធិន្ទ្រិយ និង បញ្ញិន្ទ្រិយជាដើម

៣.ឆ្លាតក្នុងនិមិត្ត មានកសិណនិមិត្តជាដើម ក្នុងការរក្សានូវនិមិត្តមានសប្បាយ ៧យ៉ាង:

ក.អាវាសសប្បាយ មានអាវាសជាទីសប្បាយ

ខ.គោចរគាមសប្បាយ មានគោចរជាទីសប្បាយ

គ.កថាសប្បាយ សប្បាយក្នុងពាក្យពោល

ឃ.បុគ្គលសប្បាយសប្បាយក្នុងបុគ្គលមានសីល

ង.អាហារសប្បាយ សប្បាយក្នុងអាហារ

ច.ឧតុសប្បាយ សប្បាយក្នុងឧតុ

ឆ.ឥរិយាបថសប្បាយ សប្បាយក្នុងឥរិយាបថ

៤.គ្រប់គ្រងចិត្តក្នុងសម័យដែលចិត្តរវើរវាយ ដោយបស្សិទ្ធិ-សម្ពោជ្ឈង្គៈ សមាធិ និង ឧបេក្ខា ។

៥.ផ្គត់ផ្គង់គាំទ្រចម្រើនចិត្តក្នុងសម័យដែលចិត្តរួញរា ដោយ-ធម្មវិចយ វិរិយៈ បីតិសម្ពោជ្ឈង្គៈ ហៅថា សម្ពោជ្ឈង្គកុសល ។

៦.ញុំាងចិត្តឱ្យរីករាយ ក្នុងសម័យនៃសេចក្ដីព្យាយាមខាងផ្លូវបញ្ញាទន់ខ្សោយ ដោយញុំាងសង្វេគធម៌ឱ្យកើតឡើងក្នុងសង្វេគវត្ថុ៨យ៉ាង រួចហើយញុំាងចិត្តឱ្យជ្រះថ្លារីករាយក្នុងគុណព្រះរតន-ត្រ័យ ។

៧.ព្រងើយក្នុងសម័យដែលចិត្តមិនរវើរវាយ មិនខ្ជិល មិនរួញរា មានការរីករាយស្រស់បស់ហើយនោះ គ្រាន់តែសម្លឹងមើលដោយព្រងើយៗ។

៨.វៀរចាកបុគ្គលដែលមានចិត្តរវើរវាយ

៩.សេពគប់បុគ្គលដែលមានសមាធិចិត្ត

១០.ពិចារណានូវឈាន វិមោក្ខ

១១.បង្អោនចិត្តទៅដើម្បីសមាធិសម្ពោជ្ឈង្គៈ។

## អាហាររបស់ឧបេក្ខាសម្ពោជ្ឈង្គៈមាន ៥

១.ព្រងើយកន្តើយក្នុងសត្វ មានចំណុចពីរយ៉ាងគឺ:

ក.ពិចារណាឃើញសត្វលោកប្រព្រឹត្តទៅតាមកម្ម

ខ.ពិចារណាដោយបរមត្ថ មិនមានសត្វ មិនមានបុគ្គល

២.ពិចារណាព្រងើយកន្តើយក្នុងសង្ខារ មានចំណុចពីរយ៉ាង:

ក.ពិចារណាឃើញថា មិនមានម្ចាស់

ខ.ពិចារណាឃើញថាគ្រាន់តែជារបស់មួយកាល មួយគ្រា

៣.ជៀសវាងពីបុគ្គលដែលជាប់ជំពាក់ក្នុងសត្វ និង សង្ខារ

៤.សេពគប់ចំពោះបុគ្គលដែលព្រងើយកន្តើយក្នុងសត្វ សង្ខារ

៥.បង្អោនចិត្តទៅរកឧបេក្ខាសម្ពោជ្ឈង្គ:

**ចប់អាហារនៃសម្ពោជ្ឈង្គៈទាំង៧ដោយបរិបូណ៌**

បិដកលេខ៤៦ អង្គុត្តរនិកាយ ឆក្កនិបាត ទំព័រ៦

៣.ម្នាលភិក្ខុទាំងឡាយ ភិក្ខុប្រកបដោយធម៌ ៦ យ៉ាង ជាអ្នកគួរទទួលនូវចតុប្បច្ច័យដែលគេនាំមកបូជា។ល។ជាបុញ្ញក្ខេត្តដ៏ប្រសើររបស់សត្វលោក។ ប្រកបដោយធម៌ ៦ យ៉ាងតើដូចម្តេចខ្លះ? គឺ ភិក្ខុប្រកបដោយសទ្ធិន្ទ្រិយ ១ វិរិយិន្ទ្រិយ ១ សតិន្ទ្រិយ ១

សមាធិន្ទ្រិយ១ បញ្ញិន្ទ្រិយ ១ បានធ្វើឱ្យជាក់ច្បាស់ សម្រេចនូវចេ-តោវិមុត្តិ និង បញ្ញាវិមុត្តិដែលមិនមានអាសវៈ ព្រោះអស់អាសវៈទាំងឡាយ ដោយប្រាជ្ញាដ៏ឧត្តមដោយខ្លួនឯងក្នុងបច្ចុប្បន្ន១ ។

ទំព័រលេខ៧: ភិក្ខុប្រកបដោយ សទ្ធាពលៈ១ វីរិយពលៈ១ សតិពលៈ១ សមាធិពលៈ១ បញ្ញាពលៈ១បានធ្វើឱ្យជាក់ច្បាស់ សម្រេចនូវចេតោវិមុត្តិ និង បញ្ញាវិមុត្តិដែលមិនមានអាសវៈ ព្រោះអស់អាសវៈទាំងឡាយ ដោយប្រាជ្ញាដ៏ឧត្តមដោយខ្លួនឯងក្នុងបច្ចុប្បន្ន១ ។

ទំព័រលេខ១០: ម្នាលភិក្ខុទាំងឡាយ អនុត្តរិយៈ ធម្មជាតិដ៏ប្រសើរនេះមាន៦ យ៉ាង ។ អនុត្តរិយៈ ៦យ៉ាង តើដូចម្ដេចខ្លះ? គឺ ទស្សនានុត្តរិយៈ១ សវនានុត្តរិយៈ១ លាភានុត្តរិយៈ១ សិក្ខា-នុត្តរិយៈ១ បារិចរិយានុត្តរិយៈ១ អនុស្សតានុត្តរិយៈ១។

ទំព័រលេខ១១ដល់លេខ១៩: ម្នាលភិក្ខុទាំងឡាយ អនុស្ស -តិដ្ឋាន ហេតុជាទីតាំងនៃសេចក្ដីរឭកនេះមាន ៦ យ៉ាង ។ អនុស្សតិដ្ឋាន ៦ យ៉ាង តើដូចម្ដេចខ្លះ ? គឺ ពុទ្ធានុស្សតិ១

ធម្មានុស្សតិ១ សង្ឃានុស្សតិ១ សីលានុស្សតិ១ ចាគានុស្សតិ១ ទេវតានុស្សតិ១។

សម័យមួយ ព្រះដ៏មានព្រះភាគ ទ្រង់គង់នៅក្នុងនិគ្រោធារាម ទៀបក្រុងកបិលវត្ថុ ក្នុងសក្កជនបទ ។ គ្រានោះ មហានាមសក្កៈ ចូលទៅគាល់ព្រះដ៏មានព្រះភាគ លុះចូលទៅដល់ហើយក្រាប-ថ្វាយបង្គំព្រះដ៏មានព្រះភាគ ហើយប្រថាប់ក្នុងទីដ៏សមគួរ ។ លុះមហានាមសក្កៈ ប្រថាប់ក្នុងទីដ៏សមគួរ ស៊ប់ហើយ បានក្រាបទូលសួរព្រះដ៏មានព្រះភាគដូច្នេះថា បពិត្រព្រះអង្គដ៏ចម្រើនអរិយសាវកណាបានសម្រេចអរិយផល ដឹងច្បាស់នូវសាសនាគឺត្រៃ-សិក្ខាហើយ តើអរិយសាវកនោះ ច្រើនតែនៅដោយវិហារធម៌ដូចម្តេច។ ថ្វាយព្រះពរមហានាម អរិយសាវកណាបានសំរេចអរិយផល ដឹងច្បាស់នូវសាសនាហើយ អរិយសាវកនោះ ច្រើន-តែនៅដោយ វិហារធម៌យ៉ាងនេះ ។ បពិត្រមហានាម អរិយ-សាវកក្នុងសាសនានេះ រឭករឿយៗ នូវព្រះតថាគតថា ព្រះដ៏មានព្រះភាគអង្គនោះ ព្រះអង្គឆ្ងាយចាករាគាទិក្កិលេស ត្រាស់ដឹងនូវញេយ្យធម៌ដោយ ប្រពៃចំពោះព្រះអង្គឯង ព្រះអង្គបរិបូណ៌

ដោយវិជ្ជា និង ចរណៈព្រះអង្គមានដំណើរល្អ ព្រះអង្គជ្រាបច្បាស់នូវត្រៃលោក ព្រះអង្គជាបុគ្គលប្រសើរដោយសីលាទិគុណ ព្រះអង្គជា អ្នកទូន្មាននូវបុរស ព្រះអង្គជាគ្រូនៃទេវតា និងមនុស្ស-ទាំងឡាយ ព្រះអង្គត្រាស់ដឹងនូវចតុរារិយសច្ច ព្រះអង្គលែងវិលមកកាន់ភពថ្មីទៀត ដោយហេតុនេះ ។ បពិត្រមហានាម ក្នុងសម័យណា អរិយសាវករលឹករឿយៗ នូវគុណនៃព្រះតថាគត សម័យនោះ អរិយសាវកនោះ រមែងមិនត្រូវរាគៈរួបរិតចិត្ត មិនត្រូវទោសៈរួបរិតចិត្តមិនត្រូវមោហៈរួបរិតចិត្ត ក្នុងសម័យនោះ ចិត្តរបស់អរិយសាវកនោះ រមែងជាចិត្តត្រង់បានព្រោះប្រារព្ធនូវគុណនៃព្រះតថាគតបពិត្រមហានាម លុះអរិយសាវកមានចិត្តត្រង់ រមែងបាននូវការដឹងនូវអត្ថ បាននូវការដឹងនូវធម៌ បាននូវសេចក្ដីរីករាយប្រកបដោយធម៌ កាលបើមានសេចក្ដីរីករាយ ហើយបីតិក៏កើតឡើង កាលបើចិត្តប្រកប ដោយបីតិហើយនាមកាយក៏ស្ងប់រម្ងាប់ លុះនាមកាយស្ងប់រម្ងាប់ហើយ ក៏រមែងទទួលនូវសេចក្ដី-សុខ លុះប្រកបដោយសេចក្ដីសុខហើយ ចិត្តក៏រមែងតម្កល់មាំ ។ បពិត្រមហានាម អរិយសាវកនេះហៅថា ជាអ្នកដល់នូវការស្ងប់

រម្ងាប់ ក្នុងពួកសត្វដែលប្រាសចាកការស្ងប់រម្ងាប់ជាអ្នកមិនចង្អៀតចង្អល់ក្នុងពួកសត្វ ដែលប្រកបដោយសេចក្ដីចង្អៀតចង្អល់ជាអ្នក សម្រេចនូវ ធម្មស្សោតៈគឺវិបស្សនា ចម្រើនទូវពុទ្ធានុស្សតិកម្មដ្ឋាន ។ បពិត្រមហានាម មួយទៀត អរិយសាវករលឹករឿយៗ នូវគុណព្រះធម៌ថា ព្រះបរិយត្តិធម៌ដែលព្រះដ៏មានព្រះភាគទ្រង់សម្ដែងហើយដោយប្រពៃ ព្រះនព្វលោកុត្តរធម៌ដែលបុគ្គលគប្បីដឹងដោយខ្លួនឯង ជាធម៌ឱ្យផលមិនរង់ចាំកាល ជាធម៌គួរដល់ឯហិបស្សវិធី ជាធម៌គួរបង្អោនចូលមកទុកក្នុងខ្លួន ជាធម៌ដែលវិញ្ញូជន គប្បីដឹងច្បាស់ចំពោះខ្លួន ។ បពិត្រមហានាមក្នុងសម័យណាអរិយសាវករលឹករឿយៗនូវព្រះធម៌ ។ ល ។ កាលបើមានសេចក្ដីសុខ ចិត្តក៏រមែងតម្កល់មាំ។ ជាអ្នកសម្រេចនូវធម្មស្សោតៈគឺវិបស្សនា ចម្រើននូវធម្មានុស្សតិកម្មដ្ឋាន ។ បពិត្រមហានាម មួយទៀត អរិយសាវករលឹករឿយៗនូវគុណ នៃព្រះសង្ឃថា ព្រះសង្ឃសាវកនៃព្រះដ៏មានព្រះភាគ ប្រតិបត្តិល្អហើយ ព្រះសង្ឃសាវកនៃព្រះដ៏មានព្រះភាគ ប្រតិបត្តិត្រង់ហើយ ព្រះសង្ឃសាវកនៃព្រះដ៏មានព្រះភាគ ប្រតិបត្តិដើម្បីត្រាស់ដឹង

ព្រះនិព្វាន ព្រះសង្ឃសាវកនៃព្រះដ៏មានព្រះភាគ ប្រតិបត្តិគួរដល់សាមីចិកម្ម បើរាប់ជាគូនៃបុរសបាន៤គូ បើរាប់រៀងជាបុរសបុគ្គលបាន៨ ព្រះសង្ឃទាំងនោះជាសង្ឃសាវកនៃព្រះដ៏មានព្រះ-ភាគ គួរទទួលនូវចតុប្បច្ច័យដែលគេនាំមកបូជា គួរទទួលនូវវត្ថុដែលគេរៀបចំដើម្បីភ្ញៀវ គួរទទួលនូវទក្ខិណាទានគួរដល់អញ្ជ-លិកម្ម ជាបុញ្ញក្ខេត្តដ៏ប្រសើររបស់សត្វលោក ។ បពិត្រមហា នាមក្នុងសម័យណា អរិយសាវក រលឹករឿយៗ នូវគុណព្រះសង្ឃសម័យនោះ អរិយសាវកនោះ ក៏មិនត្រូវរាគៈរួបរិតចិត្ត មិនត្រូវទោសៈរួបរិតចិត្ត មិនត្រូវមោហៈរួបរិតចិត្តបាន រមែងជាចិត្តត្រង់ព្រោះប្រារព្ធនូវគុណព្រះសង្ឃ ។

បពិត្រមហានាម លុះអរិយសាវកមានចិត្តត្រង់ហើយ រមែងបាននូវការដឹងនូវអត្ថ បាននូវការដឹងនូវធម៌ បាននូវសេចក្តីរីក-រាយប្រកបដោយធម៌ កាលបើមានសេចក្តីរីករាយហើយ បីតិក៏កើតឡើង ។ល។ ជាអ្នកសម្រេចនូវធម្មស្សោតៈ គឺវិបស្សនាចម្រើនសង្ឃានុស្សតិកម្មដ្ឋាន ។ បពិត្រមហានាម មួយទៀតអរិយសាវករលឹក រឿយៗនូវសីលរបស់ខ្លួនដែលមិនដាច់ មិនធ្លុះ

មិនពពាល មិនពព្រុស ជាសីលរួចខ្លួន គឺមិនជាខ្ញុំតណ្ហា ដែលវិញ្ញូជនសរសើរហើយ មិនមានតណ្ហានិងទិដ្ឋិប៉ះពាល់បាន ជាសីលប្រព្រឹត្តទៅដើម្បីសមាធិ ។ បពិត្រមហានាម ក្នុងសម័យណា អរិយសាវករលឹក រឿយៗនូវសីលរបស់ខ្លួន ក្នុងសម័យ នោះ អរិយសាវកនោះ រមែងមិនត្រូវរាគៈរួបរិតចិត្ត មិនត្រូវទោសៈរួបរិតចិត្ត មិនត្រូវមោហៈរួបរិតចិត្តបាន ក្នុងសម័យនោះ ចិត្តរបស់អរិយសាវកនោះ រមែងជាចិត្តត្រង់ ព្រោះប្រារព្ធនូវសីល ។ បពិត្រមហានាម លុះអរិយសាវកមានចិត្តត្រង់ រមែងបាននូវការដឹងនូវអត្ថ បាននូវការដឹងនូវធម៌ បាននូវសេចក្តីរីករាយប្រកបដោយធម៌ កាលបើមានសេចក្តីរីករាយ ហើយបីតិក៏កើតឡើង កាលបើចិត្តប្រកបដោយបីតិហើយ នាមកាយ ក៏ស្ងប់រម្ងាប់ លុះនាមកាយស្ងប់រម្ងាប់ហើយ ក៏រមែងទទួលនូវ សេចក្តីសុខ លុះប្រកបដោយសេចក្តី សុខហើយចិត្តក៏រមែងតម្កល់មាំ ។ បពិត្រមហានាម អរិយសាវកនេះ ហៅថាជាអ្នកដល់នូវការស្ងប់រម្ងាប់ ក្នុងពួកសត្វដែលប្រាសចាកការស្ងប់រម្ងាប់ជាអ្នកមិនចង្អៀត ចង្អល់ក្នុងពួកសត្វដែលប្រកបដោយសេចក្តីចង្អៀត

ចង្អុល ជាអ្នកសម្រេចនូវធម្មស្សោតៈ គឺ វិបស្សនាចម្រើននូវសីលានុស្សតិកម្មដ្ឋាន ។ បពិត្រមហានាមមួយទៀត អរិយសាវករលឹករឿយៗ នូវចាគៈរបស់ខ្លួនថា ឱហ្ន៎អញពេញជាមានលាភហើយ ឱ ហ្ន៎អត្តភាពជាមនុស្ស អញពេញជាបានល្អហើយ ព្រោះកាលពួកសត្វមានសេចក្ដីកំណាញ់ ជាមន្ទិលកំពុងរួបរឹត អញមានចិត្តប្រាសចាកសេចក្ដីកំណាញ់ជាមន្ទិល ជាអ្នកមានការលះរួចផុតហើយ មានដៃលាងស្អាតហើយ ត្រេកអរក្នុងការ-លះបង់ ជាបុគ្គលគួរគេសូម ត្រេកអរក្នុងការចែកចាយទាននៅគ្រប់គ្រងផ្ទះ។

បពិត្រមហានាម ក្នុងសម័យណា អរិយសាវករលឹករឿយៗ នូវចាគៈ ក្នុងសម័យនោះ អរិយសាវកនោះ រមែងមិនត្រូវរាគៈរួបរឹតចិត្ត ។ល។ ក៏រមែងមានចិត្តត្រង់ ព្រោះប្រារព្ធនូវចាគៈ ។ បពិត្រមហានាមលុះអរិយសាវក មានចិត្តត្រង់ហើយរមែងបាននូវការដឹងអត្ថបាននូវការដឹង នូវធម៌បាននូវសេចក្ដីរីករាយប្រកបដោយធម៌ កាលបើមានសេចក្ដីរីករាយហើយ បីតិក៏កើតឡើង កាលបើចិត្តប្រកបដោយបីតិហើយ នាមកាយក៏ស្ងប់រម្ងាប់ លុះ

នាមកាយស្ងប់រម្ងាប់ហើយ ក៏រមែងទទួលនូវសេចក្តីសុខ លុះ-ប្រកបដោយសេចក្តីសុខហើយ ចិត្តក៏រមែងតម្កល់មាំ ។ បពិត្រមហានាម អរិយសាវកនេះ ហៅថាជាអ្នក ដល់នូវការស្ងប់រម្ងាប់ក្នុងពួកសត្វ ដែលប្រាសចាកការស្ងប់រម្ងាប់ ជាអ្នកសម្រេចនូវធម្មសោ្រតៈ គឺវិបស្សនា ចម្រើននូវចាគានុស្សតិកម្មដ្ឋាន ។ បពិត្រមហានាម មួយវិញទៀត អរិយសាវកចម្រើននូវទេវតានុស្សតិថា ទេវតាទាំងឡាយជាន់ចាតុម្មហារាជិកៈក៏មាន ទេវតាទាំងឡាយជាន់តាវត្តឹង្សក៏មាន ទេវតាទាំងឡាយជាន់យាមាក៏មាន ទេវតាទាំងឡាយជាន់តុសិតក៏មាន ទេវតាទាំងឡាយជាន់និម្មានរ-តីក៏មាន ទេវតាទាំងឡាយជាន់បរនិម្មិតវសវត្តិក៏មាន ទេវតាទាំង-ឡាយជាព្រហ្មកាយិកៈក៏មាន ទេវតាទាំងឡាយជាន់លើសជាង-នោះក៏មាន ទេវតាទាំងនោះ ប្រកបដោយសទ្ធា មានសភាពយ៉ាងណា លុះច្យុតចាកលោកនេះហើយទៅកើតទីនោះ សទ្ធារបស់អញ ដែលមានយ៉ាងនោះក៏មាន ទេវតាទាំងនោះប្រកប-ដោយសីល មានសភាពយ៉ាងណា លុះច្យុតចាកលោកនេះហើយទៅកើត ក្នុងទីនោះសីលរបស់អញដែលមានសភាពយ៉ាងនោះ-

ក៏មាន ពួកទេវតាទាំងនោះ ប្រកបដោយសុតៈមានសភាពយ៉ាង-ណាលុះច្យុតចាកលោកនេះហើយ ទៅកើតក្នុងទីនោះ សុតៈរបស់អញ ដែលមានសភាពយ៉ាងនោះមាន ទេវតាទាំងនោះប្រកបដោយចាគៈមានសភាពយ៉ាងណា លុះច្យុតចាកលោកនេះហើយ ទៅកើតក្នុងទីនោះ ចាគៈរបស់អញ ដែលមានសភាពដូច្នោះក៏មាន ទេវតាទាំងនោះប្រកបដោយបញ្ញាមានសភាពយ៉ាងណា លុះច្យុតចាកលោកនេះហើយ ទៅកើតក្នុងទីនោះ បញ្ញារបស់អញដែលមានសភាពដូច្នោះក៏មាន។

បពិត្រមហានាម ក្នុងសម័យណា អរិយសាវករលឹក រឿយៗ នូវសទ្ធា សីល សុតៈ ចាគៈ និងបញ្ញា របស់ខ្លួនផង របស់ទេវ-តាទាំងនោះផង ក្នុងសម័យនោះ អរិយសាវកនោះរមែងមិនត្រូវរាគៈរួបរឹតចិត្ត មិនត្រូវទោសៈរួបរឹតចិត្ត មិនត្រូវមោហៈរួប-រឹតចិត្តបាន ក្នុងសម័យនោះ ចិត្តរបស់អរិយសាវកនោះ រមែងជាចិត្តត្រង់ ព្រោះប្រារព្ធនូវពួកទេវតា។

បពិត្រមហានាម លុះអរិយសាវកមានចិត្តត្រង់ហើយ រមែងបាននូវការដឹងនូវអត្ថ បាននូវការដឹងនូវធម៌ បាននូវសេចក្តី

វិករាយ ដែលប្រកបដោយធម៌ កាលបើមានសេចក្តីរីករាយហើយ បីតិក៏កើតឡើង កាលបើចិត្តប្រកបដោយបីតិហើយ នាមកាយ-ក៏ស្ងប់រម្ងាប់ លុះនាមកាយស្ងប់រម្ងាប់ហើយ ក៏រមែងទទួលនូវសេចក្តីសុខកាលបើមានសេចក្តីសុខហើយ ចិត្តក៏រមែងតម្កល់មាំ។

បពិត្រមហានាម អរិយសាវកនេះ ហៅថាជាអ្នកដល់នូវការស្ងប់រម្ងាប់ ក្នុងពួកសត្វដែលប្រាសចាកការស្ងប់រម្ងាប់ ជាអ្នក-មិនចង្អៀតចង្អល់ ក្នុងពួកសត្វដែលមានសេចក្តីចង្អៀតចង្អល់ ជាអ្នកសម្រេចនូវធម្មសោ្សតៈគឺវិបស្សនា ចម្រើននូវទេវតា-នុស្សតិកម្មដ្ឋាន ។ បពិត្រមហានាម អរិយសាវកណាបានសម្រេច-នូវអរិយផល ដឹងច្បាស់នូវសាសនាហើយ អរិយសាវកនោះច្រើនតែនៅដោយវិហារធម៌នេះ ។

**ឧបមាព្រះរតនត្រ័យ**(*មេរៀនវត្តឧណ្ណាលោម ព.ស.២៥៤៩*)

១-**ព្រះពុទ្ធ** ប្រៀបដូចព្រះច័ន្ទពេញបូរមី

-**ព្រះធម៌** ប្រៀបដូចរស្មីនៃព្រះច័ន្ទ

-**ព្រះសង្ឃ** ប្រៀបដូចលោកដែលស្រស់បស់ដោយរស្មីនៃព្រះច័ន្ទនោះ។

២-ព្រះពុទ្ធ ប្រៀបដូចដួងព្រះអាទិត្យ

-ព្រះធម៌ ប្រៀបដូចរស្មីនៃព្រះអាទិត្យ

-ព្រះសង្ឃប្រៀបដូចលោកដែលដួងព្រះអាទិត្យកម្ចាត់ងងឹតហើយ។

៣-ព្រះពុទ្ធ ប្រៀបដូចជាអ្នកដុតព្រៃគឺកិលេស

-ព្រះធម៌ ប្រៀបដូចភ្លើងដុតព្រៃគឺកិលេស

-ព្រះសង្ឃ ដែលជាបុញ្ញក្ខេត្តព្រោះដុតកិលេសបានហើយ ប្រៀបដូចភូមិភាគដែលជាស្រែព្រោះដុតព្រៃអស់ហើយ ។

៤-ព្រះពុទ្ធ ប្រៀបដូចជាមហាមេឃ

-ព្រះធម៌ ប្រៀបដូចជាទឹកភ្លៀង

-ព្រះសង្ឃ អ្នករំងាប់ល្អងកិលេសប្រៀបដូចជាជនបទដែលរម្ងាប់នូវល្អងធូលីព្រោះភ្លៀងធ្លាក់ ។

៥-ព្រះពុទ្ធ ប្រៀបដូចជាសារថីដ៏ប្រសើរ

-ព្រះធម៌ប្រៀបដូចជាឧបាយសម្រាប់បង្ហឹកសេះអាជានេយ្យ

-ព្រះសង្ឃប្រៀបដូចហ្វូងសេះអាជានេយ្យដែលហ្វឹកហាត់ល្អហើយ ។

៦-ព្រះពុទ្ធប្រៀបដូចជាអ្នកដកព្រួញ (សល្លវេជ្ជ) ព្រោះទ្រង់ដកសរគឺទិដ្ឋិអស់ ។

-**ព្រះធម៌** ប្រៀបដូចឧបាយសម្រាប់ដកព្រួញសរ

-**ព្រះសង្ឃ**អ្នកដកសរគឺកិលេសចេញបានហើយប្រៀបដូចជនដែលត្រូវដកសរចេញបាន។

៧.-**ព្រះពុទ្ធ**ប្រៀបដូចជាពេទ្យព្យាបាលភ្នែក(ចក្ខុវេជ្ជ) ព្រោះទ្រង់ដកនូវស្រទាប់មោហៈចេញបានហើយ ។

-**ព្រះធម៌** ប្រៀបដូចឧបាយជាគ្រឿងបកភ្នែក

-**ព្រះសង្ឃ**មានស្រទាប់ភ្នែកបកហើយ ភ្នែកគឺញាណដ៏ភ្លឺថ្លា ប្រៀបដូចជា ជនដែលបកភ្នែកហើយ មានភ្នែកភ្លឺ។

៨.-**ព្រះពុទ្ធ**ប្រៀបដូចជាពេទ្យដ៏ពូកែ ព្រោះទ្រង់អាចកម្ចាត់នូវព្យាធិគឺកិលេស ព្រមទាំងអនុសយក្កិលេសចេញបាន ។

-**ព្រះធម៌**ប្រៀដូចជាថ្នាំដែលផ្សំត្រឹមត្រូវហើយ

-**ព្រះសង្ឃ** ដែលមានព្យាធិគឺកិលេស និងអនុស័យរម្ងាប់ហើយប្រៀបដូចជាពពួកជនដែលមានព្យាធិរម្ងាប់ហើយព្រោះកបនឹងថ្នាំ។

៩.-**ព្រះពុទ្ធ** ប្រៀបដូចអ្នកចង្អុលផ្លូវ

-**ព្រះធម៌**ប្រៀបដូចជាផ្លូវល្អ គឺផ្លូវដែលសម្រាប់រួចផុតពីភ័យ

-**ព្រះសង្ឃ** ប្រៀបដូចជាអ្នកដើរផ្លូវដល់ទីផុតភ័យ។

១០-**ព្រះពុទ្ធ** ប្រៀបដូចជាអ្នកអុំទូកដ៏ចំណាន

-**ព្រះធម៌** ប្រៀបដូចជាទូក

-**ព្រះសង្ឃ** ប្រៀបដូចជាអ្នកដើរផ្លូវបានដល់ត្រើយ។

១១-**ព្រះពុទ្ធ** ប្រៀបដូចជាព្រៃហេមពាន្ត(ព្រៃដែលមាន ទឹកសន្សើម)

-**ព្រះធម៌** ប្រៀបដូចជាឱសថកើតនៅព្រៃហេមពាន្តនោះ

-**ព្រះសង្ឃ** ប្រៀបដូចជាជនអ្នកមិនមានរោគព្រោះប្រើថ្នាំ។

១២-**ព្រះពុទ្ធ** ប្រៀបដូចជាអ្នកប្រទានទ្រព្យ

-**ព្រះធម៌** ប្រៀបដូចជាទ្រព្យ

-**ព្រះសង្ឃ**ជាអ្នកបានអរិយទ្រព្យមកដោយប្រពៃ ប្រៀបដូចជា ជនអ្នកបានទ្រព្យតាមបំណង ។

១៣-**ព្រះពុទ្ធ** ប្រៀបដូចជាអ្នកចង្អុលកំណប់ទ្រព្យ

-**ព្រះធម៌** ប្រៀបដូចជាកំណប់ទ្រព្យ

-**ព្រះសង្ឃ** ប្រៀបដូចជាជនអ្នកបានកំណប់ទ្រព្យ។

១៤-**ព្រះសម្មាសម្ពុទ្ធ** ជាវីរបុរស ប្រៀបដូចជាអ្នកប្រទានន្ទូវ-

ការមិនមានភ័យ

-**ព្រះធម៌** ប្រៀបដូចជាការមិនមានភ័យ

-**ព្រះសង្ឃ** ដែលរួចពីភ័យគ្រប់យ៉ាង ប្រៀបដូចជាជនអ្នកដល់នូវការមិន មានភ័យ។

១៥-**ព្រះពុទ្ធ** ប្រៀបដូចជាអ្នកលួងលោម

-**ព្រះធម៌** ប្រៀបដូចជាការលួងលោម

-**ព្រះសង្ឃ** ប្រៀបដូចជាជនអ្នកត្រូវលួងលោម។

១៦-**ព្រះពុទ្ធ** ប្រៀបដូចជាមិត្តល្អ

-**ព្រះធម៌**ប្រៀបដូចជាពាក្យដាស់តឿនដែលជាពាក្យមានប្រយោជន៍

-**ព្រះសង្ឃ** ប្រៀបដូចជាជនអ្នកជួបប្រសព្វនូវប្រយោ-ជន៍ព្រោះធ្វើតាមពាក្យរបស់មិត្តល្អ។

១៧-**ព្រះពុទ្ធ** ប្រៀបដូចជាអណ្តូងនាំឱ្យកើតទ្រព្យ

-**ព្រះធម៌** ប្រៀបដូចជាទ្រព្យដែលមានសារៈ

-**ព្រះសង្ឃ**ប្រៀបដូចជាជនអ្នកប្រើទ្រព្យដែលមានសារៈ

១៨-**ព្រះពុទ្ធ**ប្រៀបដូចជាអ្នកស្រោចទឹកងូតឱ្យព្រះរាជកុមារ

-**ព្រះធម៌** ប្រៀបដូចជាទឹកស្រោចស្រពលើព្រះរាជកុមារ តាំងពីព្រះសីសៈ ចុះមក។

-**ព្រះសង្ឃ** ជាអ្នកបានទទួលនូវការស្រោចស្រពទឹកល្អ ហើយ ដោយទឹកគឺ ព្រះសទ្ធម្ម ប្រៀបដូចជាក្រុមព្រះរាជកុមារ ដែលបាន ស្រង់ទឹកល្អហើយ។

១៩-**ព្រះពុទ្ធ** ប្រៀបដូចជាជាងធ្វើគ្រឿងប្រដាប់

-**ព្រះធម៌** ប្រៀបដូចជាគ្រឿងប្រដាប់(អលង្ការ)

-**ព្រះសង្ឃ** ជាអ្នកប្រដាប់ដោយព្រះសទ្ធម្ម ប្រៀបដូច ជាព្រះ រាជឱរសទាំង ឡាយដែលទ្រង់ប្រដាប់ហើយ។

២០-**ព្រះពុទ្ធ** ប្រៀបដូចជាដើមចន្ទន៍

-**ព្រះធម៌** ប្រៀបដូចជាក្លិនដែលកើតពីខ្លឹមចន្ទន៍នោះ

-**ព្រះសង្ឃ**បានរំងាប់សេចក្ដីក្ដៅក្រហាយចិត្តដោយព្រះសទ្ធម្ម ប្រៀបដូច ជាជនអ្នករំងាប់នូវភាពក្ដៅផ្លូវចិត្ត ព្រោះប្រើលំអិត ខ្លឹមចន្ទន៍នោះឯង។

២១-**ព្រះពុទ្ធ** ប្រៀបដូចជាបិតា អ្នកចែកទ្រព្យមតិកប្រកប ដោយធម៌

-**ព្រះធម៌** ប្រៀបដូចជាទ្រព្យមតក

-**ព្រះសង្ឃ** អ្នកទទួលនូវទ្រព្យមរតកគឺព្រះសទ្ធម្មប្រៀបដូចជាបុត្តទាំង ឡាយដែលជាអ្នកទទួលនូវទ្រព្យមរតក។

២២-**ព្រះពុទ្ធ** ប្រៀបដូចជាផ្កាឈូកដែលរីក

-**ព្រះធម៌** ប្រៀបដូចជាលំអងកេសរដែលកើតក្នុងផ្កាឈូកនោះ

-**ព្រះសង្ឃ** ប្រៀបដូចជាពួកភមរជាតិ( មានសត្វឃ្មុំជាដើម) ដែលក្រេបយក លំអងកេសរក្នុងផ្កាឈូក។

គប្បីប្រកាសព្រះរតនត្រ័យនោះ ដោយសេចក្ដីឧបមាទាំងឡាយដូចពោលមក នេះឯង។

*បិដកលេខ ៤៦ ទំព័រ ២១ សារាណីយាទិវគ្គ*

(១១) ម្នាលភិក្ខុទាំងឡាយ សារាណីយធម៌ (ធម៌ដែលគួរ-រលឹក) នេះមាន៦យ៉ាង ។ សារាណីយធម៌៦យ៉ាង តើដូចម្ដេចខ្លះ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ តម្កល់នូវកាយកម្មប្រកបដោយមេត្តាចំពោះសព្រហ្មចារីបុគ្គលទាំងឡាយ ទាំងទី-ចំពោះមុខ ទាំងទីកំបាំងមុខ នេះសារាណីយធម៌។ ម្នាលភិក្ខុទាំង-ឡាយមួយទៀត ភិក្ខុតម្កល់នូវវចីកម្មប្រកបដោយមេត្តាចំពោះ

សព្រហ្មចារីបុគ្គលទាំងឡាយ ទាំងទីចំពោះមុខ ទាំងទីកំបាំងមុខ នេះជាសារាណីយធម៌។ ម្នាលភិក្ខុទាំងឡាយ មួយទៀតភិក្ខុតម្កល់-នូវមនោកម្មប្រកបដោយមេត្តា ចំពោះសព្រហ្មចារីបុគ្គលទាំង-ឡាយទាំងទីចំពោះមុខ ទាំងទីកំបាំង មុខនេះជាសារាណីយធម៌។

ម្នាលភិក្ខុទាំងឡាយ មួយទៀតភិក្ខុអ្នកបរិភោគ មិនញែកមុខដោយលាភទាំងឡាយ ដែលប្រកបដោយធម៌ បានមកដោយធម៌ ដោយហោចទៅសូម្បីតែរបស់ដែលមានក្នុងបាត្រ ជាអ្នកបរិភោគជាសាធារណៈ ដោយសព្រហ្មចារីបុគ្គលទាំងឡាយ ជាអ្នកមានសីល នេះជាសារាណីយធម៌។ ម្នាលភិក្ខុទាំងឡាយ មួយទៀតភិក្ខុជាអ្នកមានសីលស្មើគ្នានឹងសព្រហ្មចារីទាំងឡាយ ក្នុងសីល-ទាំងឡាយ ដែលជាសីលមិនដាច់មិនធ្លុះ មិនពពាល មិនពព្រុសជាសីលរួចខ្លួន គឺមិនជាខ្ញុំតណ្ហា ដែលវិញ្ញូជនសរសើរហើយមិនមានតណ្ហា និងទិដ្ឋិប៉ះពាល់បានជាសីលប្រព្រឹត្តទៅដើម្បីសមាធិទាំងទីចំពោះមុខទាំងទីកំបាំងមុខ នេះជាសារាណីយធម៌។ ម្នាល-ភិក្ខុទាំងឡាយ មួយវិញទៀត ភិក្ខុមានសេចក្តីយល់ឃើញស្មើគ្នានិងសព្រហ្មចារីទាំងឡាយក្នុងទិដ្ឋិដ៏ប្រសើរ ជាទីស្រោចស្រង់សត្វ

ប្រព្រឹត្តទៅដើម្បីអស់ទៅនៃកងទុក្ខដោយប្រពៃដល់អ្នកធ្វើតាមទិដ្ឋិនោះ ទាំងទីចំពោះមុខទាំងទីកំបាំងមុខនេះជាសារាណីយធម៌ ។ ម្នាលភិក្ខុទាំងឡាយ សារាណីយធម៌ ៦ យ៉ាងនេះឯង ។

ទំព័រ៣០៦ : ម្នាលភិក្ខុទាំងឡាយ ភិក្ខុប្រកបដោយធម៌៦ យ៉ាង ជាអ្នកគួរដេម្បីធ្វើឱ្យជាក់ច្បាស់នូវអរហត្តជាធម៌ដ៏ខ្ពង់ខ្ពស់។ ធម៌៦យ៉ាង តើអ្វីខ្លះ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ ជាអ្នកមានសទ្ធា១ មានសេចក្ដីខ្មាសបាប១ មានសេចក្ដីខ្លាចបាប១ ប្រារព្ធព្យាយាម១ មានប្រាជ្ញា១ មិនអាឡោះអាល័យក្នុង-រាងកាយនិងជីវិត១ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុប្រកបដោយ-ធម៌៦យ៉ាងនេះឯង ជាអ្នកគួរដើម្បីធ្វើឱ្យជាក់ច្បាស់នូវអរហត្តជាធម៌ដ៏ខ្ពង់ខ្ពស់ ។

ម្នាលភិក្ខុទាំងឡាយ ភិក្ខុប្រកបដោយធម៌ ៦ យ៉ាង យប់ក្ដី ថ្ងៃក្ដី រមែងមានមក ឯសេចក្ដីសាបសូន្យក្នុងកុសលធម៌ទាំងឡាយ តែងកើតឡើងប្រាកដ សេចក្ដីចំរើនមិនមានឡើយ ។ ធម៌ ៦ យ៉ាង តើអ្វីខ្លះ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ ជាអ្នកមានសេចក្ដីប្រាថ្នាច្រើនមានសេចក្ដីចង្អៀតចង្អល់ មិនសន្តោស ដោយ

ចីវរ បិណ្ឌបាត សេនាសនៈ និងគិលានប្បច្ចយភេសជ្ជបរិក្ខារ តាមមាន តាមបាន១ មិនមានសទ្ធា១ ទ្រុស្តសីល១ ខ្ជិលច្រអូស១ ភ្លេចស្មារតី១ អប្បឥតប្រាជ្ញា១ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុប្រកប ដោយធម៌ ៦ យ៉ាងនេះឯង យប់ក្តី ថ្ងៃក្តី រមែងមានមក ឯសេចក្តី សាបសូន្យក្នុងកុសលធម៌ទាំងឡាយតែងកើតឡើងប្រាកដ សេចក្តី ចម្រើនមិនមានឡើយ ។

*បិដកលេខ ៥៤ ទំព័រ ១១៦ សម្មាបរិព្វាជនិយសូត្រទី១៣*

(ព្រះពុទ្ធនិម្មិតទ្រង់សួរថា)

**បុច្ឆាមិ មុនឹ បហូតបញ្ញំ តិណ្ណំ (បារគតំ) បរិនិព្វុតំ ឋិតត្តំ និក្ខម្ម ឃរា បនុជ្ជ កាមេ កថំ ភិក្ខុ សម្មា សោ លោកេ បរិព្វជេយ្យ ។**

ខ្ញុំសូមសួរនូវព្រះមុនីដែលមានប្រាជ្ញាច្រើន បានឆ្លងចាកឱឃៈ (ដល់នូវត្រើយ គឺព្រះនិព្វាន) បានរំលត់ហើយ មានព្រះទ័យតម្កល់-នៅមាំ ភិក្ខុបន្ទោបង់នូវកាមទាំងឡាយ ហើយចេញចាកផ្ទះ ភិក្ខុនោះឈ្មោះថា វៀរដោយប្រពៃក្នុងលោកតើដោយប្រការដូច ម្តេច ។

( ព្រះមានព្រះភាគទ្រង់ត្រាស់ថា)

**យស្ស មង្គលា សមូហតា (ឥតិ ភគវា) ឧប្បាតា សុបិនា ច លក្ខណា ច ស មង្គលទោសវិប្បហីនោ (ភិក្ខុ) សម្មា សោ លោកេ បរិព្វជេយ្យ ។**

ភិក្ខុណាបានគាស់រំលើង នូវមង្គលផង នូវប្រកាន់ឧត្បាតផង (មានរន្ទះបាញ់ជាដើម) នូវការប្រកាន់យល់សប្តិផង នូវការប្រកាន់លក្ខណៈផង ភិក្ខុនោះ ឈ្មោះថា លះបង់ស្រឡះ នូវមង្គលជាទោស ភិក្ខុនោះឈ្មោះថា វៀរដោយប្រពៃក្នុងលោក។

**រាគំ វិនយេថ មានុសេសុ ទិព្វេសុ កាមេសុ ចាបិ ភិក្ខុ អតិក្កម្ម ភវំ សមេច្ច ធម្មំ សម្មា សោ លោកេ បរិព្វជេយ្យ ។**

ភិក្ខុបន្ទោបង់នូវតម្រេក ក្នុងកាមទាំងឡាយ ជារបស់មនុស្ស ផង ជារបស់ទេវតាផងកន្លងនូវភពបានត្រាស់ដឹងនូវធម៌ ភិក្ខុនោះឈ្មោះថា វៀរដោយប្រពៃ ក្នុងលោក ។

**វិបិដ្ឋិកត្វា បេសុណានិ កោធំ កទរិយំ ជហេយ្យ ភិក្ខុ អនុរោធវិរោធវិប្បហីនោ សម្មាសោលោកេ បរិព្វជេយ្យ។**

ភិក្ខុធ្វើចិត្តមិនឱ្យត្រេកអរ លះនូវពាក្យញុះញង់ទាំងឡាយ នូវ-សេចក្តីក្រោធ និង សេចក្តីកំណាញ់ លះនូវរាគៈនិងទោសៈ ភិក្ខុ-នោះឈ្មោះថាវៀរដោយប្រពៃក្នុងលោក ។

**ហិត្វាន បិយញ្ច អប្បិយញ្ច អនុបាទាយ អនិស្សិតោ កុហិញ្ចិ សំយោជនិយេហិ វិប្បមុត្តោ សម្មា សោ លោកេ បរិព្វជេយ្យ ។**

ភិក្ខុលះបង់នូវសេចក្តីស្រឡាញ់និងស្អប់ មិនប្រកាន់មាំ មិនអាស្រ័យ ក្នុងសភាវៈតិចតួច (ដោយតណ្ហានិងទិដ្ឋិ)ឡើយមាន ចិត្តផុតស្រឡះហើយចាកសំយោជនិយធម៌ទាំងឡាយ (ធម៌ជា-អារម្មណ៍នៃសំយោជនៈ) ភិក្ខុនោះឈ្មោះថា វៀរដោយប្រពៃ-ក្នុងលោក ។

**ន សោ ឧបធីសុ សារមេតិ អាទានេសុ វិនេយ្យ ឆន្ទរាគំ សោ អនិស្សិតោ អនញ្ញនេយ្យោ សម្មា សោ លោកេ បរិព្វជេយ្យ ។**

ភិក្ខុនោះបន្ទោបង់នូវឆន្ទរាគៈ ក្នុងខន្ធជាគ្រឿងប្រកាន់ មិនដល់ នូវការឃើញ ថាមានខ្លឹមក្នុងឧបធិ គឺខន្ធទាំងឡាយនោះ ជាបុគ្គល

មិនអាស្រ័យ (ដោយឆន្ទៈនិងរាគៈ) មិនបាច់មានបុគ្គលដទៃណែនាំឡើយភិក្ខុនោះឈ្មោះថាវៀរដោយប្រពៃក្នុងលោក ។

**វចសា មនសា ច កម្មុនា ច អវិរុទ្ធោ សម្មា វិទិត្វា ធម្មំ និព្វានបទាភិបត្ថយានោ សម្មា សោ លោកេ បរិព្វជេយ្យ ។**

ភិក្ខុមិនភ្លាត់ខុសដោយកាយវាចា និង ចិត្តដឹងច្បាស់នូវធម៌ដោយប្រពៃ ប្រាថ្នាយកនូវបទគឺព្រះនិព្វាន ភិក្ខុនោះឈ្មោះថាវៀរដោយប្រពៃ ក្នុងលោក ។

**យោ វន្ទិ មន្តិ ន ឧណ្ណមេយ្យ អក្កុដ្ឋោបិ ន សន្ធិយេថ ភិក្ខុ លទ្ធា បរភោជនំ ន មជ្ជេ សម្មា សោ លោកេ បរិព្វជេយ្យ ។**

ភិក្ខុណាមិនក្រអឺតក្រឱង ដោយគិតថា គេថ្វាយបង្គំអញ សូម្បីគេជេរក៏មិនតបត បាននូវភោជនដែលអ្នកដទៃឱ្យ ក៏មិនស្រវឹង ភិក្ខុនោះ ឈ្មោះថាវៀរដោយប្រពៃក្នុងលោក ។

**លោភក៏ច្ច ភវញ្ច វិប្បហាយ វិរតោ ឆេទនពន្ធនតោ ភិក្ខុ សោ តិណ្ណកថង្កថោ វិសល្លោសម្ហា សោ លោកេ បរិព្វជេយ្យ ។**

ភិក្ខុលះបង់សេចក្តីលោភនឹងភព វៀរចាកការកាប់កាត់និងការចងសត្វដទៃ ភិក្ខុនោះជាអ្នកឆ្លងចាកសេចក្តីងឿងឆ្ងល់ប្រាសចាកសរគីសេចក្តីសោកភិក្ខុនោះឈ្មោះថាវៀរដោយប្រពៃក្នុងលោក។

**សារុប្បមត្តនោវិទិត្វាន ច ភិក្ខុហឹសេយ្យ កិញ្ចិ លោកេ យថាតថំ ធម្មំ វិទិត្វា សម្មាសោលោកេ រិព្វជេយ្យ។**

ភិក្ខុណាបានដឹងច្បាស់នូវសេចក្តីប្រព្រឹត្តដ៏សមគួរ របស់-ខ្លួនផងមិនបៀតបៀនជនដទៃណាមួយក្នុងលោកផង ដឹងច្បាស់-នូវធម៌តាមសេចក្តីពិត ភិក្ខុនោះ ឈ្មោះថា វៀរដោយប្រពៃក្នុងលោក ។

**យស្សានុសយា ន សន្តិ កេចិ មូលា អកុសលា សមូហតា សេ សោ និរាសសោ អនាសសានោ សម្មា សោ លោកេ បរិព្វជេយ្យ។**

អនុស័យទាំងឡាយណាមួយ មិនមានដល់ភិកក្ខុណាអកុសលមូលទាំងឡាយ ភិក្ខុណាបានដកចោលហើយ ភិក្ខុនោះជាអ្នកមិន-

មានសេចក្ដីប្រាថ្នាមិនមានសេចក្ដីអាឡោះអាល័យភិក្ខុនោះឈ្មោះថាវៀរដោយប្រពៃក្នុងលោក។

**អាសវខីណោ បហីនមានោ សព្វំ រាគបថំ ឧបាតិវត្តោ**
**ទន្តោ បរិនិព្វុតោ ឋិតត្តោ សម្មា សោ លោកេ បរិព្វជេយ្យ។**

ភិក្ខុអ្នកអស់អាសវៈហើយ លះបង់នូវមានះ កន្លងផុតនូវធម៌ជាគន្លងនៃរាគៈទាំងអស់ ទូន្មានខ្លួន សម្រេចនូវព្រះនិព្វាន មាន-ចិត្តតាំងនៅមាំ ភិក្ខុនោះ ឈ្មោះថាវៀរដោយប្រពៃក្នុងលោក ។

**សទ្ធោ សុតវា និយាមទស្សី វគ្គគតេសុ ន វគ្គសារី ធីរោ លោភំ ទោសំ វិនេយ្យ បដិឃំ សម្មា សោ លោកេ បរិព្វជេយ្យ ។**

ភិក្ខុអ្នកមានសទ្ធា ប្រកបដោយសុតៈ ប្រព្រឹត្តទៅក្នុងបរមត្ថ បានឃើញ សម្មត្តនិយាមនិងមគ្គ កាលពួកសត្វប្រព្រឹត្តទៅដោយទិដ្ឋិ ៦២ ក៏មិនប្រព្រឹត្តទៅដោយពួក ជាអ្នកប្រាជ្ញអាចបន្ទោបង់នូវលោភៈ ទោសៈនិងសេចក្ដីថ្នាំងថ្នាក់ភិក្ខុនោះឈ្មោះថា វៀរដោយប្រពៃក្នុងលោក ។

**សំសុទ្ធជិនោ វិវដច្ឆទោ ធម្មេសុ វសី បារគូ អនេជោ**

**សង្ខារនិរោធញ្ញាណកុសលោ សម្មា សោ លោកេ បរិព្វជេយ្យ។**

ភិក្ខុបានឈ្នះកិលេស ដោយអរហត្តមគ្គដ៏បរិសុទ្ធ បើកចេញនូវកិលេសជាគ្រឿងប្រក់ ជាអ្នកស្ទាត់នៅក្នុងចតុស្សច្ចធម៌ ដល់នូវត្រើយគឺព្រះនិព្វាន មានសន្តាន មិនរំភើបដោយតណ្ហាជាអ្នកឈ្លាសវៃក្នុងអរិយមគ្គគ្រឿងដឹងនូវធម៌ជាទីរលត់នៃសង្ខារ ភិក្ខុនោះ ឈ្មោះថា វៀរដោយប្រពៃក្នុងលោក។

**អតីតេសុ អនាគតេសុ ចាបិកប្បាតីតោ អតិច្ចសុទ្ធិបញ្ញោ**
**សព្វយតនេហិ វិប្បមុត្តោ សម្មា សោ លោកេ បរិព្វជេយ្យ។**

ភិក្ខុកន្លងនូវកប្បៈ គឺតណ្ហានិងទិដ្ឋិ ក្នុងខន្ធទាំងឡាយដែលជាអតីតៈនិង អនាគត ជាអ្នកមានប្រាជ្ញាដ៏បរិសុទ្ធ ព្រោះកន្លងផុត (នូវអទ្ធា៣) មានចិត្តផុតស្រឡះ ចាកអាយតនៈទាំងពួងភិក្ខុ នោះ ឈ្មោះថា វៀរដោយប្រពៃក្នុងលោក។

**អញ្ញាយ បទំ សមេច្ច ធម្មំ វិវដំ ទិស្វាន បហានមាសវានំ**
**សព្វូបធីនំ បរិក្ខយា នោ សម្មា សោ លោកេ បរិព្វជេយ្យ។**

ភិក្ខុកំណត់ដឹងនូវបទ គឺសច្ចៈមួយៗ ហើយត្រាស់ដឹងនូវសច្ចធម៌ ឃើញនូវព្រះនិព្វាន មិនមានគ្រឿងដោតក្រងជាទីលះបង់

នូវអាសវៈទាំងឡាយ ព្រោះអស់ទៅនៃឧបធិកិលេសទាំងពួង ភិក្ខុនោះ ឈ្មោះថា វៀរដោយប្រពៃក្នុងលោក។

**អន្ធា ហិ ភគវា តថេវ ឯតំ យោ សោ ឯវំវិហារិ ទន្តោ ភិក្ខុសព្វសំយោជនិយេ វតិវត្តោ សម្មាសោ លោកេ បរិព្វជេយ្យាតិ។**

(ព្រះពុទ្ធនិម្មិតពោលសរសើរថា) សេចក្តីពិតថាព្រះមានព្រះភាគទ្រង់ត្រាស់ ព្រះពុទ្ធដីកាយ៉ាងនេះ មានសេចក្តីបែបនោះដដែលថា ភិក្ខុណាមានការនៅយ៉ាងនេះ ជាអ្នកទូន្មានខ្លួនប្រព្រឹត្តកន្លងនូវសំយោជនធម៌ទាំងពួង ភិក្ខុនោះ ឈ្មោះថាវៀរដោយប្រពៃក្នុងលោក ។

*( ចប់ សម្មាបរិព្វាជនិយសូត្រទី ១៣ )*

ព្រះគាថាក្នុងកលហវិវាទសូត្រទី១១ បិដកលេខ៥៤ ទំព័រ ២៩០

(ព្រះពុទ្ធនិម្មិត ត្រាស់សួរព្រះសម្ពុទ្ធថា បពិត្រព្រះអង្គ )

**កុតោ បហូតា កលហា វិវាទា បរិទេវសោកា សហមច្ឆរា ច មានាតិមានា សហបេសុណា ច កុតោ បហូតា តេ តទិង្ឃ ព្រូហិ។**

ការឈ្លោះ ការទាស់ទែងគ្នា ការខ្សឹកខ្សួល ការសោកស្តាយ និងសេចក្តីកំណាញ់ ការប្រកាន់ ការមើលងាយ និងការញុះញង់

កើតមកអំពីណា កិលេសធម៌ទាំងនោះ បណ្តាលមកអំពីណា សូមព្រះអង្គសម្តែងសេចក្តីនោះឱ្យទាន ។

(ព្រះសម្ពុទ្ធទ្រង់ត្រាស់ថា)

**បិយប្បហូតា កលហា វិវាទា បរិទេវសោកា សហមច្ឆរា ច**
**មានាតិមានា សហបេសុណា ច វិវាទជាតេសុ ច បេសុណានិ។**

ការឈ្លោះ ការទាស់ទែងគ្នា ការខ្សឹកខ្សួល ការសោកស្តាយ និងសេចក្តីកំណាញ់ ការប្រកាន់ ការមើលងាយ និងការញុះញង់ កើតមកអំពីរបស់ជាទីស្រឡាញ់ ឯកិលេសធម៌ មានការឈ្លោះ និងការជជែកគ្នា(ជាដើម)ប្រកបក្នុងសេចក្តីកំណាញ់កាលបើសេច - ក្តីទាស់ទែងគ្នាកើតឡើងហើយពាក្យញុះញង់ក៏កើតឡើងដែរ ។

## **សម្បត្តិ ២ យ៉ាង**

ពោលពីទ្រព្យសម្បត្តិ គឺអ្នកណាៗក៏ដឹងថា មាស ប្រាក់ គោ ក្របី ដំរី សេះ ឡាន វីឡា ដីស្រែ ដីឡូតិ៍ សម្បូរហូរហៀរចាយ

វាយតាមអំពើចិត្ត មិនកង្វល់ មិនព្រួយចិត្ត មិនលំបាកគិតនេះឯង ដែលលោកិយមហាជនសម្គាល់ថាមានទ្រព្យសម្បត្តិ ឬអ្នកមានធំ។

តាមព្រះបរមពុទ្ធោវាទ ព្រះអង្គត្រាស់សម្តែង ក៏ទ្រង់មិនបាន បដិសេធនូវទ្រព្យទាំងនោះ ថាអត់ប្រយោជន៍នោះទេព្រោះការ រស់នៅក្នុងជីវភាពប្រចាំថ្ងៃ គឺត្រូវអាស្រ័យនូវបច្ច័យ៤ សម្រាប់- រស់ហ្នឹងឯង។ តែថាទ្រព្យសម្បត្តិនោះៗក៏មិនចាំបាច់ទាល់តែមាន លើស លប់ទើបជីវិតមានសេចក្តីសុខដែរ ។ ជីវិតដែលមាន សេចក្តីសុខបរិបូណ៌ត្រូវតែសម្បទាដោយហេតុច្រើនយ៉ាងណាស់ ហើយទ្រព្យសម្បត្តិគ្រាន់តែ១ចំណែកតូចនៃសេចក្តីសុខនោះ នឹង អាចដោះស្រាយរឿងរ៉ាវជីវិតដែលមានទុក្ខ ជីវិតដែលជាទុក្ខមិន បានទាំងស្រុងនោះទេ។

សម្បត្តិទ្រព្យដែលប្រសើរ ជាសម្បត្តិនាំមកនូវសេចក្តីសុខពិត ប្រាកដនោះតើដូចម្តេច? សូមពុទ្ធបរិស័ទងាកចិត្តមកសិក្សា អំពី សម្បត្តិ ២ យ៉ាង ដូចតទៅ ។

សម្បត្តិជាលោកិយ១ សម្បត្តិលោកុត្តរ១ (ឬសម្បត្តិព្រះធម៌ ក្នុង ចិត្តដែលចិត្តមានសទ្ធា ដែលធ្លាប់ហ្វឹកហាត់ អប់រំទទួលបាន) ។

កាលដែលព្រះសម្មាសម្ពុទ្ធទ្រង់យាងចូលកាន់កបិលព័ស្តុជានគរព្រះពុទ្ធបិតា ថ្ងៃដែល ព្រះអង្គយាងចេញពីមហាប្រាសាទ ព្រះ-បិតាព្រះនាងពិម្ពាយសោធរាបានបង្គាប់ឱ្យព្រះរាហុលកុមារដែលមានព្រះជន្ម៧ព្រះវស្សា ទៅទូលសូមកំណាប់អំពីព្រះសម្មាសម្ពុទ្ធដែលជា សម្បត្តិស្តេចចក្រ។ ព្រះសម្មាសម្ពុទ្ធ ទ្រង់ព្រះតម្រិះថាសម្បត្តិស្តេចចក្រជាសម្បត្តិលោកិយ មិនអាចធ្វើឱ្យរួចផុតចាកពី-ទុក្ខ គឺ ជាតិជរា ព្យាធិ មរណៈ បានឡើយ។ ដូច្នោះហើយទើបទ្រង់ត្រាស់បង្គាប់ឱ្យព្រះធម្មសេនាបតីសារីបុត្ត ជាព្រះឧបជ្ឈាយ៍បំបួសព្រះរាហុលកុមារ ព្រះមហាមោគ្គល្លាន ជាព្រះអាចារ្យទាំងដែលព្រះរាហុលមានព្រះជន្ម៧ខួបនោះ ។ ព្រោះការដែល-បព្វជ្ជាជាសម្បត្តិក្រៃលែង នឹងធ្វើឱ្យជីវិតនេះទទួលបាននូវសេចក្តីសុខពិតប្រាកដ ឬថាជាលោកុត្តរៈ សម្បត្តិសម្រាប់ព្រះរាហុលនោះឯង។

នៅក្នុងព្រះត្រៃបិដកលេខ៤៧ ទំព័រ៦ ធនវគ្គ ព្រះអង្គទ្រង់ត្រាស់ថា :

**សត្តិមានិ ភិក្ខវេ ធនានិ** ម្នាលភិក្ខុទាំងឡាយ ទ្រព្យនេះមាន ៧ យ៉ាង ។ **កតមានិ សត្ត** ៧យ៉ាង តើអ្វីខ្លះ។ **សទ្ធាធនំ** ទ្រព្យគឺសទ្ធា១ **សីលធនំ** ទ្រព្យគឺសីល១ **ហិរិធនំ** ទ្រព្យគឺហិរិ១ **ឱត្តប្បធនំ** ទ្រព្យគឺឱត្តប្បៈ១ **សុតធនំ** ទ្រព្យគឺ សុតៈ១ **ចាគធនំ** ទ្រព្យ គឺចាគៈ១ **បញ្ញាធនំ** ទ្រព្យគឺបញ្ញា១។ **ឥមានិ ខោ ភិក្ខវេ សត្តធនានីតិ** ម្នាលភិក្ខុទាំងឡាយ នេះទ្រព្យ ៧ យ៉ាង។

**សទ្ធាធនំ សីលធនំ ហិរី ឱត្តប្បិយំ ធនំ**
**សុតធនញ្ច ចាគោ ច បញ្ញា វេ សត្តមំ ធនំ ។**

ទ្រព្យគឺសទ្ធា ទ្រព្យគឺសីល ទ្រព្យគឺហិរិ ទ្រព្យគឺឱត្តប្បៈ ទ្រព្យគឺសុតៈ ទ្រព្យគឺចាគៈ ទ្រព្យគឺបញ្ញា ជាគម្រប់ ៧ ។

**យស្ស ឯតា ធនា អត្ថិ ឥត្ថិយា បុរិសស្ស វា**
**អទលិទ្ទោតិ តំ អាហុ អមោឃំ តស្ស ជីវិតំ ។**

បុគ្គលណា ទោះស្ត្រីក្តី បុរសក្តី មានទ្រព្យទាំងនេះ អ្នកប្រាជ្ញទាំងឡាយ ហៅបុគ្គល នោះថាជាអ្នកមិនទាល់ក្រឡើយការរស់នៅរបស់បុគ្គលនោះមិនសោះសូន្យឡើយ។

**តស្មា សទ្ធញ្ច សីលញ្ច បសាទំ ធម្មទស្សនំ**

**អនុយុញ្ជេថ មេធាវី សរំ ពុទ្ធានសាសនន្តិ។**

ហេតុនោះ អ្នកប្រាជ្ញ កាលរឭកនូវពាក្យប្រៀនប្រដៅរបស់ព្រះពុទ្ធទាំងឡាយ គប្បីប្រកបរឿយៗ នូវសទ្ធាសីល សេចក្តីជ្រះថ្លា និងការឃើញធម៌ ។

ដូច្នេះ យោងតាមព្រះពុទ្ធដីកានេះ យើងឃើញថាសម្បត្តិជាលោកិយគឺ លុយកាក់ មាស ប្រាក់ ឡាន វីឡា និងវត្ថុ សម្ភារៈទាំងអស់ មិនសំខាន់ពេកទេ គ្រាន់តែល្មមៗ ដែលអាចញ៉ាំងជីវិតឱ្យរស់នៅជាសុខក្នុងបច្ចុប្បន្ន ហើយបំពេញ សេចក្តីឧស្សាហ៍ព្យាយាមក្នុងការ សិក្សានូវព្រះធម៌ ព្រះពុទ្ធោវាទ សមរម្យណាស់ទៅហើយ។ អ្វីដែលគប្បីមាននោះ គឺការហ្វឹកហាត់អប់រំទូន្មានចិត្ត ឃុំគ្រងថែរក្សាចិត្ត ឱ្យចេះទទួលនូវសេចក្តីសុខតាមផ្លូវព្រះធម៌វិញព្រោះថាបើចិត្តសុខហើយ គឺមិនមានអ្វីដែលនាំឱ្យកើតទុក្ខនោះទេ ចិត្តនេះព្រះសាស្តា ព្រះអង្គទ្រង់ត្រាស់នៅក្នុងគាថាធម្មបទ ចិត្តវគ្គថា :

**ទូរង្គមំ ឯកចរំ អសរីរំ គុហាសយំ**

**យេ ចិត្តំ សញ្ញមេស្សន្តិ មោក្ខន្តិ មារពន្ធនា ។**

អ្នកទាំងឡាយណា នឹងសង្រួមចិត្តដែលទៅឆ្ងាយ ជាចិត្តត្រេចទៅតែឯង មិនមានសរីរៈ មានគុហាគឺមហាភូតរូប៤ ជាទីអាស្រ័យនៅ អ្នកទាំងនោះឯង រមែងរួចចាកចំណង នៃមារ។

ដោយសេចក្តីថា កាលបើចិត្តមានសេចក្តីសុខ ព្រោះបានការឃុំគ្រងហើយនោះ មិនមែនត្រឹមតែសុខធម្មតាៗនោះទេ សេចក្តីសុខដែលមិនអាស្រ័យសម្បត្តិខាងក្រៅ គឺសុខដល់កំពូលគឺមិនអាចនឹងពណ៌នាឱ្យអស់បាននោះទេ។ ដែលថាមិនអាស្រ័យសម្បត្តិខាងក្រៅ តែទទួលបានសេចក្តីសុខនោះ ព្រះសម្មាសម្ពុទ្ធទ្រង់ត្រាស់សម្តែងទុកជាច្រើន នឹងលើកឡើងឱ្យឃើញហើយដើម្បីសិក្សានូវសេចក្តីសុខនោះ ហ្វឹកហាត់ទទួលយកសេចក្តីសុខនោះមក ទុកដាក់ក្នុងសន្តានចិត្តដូចតទៅ:

**ហេតុនៃសេចក្តីសុខដែលមិនអាស្រ័យសម្បត្តិខាងក្រៅ**

គាថាធម្មបទ ចិត្តវគ្គ បិដកលេខ៥២ ទំព័រ២៨:

**ទុន្និគ្គហស្ស លហុនោ យត្ថ កាមនិបាតិនោ**

**ចិត្តស្ស ទមថោ សាធុ ចិត្តំ ទន្តំ សុខាវហំ ។**

ការទូន្មានចិត្ត ដែលសង្កត់សង្កិន បានដោយលំបាកជាធម្មជាតិរហ័ស មានប្រក្រតី ធ្លាក់ចុះទៅតាមសេចក្តីប្រាថ្នា ក្នុងអារម្មណ៍ណាមួយ រមែងញុំាងគុណឱ្យសម្រេច (ព្រោះថា) ចិត្តដែលហ្វឹកហាត់បានហើយ រមែងនាំមកនូវសេចក្តីសុខ។

**សុទុទ្ទសំ សុនិបុណំ យត្ថ កាមនិបាតិនំ**
**ចិត្តំ រក្ខេថ មេធាវី ចិត្តំ គុត្តំ សុខាវហំ ។**

អ្នកមានប្រាជ្ញាគួររក្សាចិត្តដែលឃើញដោយកម្រក្រៃពេក ដែលល្អិតក្រៃពេក មានប្រក្រតីធ្លាក់ចុះទៅតាមសេចក្តីប្រាថ្នា ក្នុងអារម្មណ៍ណាមួយ (ព្រោះថា) ចិត្តដែលគេរក្សាបានហើយរមែងនាំមកនូវសេចក្តីសុខ។

**បុញ្ញញ្ចេ បុរិសោ កយិរា កយិរាថេនំ បុនប្បុនំ**
**តម្ហិ ឆន្ទំ កយិរាថ សុខោ បុញ្ញស្ស ឧច្ចយោ ។**

បើបុរសធ្វើបុណ្យ គួរធ្វើបុណ្យនោះឱ្យរឿយៗ គួរធ្វើសេចក្តីពេញចិត្តក្នុងបុណ្យនោះ (ព្រោះថា) ការសន្សំបុណ្យ តែងនាំសេចក្តីសុខមកឱ្យ។

មិនត្រឹមតែប៉ុណ្ណោះ សេចក្ដីសុខដែលកើតអំពីបុណ្យដូចដែលបានពោលរៀបរាប់មកនេះព្រះសាស្ដាទ្រង់ត្រាស់ដល់សេចក្ដីសុខ-ក្នុងការប្រព្រឹត្តនូវសុចរិតកម្មផង ទាំងសេចក្ដីសុខដែលជាវិបាកផង សេចក្ដីសុខដែលមិនអាស្រ័យដោយទ្រព្យសម្បត្តិខាងក្រៅមានសេចក្ដីសុខដ៏ជ្រាលជ្រៅជាសេចក្ដីសុខល្អិតសុខុមក្រៃលែង ។ ដូចមេរៀនដែលលោកគ្រូ **អគ្គបណ្ឌិត** សម្ដែងហៅឱ្យសរសេរនៅវត្តឧណ្ណាលោម ថ្ងៃ១៣កើត ខែមិគសិរ ព.ស.២៥៤៧ អំពីសេចក្ដីសុខដ៏កំពូល ជាសេចក្ដីសុខដ៏ឧត្ដម ជាសេចក្ដីសុខដែលនរណា១ ក៏មិនដែលបានទទួលមានតែព្រះសម្មាសម្ពុទ្ធ និងព្រះអរិយសាវកតែប៉ុណ្ណោះ ទើបលោកធ្លាប់ទទួលបាននូវសេចក្ដី-សុខនោះ (ឬថា អ្នកដែលមានការអប់រំសន្សំអធ្យាស្រ័យទទួលយកនូវសេចក្ដីសុខនោះ) សេចក្ដីសុខដែលពោលមកនេះ គឺជាទុក្ខនិរោធ ឬ ព្រះនិព្វាន លក្ខណៈសំខាន់របស់ព្រះនិព្វាន ដែលមានឈ្មោះថា និរោធ ប្រែថា ការរលត់នោះគួរឱ្យពុទ្ធបរិស័ទយើង-យល់ចូលចិត្តនិងជ្រះថ្លា គឺ មាន ៣ យ៉ាង:

១.**ការរលត់អវិជ្ជា**សំដៅដល់ការកើតឡើងនៃញាណទស្សនៈដ៏ខ្ពង់ខ្ពស់ ត្រាស់ដឹងនូវសច្ចធម៌ ។

២.**ការរលត់កិលេស** សំដៅដល់ការកម្ចាត់សេចក្តីអាក្រក់ និងភាពសៅហ្មងផ្សេង ៗក្នុងចិត្ត អស់ហេតុដែលសម្រាប់បង្កបញ្ហាសេចក្តីក្តៅក្រហាយផ្សេងៗ ដល់ជីវិតក្នុងសង្គម ។

៣.**ការរលត់ទុក្ខ** សំដៅដល់ការអស់ទុក្ខ សម្រេចសេចក្តីសុខដ៏ខ្ពង់ខ្ពស់ ។

សេចក្តីសុខ មានសេចក្តីសំខាន់ណាស់ ក្នុងបដិបត្តិធម៌នៃព្រះពុទ្ធសាសនា។ បដិបត្តិធម៌មិនចែកផ្សេងគ្នាអំពីសេចក្តីសុខឡើយចាប់ផ្តើមតាំងពីដំបូងក្នុងការធ្វើល្អទូទៅ ដែលហៅថាបុណ្យ។ ព្រះសម្មាសម្ពុទ្ធទ្រង់ត្រាស់ថា "អ្នកទាំងឡាយ ចូរកុំខ្លាចបុណ្យ ព្រោះបុណ្យជាឈ្មោះនៃសេចក្តីសុខ"។

ក្នុងការបំពេញព្យាយាមផ្លូវចិត្ត ឬចម្រើនភាវនា សេចក្តីសុខក៏ជាបច្ច័យ ដ៏សំខាន់ ក្នុងការជួយឱ្យកើតសមាធិ (អ្នកមានសេចក្តីសុខ ចិត្តរមែងតាំងមាំ) លុះដល់ចិត្តជាសមាធិ សម្រេចឈានហើយ សេចក្តីសុខក៏ជាអង្គប្រកបរបស់ឈាន ដូចដែលយើង

ហៅថា អង្គឈាន រហូតដល់ឈានទី៤ (បញ្ចកន័យ)។ ឈានសមាបត្តិដែលខ្ពស់ជាងនោះតទៅ សូម្បីមិនមានសេចក្តីសុខជាអង្គប្រកបក៏ដោយ គឺរឹងរិតតែសុខយ៉ាងប្រណីតក្រៃលែងទៅទៀត ចំណុចទិសដៅដ៏ខ្ពង់ខ្ពស់របស់ព្រះពុទ្ធសាសនាគឺ **ព្រះនិព្វាន** ជាបរមសុខ គឺសុខដ៏ខ្ពង់ខ្ពស់ ក្រៃលែងបំផុត ។

ក្រៅអំពីចំណុចទិសដៅដ៏ខ្ពង់ខ្ពស់របស់ព្រះពុទ្ធសាសនា ដែលជា **បរមសុខ** គឺ **ព្រះនិព្វាន**នោះនៅមានសេចក្តីសុខដែលជាធម៌បដិបត្តិទៀត ដើម្បីឱ្យបានសម្រេចនូវទិសដៅដ៏ខ្ពង់ខ្ពស់នោះ ។

បរមសុខ គឺ ព្រះនិព្វាន មិនមែនសម្រេចដោយទុក្ខ ឬធម៌បដិបត្តិដែលជាទុក្ខឡើយ ព្រះពុទ្ធជាអម្ចាស់ទ្រង់ត្រាស់ថា "តថាគតបានសម្រេចដល់សេចក្តីសុខ ដែលមិនអាស្រ័យកាម ទើបប្តេជ្ញាថា នឹងមិនត្រឡប់មករកកាមទៀត" ព្រមជាមួយគ្នានោះ ព្រះអង្គបានត្រាស់ សម្តែងដាស់តឿន អ្នកប្រព្រឹត្តធម៌ ឱ្យចាំ ទុកថា: (បិដកលេខ ២០ ទំព័រ៣៣៦ ចំណុច២១១) បើអរិយសាវកបានឃើញច្បាស់តាមសេចក្តីពិត ដោយប្រាជ្ញាដ៏ប្រពៃតាមពិតថា **កាមទាំងឡាយមានសេចក្តីសុខតិច មានទុក្ខច្រើន មានសេចក្តី**

ចង្អៀតចង្អល់ច្រើន ទុក្ខក្នុងកាមទាំងឡាយនុះមានច្រើនក្រៃពេក ។ អរិយសាវកនោះឯង បានវៀរចាកកាមទាំងឡាយ វៀរចាកអកុសលទាំងឡាយហើយ តែមិនទាន់បាននូវបីតិ និង សុខ ឬគុណជាតដទៃដែលល្អិតលើសជាងបីតិ និង សុខនោះទេ កាលបើដូច្នោះ អរិយសាវកនោះ នឹងឈ្មោះថាមិនវិលត្រឡប់មករកកាមទាំងឡាយវិញនោះ មិនមែនឡើយ។ សេចក្ដីដែលលើកយកមកបញ្ជាក់នេះ ក្រៅអំពីការសម្ដែងឱ្យឃើញថា ព្រះពុទ្ធសាសនាកាន់យកសេចក្ដីសុខជារឿងសំខាន់ហើយ នៅធ្វើឱ្យយើងមានការសិក្សាសង្កេតតទៅទៀតថា ការដែលអរិយសាវកលះកាមនោះមិនមែនព្រោះកាមមិនមាន សេចក្ដីសុខនោះទេឬ ថាព្រោះព្រះពុទ្ធសាសនាប្រដៅឱ្យវៀរចាកសេចក្ដីសុខ ក៏មិនមែនដែរ ព្រះពុទ្ធសាសនាព្រមទទួលថា សុខតាមសេចក្ដីពិត ទូន្មានឱ្យបដិបត្តិ ដើម្បីសម្រេចនូវសេចក្ដីសុខ និងព្រមទទួលថា កាមមានសេចក្ដីសុខ ប៉ុន្តែអរិយសាវកលះបង់កាម ព្រោះឃើញថាកាមមានសេចក្ដីសុខក៏ពិតមែនហើយតែនៅច្រឡំដោយទុក្ខច្រើន និង

ចំណុចសំខាន់ក៏គឺ នៅមានសេចក្ដីសុខដទៃដែលសុខជាង ជ្រៅល្អិតប្រណីតជាងសុខដែលកើតអំពីកាម ។

ដូចដែលពោលសម្ដែងរៀបរាប់មកនេះ សម្បត្តិ ២ យ៉ាងគឺ លោកិយសម្បត្តិនិង លោកុត្តរសម្បត្តិ យើងក៏អាចហៅបានថា សេចក្ដីសុខ ២យ៉ាងដែរ គឺ កាមសុខ១ និង នេក្ខម្មសុខ១ ព្រោះថា សេចក្ដីត្រេកត្រអាលរីករាយស្រស់ស្រាយនឹងទ្រព្យសម្បត្តិដែលជាលោកិយៈ ក៏គឺសេចក្ដីរីករាយត្រេកអរក្នុងកាមទាំងឡាយដូច្នោះឯង ។ ចំណែកសម្បត្តិដែលជាលោកុត្តរៈវិញនោះ គឺការចេញចាកកាមទាំងឡាយ ហើយរីករាយដោយសេចក្ដីសុខក្នុងភាពជាអ្នកមិនមានសេចក្ដីជាប់ជំពាក់ មិនមានសេចក្ដីអាឡោះអាល័យ មិនត្រូវការ មិនពឹងពាក់នឹងកាម មិនងប់ជ្រប់ក្នុងកាម មិនសាទរនឹងកាម តែជាការត្រេកអរដោយ វិបស្សនា រីករាយដោយញាណជាដើម ដែលជាការរលាស់ចេញចាកកាម ដូចដែលព្រះសម្មាសម្ពុទ្ធ ទ្រង់បន្លឺនូវឧទាននៅទៀបមុចលិន្ទ (ដើមរាំងអន្លក់) ក្បែរឆ្នេរស្ទឹងនេរញ្ជរា ក្នុងឧរុវេលាប្រទេសថា :

**សុខោ វិវេកោ តុដ្ឋស្ស សុតធម្មស្ស បស្សតោ**

**អព្យាបជ្ឈំ សុខំ លោកេ  បាណភូតេសុ សញ្ញមោ ។**

**សុខា វិរាគតា លោកេ  កាមានំ សមតិក្កមោ**

**អស្មិមានស្ស វិនយោ  ឯតំ វេ បរមំ សុខំ ។**

វិវេករបស់បុគ្គលអ្នកត្រេកអរ (ដោយមគ្គញ្ញាណ) មានធម៌ស្តាប់ហើយ បានឃើញច្បាស់ដោយ (ញាណចក្ខុ) នាំមកនូវសុខ ការមិនបៀតបៀនគ្នា និងការសង្រួមក្នុងសត្វទាំងឡាយ ជាការប្រាសចាកតម្រេក ការប្រព្រឹត្តកន្លងកាមទាំងឡាយ ជាសុខក្នុងលោកកិរិយាកម្ចាត់ បង់នូវអស្មិមានះ ដំណើរនុ៎ះ ឈ្មោះថាជាសុខយ៉ាងក្រៃលែង ។

ធម្មបទគាថា បកិណ្ណកវគ្គទី២១ បិដកលេខ៥២ ទំព័រ៨១

**មត្តាសុខបរិច្ចាគា  បស្សេ ចេ វិបុលំ សុខំ**

**ចជេ មត្តាសុខំ ធីរោ  សម្បស្សំ វិបុលំ សុខំ ។**

បើឃើញសេចក្តីសុខធំទូលាយ ព្រោះលះបង់សុខល្មមប្រមាណ អ្នកមានប្រាជ្ញា កាលឃើញសុខធំទូលាយ គប្បីលះសុខមានប្រមាណចេញ។

**បរទុក្ខូបធានេន  យោ អត្តនោ សុខមិច្ឆតិ**

វេរសំសគ្គសំសដ្ឋោ          វេរា សោ ន បរិមុច្ចតិ ។

ជនប្រាថ្នាសេចក្តីសុខ ដើម្បីខ្លួន ដោយបង្កទុក្ខដល់អ្នកដទៃជននោះឈ្មោះថា ច្រឡូកច្របល់ហើយដោយការជាប់ជំពាក់ គឺពៀរ រមែងមិនរួចចាកពៀរទេ។

យញ្ហិ កិច្ចំ តទបវិទ្ធំ     អកិច្ចំ បន កយីរតិ
ឧន្នលានំ បមត្តានំ តេសំ វឌ្ឍន្តិ អាសវា។

របស់ណាដែលខ្លួនគួរធ្វើ របស់នោះពួកភិក្ខុណាលះបង់ចោលហើយ តែរបស់ដែលមិនគួរធ្វើត្រឡប់ជាធ្វើវិញ អាសវៈទាំងឡាយ តែងចម្រើនឡើងដល់ភិក្ខុនោះ ជាអ្នកមានសេចក្តីប្រមាទមានមានះដូចជាដើមបបុសលើកឡើងហើយ ។

យេសញ្ច សុសមារទ្ធា     និច្ចំ កាយគតា សតិ
អកិច្ចន្តេ នំ សេវន្តិ      កិច្ចេ សាតច្ចការិនោ
សតានំ សម្បជានានំ     អត្ថំ គច្ឆន្តិ អាសវា ។

លុះតែសតិប្រព្រឹត្តទៅក្នុងកាយជានិច្ច ដែលពួកភិក្ខុណាបានប្រារព្ធប្រពៃហើយ ភិក្ខុទាំងនោះ រមែងជាអ្នកធ្វើការដែលគួរធ្វើ

រឿយៗ មិនធ្វើការដែលមិនគួរធ្វើ អាសវៈទាំងឡាយ របស់ពួកភិក្ខុនោះដែលជាអ្នកមានសតិ មានសម្បជញ្ញៈរមែងដល់នូវការអស់ទៅ

**មាតរំ បិតរំ ហន្ត្វា        រាជានោ ទ្វេ ច ខត្តិយេ**
**រដ្ឋំ សានុចរំ ហន្ត្វា        អនីឃោ យាតិ ព្រាហ្មណោ ។**

បុគ្គលសម្លាប់តណ្ហាដូចមាតាផង សម្លាប់អស្មិមានះដូចបិតាផង សម្លាប់សស្សតទិដ្ឋិ និងឧច្ឆេទទិដ្ឋិ ដូចស្តេចជាក្សត្រពីរព្រះអង្គផង សម្លាប់អាយតនៈដូចជាដែន ប្រព្រឹត្តទៅមួយអន្លើដោយបុរសអ្នកដើរតាមគឺសៀនផង រមែងបានទៅជាខីណាសវព្រាហ្មណ៍ ជាអ្នកមិនមានទុក្ខ ។

**មាតរំ បិតរំ ហន្ត្វា        រាជានោ ទ្វេ ច ខត្តិយេ**
**វេយ្យគ្ឃបញ្ចមំ ហន្ត្វា    អនីឃោ យាតិ ព្រាហ្មណោ ។**

បុគ្គលសម្លាប់តណ្ហាដូចមាតាផង សម្លាប់អស្មិមានះដូចបិតាផង សម្លាប់សស្សតទិដ្ឋិ និងឧច្ឆេទទិដ្ឋិ ដូចស្តេចជាក្សត្រពីរព្រះអង្គផង សម្លាប់អាយតនៈដូចជាដែន វិចិកិច្ឆា ដូចជាខ្លាធំជាគម្រប់៥ផង(ដែលនៅស្កាត់ផ្លូវ)បានហើយរមែងបានទៅជាខីណាសវព្រាហ្មណ៍ ជាអ្នកមិនមានទុក្ខ។

**សុប្បពុទ្ធំ បពុជ្ឈន្តិ សទា គោតមសាវកា**

**យេសំ ទិវា ច រត្តោ ច និច្ចំ ពុទ្ធគតា សតិ ។**

សតិរបស់ពួកជនណា ដែលឋិតនៅក្នុងព្រះពុទ្ធគុណ អស់-កាលជានិច្ច ទាំងថ្ងៃទាំងយប់ ជនពួកនោះ ឈ្មោះថា សាវករបស់ព្រះគោតម រមែងភ្ញាក់រឭកដោយប្រពៃ សព្វកាល។

**សុប្បពុទ្ធំ បពុជ្ឈន្តិ សទា គោតមសាវកា**

**យេសំ ទិវា ច រត្តោ ច និច្ចំ ធម្មគតា សតិ ។**

សតិរបស់ពួកជនណា ដែលឋិតនៅក្នុងព្រះធម្មគុណអស់កាលជានិច្ច ទាំងថ្ងៃទាំងយប់ ជនពួកនោះ ឈ្មោះថា សាវករបស់ព្រះ-គោតម រមែងភ្ញាក់រឭកដោយប្រពៃ សព្វកាល ។

**សុប្បពុទ្ធំ បពុជ្ឈន្តិ សទា គោតមសាវកា**

**យេសំ ទិវា ច រត្តោ ច និច្ចំ សង្ឃគតា សតិ ។**

សតិរបស់ពួកជនណា ដែលឋិតនៅក្នុងព្រះសង្ឃគុណអស់កាលជានិច្ច ទាំងថ្ងៃទាំងយប់ ជនពួកនោះ ឈ្មោះថាសាវករបស់ព្រះគោតម រមែងភ្ញាក់រឭកដោយប្រពៃ សព្វកាល ។

**សុប្បពុទ្ធំ បពុជ្ឈន្តិ សទា គោតមសាវកា**

**យេសំ ទិវា ច រត្តោ ច និច្ចំ កាយគតា សតិ ។**

សតិរបស់ពួកជនណា ដែលឋិតនៅក្នុងកាយ អស់កាលជានិច្ច ទាំងថ្ងៃទាំងយប់ ជនពួកនោះ ឈ្មោះថា សាវករបស់ព្រះគោតម រមែងភ្ញាក់រឭកដោយប្រពៃ សព្វកាល ។

**សុប្បពុទ្ធំ បពុជ្ឈន្តិ សទា គោតមសាវកា**
**យេសំ ទិវា ច រត្តោ ច អហឹសាយ រតោ មនោ ។**

ចិត្តរបស់ពួកជនណា ត្រេកអរហើយក្នុងការមិនបៀតបៀន គេ ទាំងថ្ងៃទាំងយប់ ជនពួកនោះ ឈ្មោះថាសាវករបស់ព្រះគោតម រមែងភ្ញាក់រឭកដោយប្រពៃ សព្វកាល ។

**សុប្បពុទ្ធំ បពុជ្ឈន្តិ សទា គោតមសាវកា**
**យេសំ ទិវា ច រត្តោ ច ភាវនាយ រតោ មនោ ។**

ចិត្តរបស់ពួកជនណា ត្រេកអរហើយក្នុងមេត្តាភាវនា ទាំង-ថ្ងៃទាំងយប់ ជនពួកនោះ ឈ្មោះថា សាវករបស់ព្រះគោតម រមែងភ្ញាក់រឭកដោយប្រពៃ សព្វកាល ។

**ទុប្បព្វជ្ជំ ទុរភិរមំ ទុរាវាសា ឃរា ទុខា**
**ទុក្ខោសមានសំវាសោ ទុក្ខានុបតិតទ្ធគូ**

**តស្មា ច ចទ្ធគូ សិយា ន ច ទុក្ខានុតបតិតោ សិយា ។**

ការចេញបួសបានដោយក្រ ការត្រេកអរត្រូវបានដោយក្រផ្ទះទាំងឡាយមានការនៅគ្រប់គ្រងដោយលំបាក ជាការក្រការនៅរួមដោយជនស្មើគ្នា (ដែលមិនមានសេចក្តីកោតក្រែង) ជាការក្រជនអ្នកដើរផ្លូវឆ្ងាយគឺវដ្តៈ តែងត្រូវសេចក្តីទុក្ខធ្លាក់ជាប់តាមព្រោះហេតុនោះ បុគ្គលមិនគប្បីជាអ្នកដើរផ្លូវឆ្ងាយផង មិនគប្បីជាអ្នកត្រូវសេចក្តីទុក្ខធ្លាក់ជាប់តាមផង ។

**សទ្ធោ សីលេន សម្បន្នោ យសោភោគសមប្បិតោ**
**យំ យំ បទេសំ ភជតិ តត្ថ តត្ថេវ បូជិតោ ។**

បុគ្គលអ្នកមានសទ្ធា បរិបូណ៌ដោយសីល ស្កប់ស្កល់ដោយយស និង ភោគសម្បត្តិ គប់រកប្រទេសណាៗ គេតែងបូជាក្នុងប្រទេសនោះៗ ។

**ទូរេ សន្តោ បកាសេន្តិ ហិមវន្តោវ បព្វតោ**
**អសន្តេត្ថ ន ទិស្សន្តិ រត្តឹ ខិត្តា យថា សរា ។**

ពួកសប្បុរស រមែងប្រាកដក្នុងទីឆ្ងាយ ដូចភ្នំហេមពាន្តដូច្នោះ ពួកអសប្បុរស (ទុកជាឋិតនៅ) ក្នុងទីជិត ក៏រមែងមិនប្រាកដដូចព្រួញដែលបុគ្គលបាញ់ ក្នុងវេលាយប់ ។

**ឯកាសនំ ឯកសេយ្យំ ឯកោ ចរមតន្ទិតោ**

**ឯកោ ទមយមត្តានំ វនន្តេ រមិតោ សិយា ។**

បុគ្គលគួរគប់រកទីអង្គុយម្នាក់ឯង ទីដេកម្នាក់ឯងជាអ្នកត្រាច់-ទៅម្នាក់ឯង មិនជាអ្នកខ្ជិលច្រអូស ជាអ្នកម្នាក់ឯងទូន្មានខ្លួន គួរជាអ្នកត្រេកអរក្នុងព្រៃស្ងាត់ ។

*(មេរៀនវត្តឧណ្ណាលោម ព.ស.២៥៤៧ ថ្ងៃ ៥រោច ខែមិគសិរ)*

## ប្រយោជន៍សំខាន់របស់សតិ

ចាកការសិក្សាក្នុងមហាសតិប្បដ្ឋានសូត្របានឃើញថាសតិប្ប-ដ្ឋានវិបស្សនា មិនមែនជាធម៌ដែលចាំបាច់ត្រូវគេចខ្លួនចេញទៅ-បដិបត្តិនៅខាងក្រៅពីសង្គមមនុស្សឡើយ ឬថាចាំបាច់ចំពោះក្នុងកាលវេលាណាមួយក៏មិនមែនដែរ ។

ពោលដោយសារៈសំខាន់ ក្នុងគោលសតិប្បដ្ឋាន៤ បានបង្ហាញឱ្យឃើញថា ជីវិតរបស់យើងនេះមានគោលចំណុចដែលគួរអប់រំចម្រើនសតិគ្រប់គ្រងទាំងអស់ត្រឹមតែ ៤ ផ្នែក គឺៈ

១.**រូប**ដែលប្រាកដមានឡើងគ្រប់ពេលនៃការប្រព្រឹត្តទៅនៃកាយ ។

២.**វេទនា** គឺសេចក្ដីដឹងខ្លួនជាសុខ ជាទុក្ខ ផ្សេងៗ ។

៣.**សភាពនៃចិត្ត** ដែលប្រាកដលក្ខណៈដឹងច្បាស់នូវអារម្មណ៍

៤.**ពួកធម៌ផ្សេងៗ** ដែលប្រកបនឹងការនឹកគិត និង ពួកធម៌ផ្សេងៗទៀតដែលបានប្រាកដឡើង ។ បើការប្រព្រឹត្តទៅនៃជីវិតមានសតិគ្រប់គ្រងក្នុងគោលចំណុចទាំង ៤ នេះហើយក៏នឹងជួយឱ្យជីវិតរស់នៅប្រាសចាកភ័យប្រាសចាកទុក្ខមានចិត្តស្អាត ប្រកប-ដោយសុខក្នុងបដិបទាដែលនាំទៅកាន់ការដឹងនូវអរិយសច្ចធម៌ ។

អត្ថន័យសេចក្ដីក្នុងការសម្ដែង **សតិប្បដ្ឋានសូត្រ** បានបញ្ជាក់ប្រាប់ឱ្យដឹងថា ក្នុងពេលបដិបត្តិនោះមិនមែនមានសតិ តែម្យ៉ាងប៉ុណ្ណោះទេ គឺមានធម៌ផ្សេងៗទៀតដែលត្រូវអប់រំចម្រើនជាមួយគ្នា ។

ធម៌ដែលព្រះអង្គទ្រង់ត្រាស់សម្តែងក្នុងគោលសតិប្បដ្ឋាននីមួយៗគឺ:

១.**អាតាបី** មានសេចក្តីព្យាយាម បានដល់សម្មាវាយាមៈ ព្យាយាមសង្រួម និង ព្យាយាមលះនូវសេចក្តីអាក្រក់ ព្រមទាំងព្យាយាមចម្រើន និង ព្យាយាមរក្សានូវសេចក្តីល្អ ។

២.**សម្បជានោ** មានសម្បជញ្ញៈ បានដល់បញ្ញា ។

៣.**សតិមា** មានសតិ បានដល់តួសតិហ្នឹងឯង។ ចំណុចដែលគួរសង្កេតគឺ គឺ **សម្បជានោ** = ដែលប្រែថា មានសម្បជញ្ញៈ។ សម្បជញ្ញៈនេះ យើងឃើញថា ជាធម៌ច្រើនតែជាគូនិងសតិ ។ សម្បជញ្ញៈក៏គឺ**បញ្ញា** ដូច្នេះការហ្វឹកហាត់អប់រំសតិនេះ ទើបជាផ្នែកបដិបត្តិមួយក្នុងការចម្រើនបញ្ញានោះឯង។

បញ្ញា ការដឹង ការយល់ច្បាស់ ក្នុងសភាវៈធម៌ដែលសតិបានកំណត់ទុក មិនមានការវង្វេង ឬការយល់ខុសណាៗក្នុងសភាវៈធម៌ឡើយ ។

**អាតាបី សម្បជានោ សតិមា** មានព្យាយាម មានសម្បជញ្ញៈ

មានសតិបានដល់ មានសម្មាវាយាមៈ សម្មាទិដ្ឋិ សម្មាសតិ ដែលជាអង្គមគ្គ។ អង្គមគ្គជាប្រចាំ បីអប់រំចម្រើនគួបគ្នាទៅជាមួយគ្នាជានិច្ច ក្នុងការចម្រើននូវវិបស្សនា សម្មាវាយាមៈ គឺព្យាយាមដាស់ចិត្ត ជំរុញចិត្ត មិនឱ្យទម្រន់មិនឱ្យរួញរា ដូច្នេះទើបមិនបើកឱ្យអកុសលធម៌កើតឡើង ។

សម្មាវាយាមៈ រមែងញុំាងកាយ ញុំាងចិត្តឱ្យឋិតនៅក្នុងផ្លូវបដិបត្តិជានិច្ច ញុំាងកុសលធម៌ផ្សេងៗឱ្យចម្រើនឡើងៗ ។

សម្មាសតិ គឺជាតួកំណត់ចាប់អារម្មណ៍ តាមទាន់តាមដឹងមិនភ័ន្តភាំងមិនប្រហែសមិនបណ្ដោយ មិនឱ្យកម្លាំងដល់បាបអកុសល (អត់សតិដូចជាការដេកលក់)។ សេចក្ដីក្នុងគោលសតិប្បដ្ឋានចុងក្រោយគឺៈ **វិនេយ្យ លោកេ អភិជ្ឈា ទោមនស្សំ** ប្រែថា កំចាត់អភិជ្ឈា និង ទោមនស្សក្នុងលោកបាន។ ដោយសេចក្ដីថា កាលបដិបត្តិយ៉ាងនេះ ចិត្តក៏ផុតស្រឡះ មិនមានជាប់ជំពាក់ចង់បាននិងមិនមានការអាក់អន់ខ្វចចិត្តចូលមកគ្របសង្កត់ រំខាន-ក្នុងជីវិតឡើយ ។ នេះគឺជាផលនៃការព្យាយាម មានសតិមានសម្បជញ្ញៈ ។

**អត្ថិ កាយោតិ វា បនស្ស សតិ បច្ចុប្បដ្ឋិតា ហោតិ យាវ ទេវ ញាណមត្តាយ បដិស្សតិ មត្តាយ** ប្រែថា ម្យ៉ាងទៀត ស្មារតីរបស់ភិក្ខុនោះ ក៏ផ្ចង់ឡើងចំពោះថា កាយ-នេះមានមែន គ្រាន់តែជាទីកំណត់ដើម្បីឱ្យចម្រើនប្រាជ្ញា ដើម្បីឱ្យចម្រើនសតិស្មារតីប៉ុណ្ណោះ ។

ដោយសេចក្តីថា មានសតិកំណត់ច្បាស់លាស់ត្រង់តាម សេចក្តីពិតថាមានតែកាយ មិនមានសត្វបុគ្គល បុរស ស្រ្តី ខ្លួន របស់ខ្លួនឬរបស់គេឡើយ ។ កាយមានគឺមានដើម្បីត្រឹមតែឱ្យចម្រើន-ប្រាជ្ញាស្មារតីតែប៉ុណ្ណោះ ពោលគឺជាទីតាំងនៃសតិសម្បជញ្ញៈ មិនមែន ដើម្បីសេចក្តី ប្រកាន់មាំជាដើមឡើយ ។

**អនិស្សិតោ ច វិហរតិ** ប្រែថា ភិក្ខុមានចិត្តមិនអាស្រ័យដោយតណ្ហា និងទិដ្ឋិ គ្រប់ឥរិយាបថទាំង៤ផង។ ដោយសេចក្តីថាមានចិត្តជាឥស្សរៈ គឺមិនមានតណ្ហា និង ទិដ្ឋិ ជាទីអាស្រ័យមិននៅក្នុងអំណាចនៃកិលេស ។

**ន ច កិញ្ចិ លោកេ ឧបាទិយតិ** មិនប្រកៀកប្រកាន់អ្វីតិចតួចក្នុងលោកផង ។

**កាយេ កាយានុបស្សី វិហរតិ** ពិចារណាឃើញកាយក្នុងកាយជាប្រក្រតីគ្រប់ឥរិយាបថទាំង ៤ ។ ដោយសេចក្ដីថា ឃើញដោយបញ្ញាទៅក្នុងកាយថា មានតែកាយហ្នឹងឯង គឺ មើលឃើញកាយតាមសភាវធម៌ ដែលជាទីប្រជុំ ឬ ប្រកបចូលគ្នានៃសភាវរូបផ្សេងៗ មិនមែន មើលឃើញកាយថា ជាយើង ជាគេ ឬជារបស់យើង របស់គេ ជាដើមឡើយ។ ជាការឃើញ ត្រង់តាមសេចក្ដីពិត ត្រង់តាមសភាវៈ គឺមើលឃើញកាយ ក៏ឃើញកាយ មិនមែនមើល ឃើញកាយ ទៅជាឃើញអ្នកនេះ អ្នក នោះ ឬអ្នកដែលស្អប់ អ្នកដែលស្រឡាញ់ ជាដើមនោះឡើយ ។

*ឧទាន បាដលិគ្គាមិយវគ្គ ទី៨ បិដកលេខ ៥២ ទំព័រ ៣២០*

(១៥៨) ខ្ញុំបានស្ដាប់មកយ៉ាងនេះ ។ សម័យមួយ ព្រះមាន-ព្រះភាគ ទ្រង់គង់នៅក្នុងវត្តជេតពន របស់អនាថបិណ្ឌិកសេដ្ឋី ទៀបក្រុងសាវត្ថី។សម័យនោះឯងព្រះមានព្រះភាគទ្រង់ពន្យល់ភិក្ខុទាំងឡាយឱ្យយល់ច្បាស់(**សន្ទស្សេតិ**) ឱ្យកាន់យក (**សមាទបេតិ**) ឱ្យអាចហ៊ាន (**សមុត្តេជេតិ**) ឱ្យរីករាយ (**សម្បហំសេតិ**)ដោយ-ធម្មីកថាប្រកបដោយព្រះនិព្វាន ពួកភិក្ខុទាំងនោះបានធ្វើឱ្យជា-

ប្រយោជន៍ ធ្វើទុកក្នុងចិត្ត ប្រមូលមកនូវធម្មទេសនាទាំងអស់-ដោយចិត្ត ផ្ទង់ត្រចៀកស្តាប់ធម៌ ។ លំដាប់នោះ ព្រះមានព្រះភាគទ្រង់ជ្រាបច្បាស់ នូវសេចក្តីនោះទើបទ្រង់បន្លឺឧទាននេះ ក្នុងវេលានោះថា:

**អត្ថិ ភិក្ខវេ តទាយតនំ យត្ថ នេវ បឋវី ន អាបោ ន តេជោ ន វាយោ ន អាកាសានញ្ចាយតនំ ន វិញ្ញាណញ្ចាយតនំ ន អាកិញ្ចញ្ញាយតនំ ន នេវសញ្ញានាសញ្ញាយតនំ នាយំ លោកោ ន បរលោកោ ន ឧភោ ចន្ទិមសុរិយា តមហំ ភិក្ខវេ នេវ អាគតឹ វទាមិ ន គតឹ ន ឋិតឹ ន ចុតឹ ន ឧបបត្តឹ អប្បតិដ្ឋំ អប្បវត្តំ អនារម្មណមេវ តំ ឯសេវន្តោ ទុក្ខស្សាតិ ។**

ម្នាលភិក្ខុទាំងឡាយអាយតនៈនោះរមែងមានពិត (អាយតនៈក្នុងទីនេះ សំដៅយកព្រះនិព្វាន ដែលជាហេតុរបស់ផលញ្ញាណ) ដីមិនមានទឹកមិនមានភ្លើងមិនមានខ្យល់មិនមានអាកាសានញ្ចាយ-តនៈ មិនមានវិញ្ញាណញ្ចាយតនៈ មិនមានអាកិញ្ចញ្ញាយតនៈ មិនមាននេវសញ្ញានាសញ្ញាយតនៈ មិនមានលោកនេះ មិនមានលោក

មុខមិនមាន ព្រះចន្ទនិងព្រះអាទិត្យទាំងពីរ ក៏មិនមានក្នុងព្រះ-និព្វានណា ម្នាលភិក្ខុទាំងឡាយ តថាគតពោលព្រះនិព្វាននោះថា មិនមានដំណើរមក មិនមានដំណើរទៅ មិនមានការតាំងនៅ មិនមានការច្យុតិ មិនមានការកើត មិនមានទីជាទីតាំង មិនប្រព្រឹត្តទៅ មិនមានអារម្មណ៍ ព្រះនិព្វាននោះជាទីបំផុតទុក្ខតែម្យ៉ាង ។

ទំព័រ ៣២១:

**ទុទ្ទសំ អនត្តំ នាម ន ហិ សច្ចំ សុទស្សនំ**

**បដិវិទ្ធា តណ្ហា ជានតោ បស្សតោ នត្ថិ កិញ្ចនន្តិ ។**

ធម្មតាព្រះនិព្វាន បុគ្គលឃើញបានដោយកម្រ និព្វានសច្ចៈមិនមែនសម្រាប់ឃើញ បានដោយងាយទេ កិលេសជាគ្រឿងកង្វល់ រមែងមិនមាន ដល់បុគ្គលកាលដឹង កាលឃើញតណ្ហាព្រោះត្រាស់ដឹង (នូវសច្ចៈ)។

ទំព័រ ៣២២:

**អត្ថិ ភិក្ខវេ អជាតំ អភូតំ អកតំ អសង្ខតំ នោ ចេតំ ភិក្ខវេ អភវិស្ស អជាតំ អភូតំ អកតំ អសង្ខតំ នយិធ ជាតស្ស ភូតស្ស កតស្ស សង្ខតស្ស និស្សរណំ**

**បញ្ញាយេថ** : ម្នាលភិក្ខុទាំងឡាយ ព្រះនិព្វានឈ្មោះថា អជាតៈ ឈ្មោះថា អភូតៈ ឈ្មោះថាអកតៈ ឈ្មោះថាអសង្ខតៈ មានប្រាកដ ម្នាលភិក្ខុទាំងឡាយ ប្រសិនណាបើព្រះនិព្វាននោះ ឈ្មោះថា អជាតៈ ឈ្មោះថា អភូតៈ ឈ្មោះថា អកតៈ ឈ្មោះថា អសង្ខតៈ មិនមានទេការរលាស់ចេញនូវកិលេសដែលនាំឱ្យកើតមហាភូតរូប ដែលប្រាកដនូវហេតុ ដែលធ្វើនូវបច្ច័យដែលតាក់តែងក្នុងលោក-នេះ ក៏មិនប្រាកដ។

**យស្មា ច ខោ ភិក្ខវេ អត្ថិ អជាតំ អភូតំ អកតំ អសង្ខតំ តស្មា ជាតស្ស ភូតស្ស កតស្ស សង្ខតស្ស និស្សរណំ បញ្ញាយតីតិ** : ម្នាលភិក្ខុទាំងឡាយ ព្រះនិព្វានឈ្មោះថាអជាតៈ ឈ្មោះថា អភូតៈ ឈ្មោះថា អកតៈ ឈ្មោះថា អសង្ខតៈ រមែងមានប្រាកដ ព្រោះហេតុណាហេតុនោះការរលាស់ចេញនូវ-កិលេស ដែលនាំឱ្យកើតមហាភូតរូបដ៏ប្រាកដនូវហេតុគួរធ្វើនូវបច្ច័យជាទីតាក់តែង ក៏រមែង ប្រាកដ ។

ព្រះគាថាព្រះអង្គសម្តែងប្រារព្ធព្រះបាទសុទ្ធោទនសក្យរាជ

**ឧត្តិដ្ឋេ នប្បមជ្ជេយ្យ ធម្មំ សុចរិតំ ចរេ**

**ធម្មចារី សុខំ សេតិ អស្មឹ លោកេ បរម្ហិ ច ។**

បុគ្គលមិនគួរប្រមាទ ក្នុងដុំបាយដែលខ្លួនគប្បីក្រោកឡើងទទួល គប្បីប្រព្រឹត្តធម៌ឱ្យសុចរិត បុគ្គលអ្នកប្រព្រឹត្តធម៌ជាប្រក្រតីរមែងដេកជាសុខក្នុងលោកនេះផង ក្នុងលោកខាងមុខផង ។

ព្រះរាជាទ្រង់បានធ្វើឱ្យជាក់ច្បាស់នូវសោតាបត្តិផល ក្នុងកាលដែលចប់នៃព្រះគាថា និងបានស្ដាប់ព្រះគាថានេះថា:

**ធម្មំ សុចរិតំ ចរេ ន តំ ទុច្ចរិតំ ចរេ**

**ធម្មចារី សុខំ សេតិ អស្មឹ លោកេ បរម្ហិ ច ។**

បុគ្គលគួរប្រព្រឹត្តធម៌ឱ្យជាសុចរិត មិនគួរប្រព្រឹត្តធម៌នោះឱ្យទុច្ចរិតឡើយ បុគ្គលប្រព្រឹត្តធម៌ជាប្រក្រតី រមែងដេកជាសុខក្នុងលោកនេះផង ក្នុងលោកខាងមុខផង។

ដូច្នេះហើយ ទ្រង់ប្រតិស្ឋានក្នុងសកទាមិផល ទ្រង់បានស្ដាប់ធម្មបាលជាតកហើយ ទ្រង់ប្រតិស្ឋានក្នុងអនាគាមិផល ក្នុងមរណសម័យ ស្ដេចផ្ទំលើព្រះបន្ទំដ៏មានសិរី ខាងក្រោមនៃស្វេតច្ឆត្រនោះឯង ទើបទ្រង់សម្រេចព្រះអរហត្ត ។ កិច្ចដែល

ត្រូវឧស្សាហ៍ប្រកបព្យាយាម ក្នុងព្រៃមិនមានដល់ព្រះរាជា។

*(ស្រង់ចាកវិន័យខន្ធកៈនិងបរិវារៈ)*

ព្រះគាថាដែលទ្រង់សម្ដែងនឹងសហម្បតីព្រហ្ម

**អបារុតា តេ អមតស្ស ទ្វារា**

**យេ សោតវន្តោ បមុញ្ចន្តុ សទ្ធំ**

**វិហឹសសញ្ញី បគុណំ ន ភាសឹ**

**ធម្មំ បណីតំ មនុជេសុ ព្រហ្មេ ។**

ទ្វារនៃព្រះនិព្វានទាំងនោះបើកហើយ សត្វទាំងឡាយណាមានសោតប្បសាទ សត្វទាំងឡាយនោះ ចូរបញ្ចេញនូវសទ្ធាចុះ ។ ម្នាលមហាព្រហ្ម តថាគតមានសេចក្ដីសម្គាល់ក្នុងការលំបាកបានជាមិនសម្ដែងធម៌ដ៏ឧត្ដម ។

*ព្រះអដ្ឋកថាព្រហ្មយាចនកថា*

ពីរបទថា **បរិវិតក្កោ ឧទបាទិ** សេចក្ដីថា សេចក្ដីរំពឹងនៃចិត្តនេះដែលព្រះពុទ្ធគ្រប់ព្រះអង្គ ទ្រង់ប្រព្រឹត្តមកជាអាចិណ្ណៈកើតឡើងដល់ព្រះមានព្រះភាគ លុះមបានទ្រង់គង់ក្រោមម្លប់ដើម

អជបាលនិគ្រោធប៉ុណ្ណោះ។ សួរថា ក៏ព្រោះហេតុអ្វីសេចក្តីរំពឹងនៃចិត្តនេះ ទើបកើតឡើងដល់ព្រះពុទ្ធគ្រប់ព្រះអង្គ ?

**ធម្មស្ស មហន្តភាវំ គរុភាវំភារិយភា វំ បច្ចវេក្ខណាយ ព្រហ្មុនា យាចិតេ ទេសេតុកាមតាយ ច** : ឆ្លើយថាព្រោះទ្រង់ពិចារណានូវភារៈនៃព្រះធម៌ជាគុណធំ ជាគុណដ៏លើសលប់ជារបស់ធ្ងន់ និង ព្រោះជាអ្នកប្រាថ្នានឹងទ្រង់សម្តែងតាមពាក្យដែលព្រហ្មទូលអារាធនា ។

**ជានន្តិ ហិ ពុទ្ធា ឯវំ បរិវិតក្កិតេ ព្រហ្មា អាគន្ត្វា ធម្មទេសនំ យាចិស្សតិ តតោ សត្តា ធម្មេ គារវំ ឧប្បាទេស្សន្តិ ព្រហ្មគរុកោ ហិ លោកសន្និវាសោតិ** : មែនពិត ព្រះពុទ្ធទាំងឡាយរមែងទ្រង់ជ្រាបថា កាលព្រះអង្គទ្រង់រំពឹងយ៉ាងនោះ ព្រហ្មនឹងមកទូលនិមន្តឱ្យសម្តែងធម៌ គ្រានោះសត្វទាំងឡាយនឹងកើតសេចក្តីគោរពក្នុងធម៌ ព្រោះថាលោកសន្និវាសគោរពព្រហ្ម ។សេចក្តីរំពឹងនេះកើតឡើងព្រោះហេតុ ២ ប្រការនេះ ដោយប្រការ ដូច្នេះឯង ។

ព្រះមានព្រះភាគទ្រង់សម្តែងគាថាទៅរកឧបកាជីវកថា

សព្វាភិភូ សព្វវិទូហមស្មិ សព្វេសុ ធម្មេសុ អនូបលិត្តោ
សព្វញ្ជហោ តណ្ហក្ខយេ វិមុត្តោ សយំ អភិញ្ញាយ
កមុទ្ទិសេយ្យំ ។

ន មេ អាចរិយោ អត្ថិ សទិសោ មេ ន វិជ្ជតិ
សទេវកស្មឹ លោកស្មឹ នត្ថិ មេ បដិបុគ្គលោ ។
អហញ្ហិ អរហា លោកេ អហំ សត្ថា អនុត្តរោ
ឯកោម្ហិ សម្មាសម្ពុទ្ធោ សីតិភូតោស្មិ និព្វុតោ ។
ធម្មចក្កំ បវត្តេតុំ គច្ឆាមិ កាសិនំ បុរំ
អន្ធភូតស្មឹ លោកស្មឹ អាហញ្ឆិំ អមតទុន្ទុភឹ ។

តថាគតជាអ្នកគ្របសង្កត់នូវតេភូមិកធម៌ទាំងអស់ត្រាស់ដឹងនូវចតុភូមិកធម៌ទាំងអស់ មិនប្រឡាក់ដោយកិលេស ក្នុងតេភូមិកធម៌ទាំងអស់ បានលះបោលនូវតេភូមិកធម៌ទាំងអស់ហើយ មានចិត្តផុតស្រឡះហើយព្រោះអស់ទៅនៃតណ្ហា ដឹងច្បាស់នូវចតុភូមិកធម៌ដោយខ្លួនឯង (ចាំបាច់) ចំពោះបុគ្គលណា ។ តថាគតមិនមានអាចារ្យទេ មិនមានបុគ្គលដទៃស្មើនឹងតថាគតឡើយក្នុងលោកនេះ ព្រមទាំងទេវលោក មិនមានបុគ្គលប្រៀប-

នឹងតថាគតបានឡើយ ។ ព្រោះថា តថាគតជាអរហន្ត ក្នុងលោក ជាសាស្តាខ្ពស់ផុត ជាអ្នកត្រាស់ដឹង តថាគតមានសេចក្តីត្រជាក់ មានភ្លើងកិលេសរលត់ហើយ ។

ឥឡូវតថាគតទៅកាន់ក្រុងនៃពួកជនអ្នកកាសី ដើម្បីនឹងម្តែង-ធម្មចក្ក (ដោយបំណងថា) តថាគតនឹងទូងនូវស្គរគឺអមតនិព្វាន ចំពោះសត្វលោក ដែលងងឹតគឺអវិជ្ជាកំពុងគ្របសង្កត់ ។

**យថា ខោ ត្វំ អាវុសោ បដិជានាសិ អរហសិ អនន្តជិនោតិ :** ឧបកាជីវក ក៏តបថា ម្នាលអាវុសោ អ្នកប្តេជ្ញាខ្លួនអ្នកថាយ៉ាងណាអ្នក (គួរដើម្បីបាននូវឈ្មោះ) ថា អនន្តជិនៈ។

ព្រះសម្មាសម្ពុទ្ធទ្រង់មានព្រះពុទ្ធដីកាទៀតថា:

**មាទិសា វេ ជិនា ហោន្តិ យេ បត្តា អាសវក្ខយំ**
**ជិតា មេ បាបកា ធម្មា តស្មាហមុបក ជិនោ ។**

ជនទាំងឡាយណាបានដល់នូវធម៌សម្រាប់ធ្វើអាសវៈឱ្យអស់ទៅ ជនទាំងឡាយនោះ ឈ្មោះជិនៈ(ជាអ្នកឈ្នះកិលេស)ប្រាកដដូចជាតថាគតដែរ តថាគតបានឈ្នះបាបធម៌ទាំងឡាយហើយ ម្នាល-

ឧបក: ព្រោះហេតុនោះទើបតថាគតបាននូវឈ្មោះថា ជិនៈអ្នកឈ្នះបាបធម៌ ។

**-ទុក្ខអរិយសច្ច:** ជាតិ គឺកិរិយាកកើតនៃខន្ធ ក៏ជាទុក្ខ ។

-ជរា គឺក្តីកិរិយាចាស់គ្រាំគ្រានៃខន្ធ ក៏ជាទុក្ខ(ព្យាធិគឺ ជំងឺតម្កាត់ទាំងឡាយ ក៏ជាទុក្ខ)។

-មរណ: គឺកិរិយាបែកធ្លាយនៃខន្ធក៏ជាទុក្ខ ។

-សេចក្តីសោកខ្សឹកខ្សួល ទុក្ខ ទោមនស្ស និងសេចក្តីចង្អៀតចង្អល់ចិត្តទាំងឡាយ ក៏ជាទុក្ខ ។

(*សោកបរិទេវទុក្ខទោមនស្សុបាយាស*)។

-កិរិយាប្រកបដោយសត្វនិងសង្ខារទាំងឡាយដែលមិនជាទីស្រឡាញ់ពេញចិត្តក៏ជាទុក្ខ ។(*អប្បិយេហិ សម្បយោគោ*)។

-កិរិយាព្រាត់ប្រាសចាកសត្វ និងសង្ខារទាំងឡាយដែលជាទីស្រឡាញ់ពេញចិត្ត ក៏ជាទុក្ខ ។(*បិយេហិ វិប្បយោគោ*)

-កាលបើចង់បាននូវវត្ថុណាមួយហើយ មិនបាននូវវត្ថុនោះ កិរិយាមិនបាននោះក៏ជា ទុក្ខ ។(*យម្បិច្ឆំ ន លភតិ តំ*)

-ឧបាទានក្ខន្ធទាំងឡាយប្រាំ ដែលតថាគតសម្តែងហើយ ដោយបំប្រួញ ក៏ជាទុក្ខ។

**-ទុក្ខសមុទយអរិយសច្ច** : តណ្ហាឯណា ដែលរមែង តាក់តែងនូវភពថ្មី ប្រកបដោយតម្រេក ដោយអំណាចនៃសេចក្តី ត្រេកត្រអាល មានកិរិយារីករាយក្នុងអារម្មណ៍នោះៗ ជាប្រក្រតី តណ្ហានោះ ដូចម្តេចខ្លះ? កាមតណ្ហា១ ភវតណ្ហា១ វិភវតណ្ហា១ ។

**-ទុក្ខនិរោធអរិយសច្ច** : កិរិយារលត់បង់នូវតណ្ហានោះ ដោយអរិយមគ្គមិនឱ្យមានសេសសល់ កិរិយាលះបង់នូវតណ្ហា នោះ កិរិយារលាស់ចោលនូវតណ្ហានោះ កិរិយារួចផុតចាក តណ្ហា នោះ កិរិយាមិនមានអាល័យក្នុងតណ្ហានោះឯណា កិរិយារំលត់ បង់តណ្ហាដោយអរិយមគ្គមិនឱ្យមានសេសសល់ជាដើមនេះឯង ។

**-ទុក្ខនិរោធគាមិនីបដិបទាអរិយសច្ច** : អដ្ឋង្គិកមគ្គដ៏ប្រសើរនេះឯង ដូចម្តេចខ្លះ ? គឺ សម្មាទិដ្ឋិ ប្រាជ្ញា យល់ឃើញត្រូវ១ សម្មាសង្កប្បៈ សេចក្តីត្រិះរិះត្រូវ១ សម្មាវាចា សម្តីត្រូវ ១ សម្មាកម្មន្តៈ ការងារត្រូវ១ សម្មាអាជីវៈ កិរិយា

ចិញ្ចឹមជីវិតត្រូវ១ សម្មាវាយាមះ ព្យាយាម ត្រូវ១ សម្មាសតិ សេចក្ដីរឭកត្រូវ១ សម្មាសមាធិ កិរិយាតម្កល់ចិត្តឱ្យនឹងត្រូវ១។

**-អត្ថរបស់អរិយសច្ច :**

**-ទុក្ខសច្ច មានអត្ថ ៤ យ៉ាងៈ**

១-**បីឡនដ្ឋោ** មានអត្ថថា បៀតបៀននូវសត្វ

២-**សង្ខតដ្ឋោ** មានអត្ថថា ជាធម៌គឺបច្ច័យទាំងឡាយមានតណ្ហាជាដើម ប្រជុំតាក់តែងឱ្យកើត ។

៣-**សន្តាបដ្ឋោ** មានអត្ថថា ញុំាងសត្វឱ្យក្ដៅក្រហាយអន្ទះអន្ទែង។

៤-**វិបរិណាមដ្ឋោ** មានអត្ថថា ចេះតែប្រែប្រួលមិន ឋិតថេរចិរកាល។

**-សមុទយសច្ច មានអត្ថ ៤ យ៉ាង :**

១-**អាយូហនដ្ឋោ** មានអត្ថថាកៀរគរសេចក្ដីទុក្ខឱ្យកើត ។

២-**និទានដ្ឋោ**មានអត្ថថានាំយកសេចក្ដីទុក្ខមកប្រគល់ឱ្យជាផលរបស់ខ្លួន ។

៣.**សំយោគដ្ឋោ** មានអត្ថថា ប្រកបទាក់ចងសត្វដោយសេចក្ដីទុក្ខ ។

៤.**បលិពោធដ្ឋោ** មានអត្ថថាធ្វើឱ្យសត្វរវល់រំខានចិត្តស្ទាក់ដំណើរមិនឱ្យបាននូវ មគ្គ និង ផល ។

**.និរោធអរិយសច្ច មានអត្ថ ៤ យ៉ាង :**

១.**និស្សរណដ្ឋោ** មានអត្ថថា រលាស់ចោលនូវឧបធិធម៌ដែលសម្រាប់ឱ្យសេចក្ដីទុក្ខចូលទៅអែបនែបនៅ ។

២.**វិវេកដ្ឋោ** មានអត្ថថា ស្ងប់ស្ងាត់ក្នុងសង្ខារទាំងពួង

៣.**អសង្ខតដ្ឋោ** មានអត្ថថា មិនមានធម៌ជាបច្ច័យប្រជុំតាក់តែងឱ្យកើត ។

៤.**អមតដ្ឋោ**មានអត្ថថាមិនចេះស្លាប់ព្រោះជារបស់ទៀង

**.មគ្គសច្ច មានអត្ថ ៤ យ៉ាង :**

១.**និយ្យានដ្ឋោ**មានអត្ថថាដឹកជញ្ជូនសត្វចេញពីវដ្តសង្សារ

២.**ហេតុដ្ឋោ** មានអត្ថថា ជាហេតុញ៉ាំងសត្វឱ្យដល់ព្រះនិព្វាន ។

៣-**ឧស្សន្នដ្ឋោ** មានអត្ថថា ឃើញនូវព្រះនិព្វាន ដែលជាធម៌ល្អិតសុខុមក្រៃលែង ។

៤-**អធិបតេយ្យដ្ឋោ** មានអត្ថថា ជាអធិបតីនៃសម្បយុត្តធម៌ក្នុងកិរិយាឃើញនូវព្រះនិព្វាន។

**ទុក្ខនាម វិសុទ្ធិមគ្គ**:សេចក្តីទុក្ខដែលប្រព្រឹត្តទៅក្នុងកាយឈ្មោះថាទុក្ខ ទុក្ខនោះ មានការបៀតបៀនកាយ ជាលក្ខណៈមានការធ្វើទោមនស្សដល់បុគ្គលអ្នកខ្វះបញ្ញាទាំងឡាយ ជារសមានការឈឺចាប់ផ្លូវកាយជាបច្ចុប្បដ្ឋាន ។

ចំណែកទុក្ខ ជាទុក្ខ គប្បីជ្រាបថា ព្រោះជាទុក្ខ (គឺជាតួទុក្ខ) និងព្រោះនាំសេចក្តីទុក្ខផ្លូវចិត្តមកឱ្យផង ព្រោះហេតុនោះ ទើបអ្នកប្រាជ្ញ ពោលពាក្យប្រព័ន្ធនេះទុកថា :

**បីឡេតិ កាយិកមិទំ ។ល។ ទុក្ខន្តិ វិសេសតោ វុត្តំ**

ទុក្ខផ្លូវកាយនេះ រមែងបៀតបៀន(កាយ)ដដែលហើយដដែល-ទៀត ហើយនៅធ្វើទុក្ខផ្លូវចិត្តឱ្យកើតផង ដោយហេតុណា ព្រោះហេតុនោះ ទុក្ខផ្លូវកាយនេះ ទើបព្រះមានព្រះភាគ ទ្រង់ត្រាស់ថាជាទុក្ខដោយពិសេស (គឺជាទុក្ខមួយបែបដោយឡែក) ។

**មហាដីកា ពណ៌នាទុក្ខនិទ្ទេសៈ** កាលធម៌ទាំងឡាយ មានជាតិជាដើមជាទុក្ខ ដោយជាទីតាំងនៃទុក្ខ និងជាទុក្ខពិត១ តាមសមគួរដល់ទុក្ខផ្លូវកាយនេះ ក៏ឈ្មោះថាទុក្ខដែលមានភាពពិសេសទាក់ទងជាមួយការបៀតបៀនដល់កាយ ព្រោះដូច្នោះ ទើបលោកអាចារ្យពោលថាព្រះសាស្តាទ្រង់ត្រាស់ថា ជាទុក្ខ ដោយពិសេស។

**ទោមនស្សក្នុងវិសុទ្ធិមគ្គ** : សេចក្តីទុក្ខដែលប្រព្រឹត្តទៅ ក្នុងចិត្តឈ្មោះថា ទោមនស្ស ទោមនស្សនោះមានការបៀតបៀនចិត្តជាលក្ខណៈ មានការចង្អៀតជារស មានការឈឺចាប់ផ្លូវចិត្តជាបច្ចុប្បដ្ឋាន ចំណែកទោមនស្សជាទុក្ខ គប្បីជ្រាបថាព្រោះជាទុក្ខទុក្ខ និងព្រោះនាំទុក្ខផ្លូវកាយមកឱ្យផងដែរ ។ ពិតណាស់មនុស្សទាំងឡាយដែលពេញដោយសេចក្តីទុក្ខក្នុងចិត្តហើយរមែងសោយទុក្ខមានប្រការផ្សេង១ដូចជារំសាយសក់ ស្រែកយំគក់ទ្រូងបោកខ្លួនទៅមកយកជើង (គងឡើងចុះ) ចាប់សស្ត្រា (ធ្វើបាបខ្លួនឯង) ផឹកថ្នាំពិស ចងក (លោត) ចូល (គំនរ) ភ្លើងព្រោះហេតុនោះទើបអ្នកប្រាជ្ញពោលពាក្យប្រព័ន្ធ ទុកថាៈ

**បីឡេតិ យតោ ចិត្តំ ។ល។ តតោ អាហុ** ទោមនស្ស រមែងបៀតបៀនចិត្ត និងនាំសេចក្តីលំបាកកាយមកឱ្យផងដោយហេតុណាព្រោះហេតុនោះ ទើបព្រះពុទ្ធទាំងឡាយ អ្នកប្រាសចាកទោមនស្ស ត្រាស់ទោមនស្ស ថាជាទុក្ខ។

**មហាដីកា** : ពាក្យថា មានការចង្អៀតចង្អល់ចិត្តជារស គឺមានការចង្អៀតចិត្ត ដោយប្រកបជាមួយព្យាបាទជាកិច្ច ។

ពាក្យថាបុគ្គលទាំងឡាយដល់ព្រមដោយទុក្ខផ្លូវចិត្តគឺ ដែលមានការព្រមព្រៀង ដោយទុក្ខដែលកើតតាមផ្លូវចិត្ត ។ បទថា **អាវដ្តន្តិ** ប្រែថាវិលមកខាងមុខគឺផ្តួលខ្លួនចុះបែរមុខទៅ ទិសណាក៏បង្វិលខ្លួនទៅទិសនោះតែម្យ៉ាង។ បទថា **វិវដ្តន្តិ** ប្រែថាវិលទៅក្នុងការផ្លាស់ប្តូរឥរិយាបថផ្សេងៗ ។ ពីរបទថា **ឧទ្ធំបាទំ បបតន្តិ** ប្រែថាដួលផ្ការពោះលើកជើងឡើងលើ ។ ពាក្យថាចាប់សស្ត្រា គឺនាំសស្ត្រាចូលទៅចាក់ និង ទម្លាយ សរីរៈរបស់ខ្លួន ។

**ឧបាយាស ក្នុងវិសុទ្ធិមគ្គ** : ទោសៈដែលជាសេចក្តីទុក្ខចិត្តយ៉ាងធ្ងន់បណ្តាលឡើងនៃបុគ្គលដែលត្រូវទុក្ខមានការវិនាសញាតិជាដើមពាល់ត្រូវនោះឯង ឈ្មោះថាឧបាយាសៈអាចារ្យមួយពួក

ពោលថាឧបាយាសជា (ចេតសិក) ធម៌មួយរាប់ចូលនៅក្នុងសង្ខារ-ក្ខន្ធ ឧបាយាសនោះមានការដុតរោលចិត្ត ជាលក្ខណៈ មានការតានតឹងជារស មានការព្រួយជា បច្ចុប្បដ្ឋាន ដែលថា ឧបាយាសជាទុក្ខ គប្បីជ្រាបថា ជាសង្ខារទុក្ខ ព្រោះដុតរោលចិត្ត និងព្រោះធ្វើរាងកាយឱ្យស្លេកស្លាំងផង ព្រោះហេតុនោះ ទើបអ្នកប្រាជ្ញពោលពាក្យប្រព័ន្ធនេះ ទុកថា: **ចិត្តស្ស ច បរិទហនា** ។ល។ **ឧុក្ខោ តតោ ឧុត្តោ** ឧបាយាស រមែងញ៉ាំទុក្ខ ណាឱ្យកើតឡើង ទុក្ខនោះចាត់ថា មានប្រមាណក្រៃលែង ព្រោះដុតរោលចិត្តផង ធ្វើកាយឱ្យស្គាំងស្គម ហេតុនោះ ទើបឧបាយាស ព្រះមានព្រះ-ភាគត្រាស់ថាជាទុក្ខ ។

-*ប្រៀបធៀប សោក: បរិទេវ:* ឧបាយាស: ក្នុងសោក: បរិទេវ:និងឧបាយាស:នេះលោកគប្បីឃើញដូចការដែល(ទឹក) ក្ដៅនៅក្នុងភាជនៈដោយភ្លើងឧណ្ហៗ បរិទេវ: គប្បីឃើញដូចការ (ហៀរ) ចេញក្រៅនៃភាជនៈទឹកដែលក្ដៅដោយភ្លើងខ្លាំង ឧបាយា-ស:គប្បីឃើញដូចការក្ដៅ រហូតស្ងួតទៅក្នុងភាជនៈនោះឯង

នៃទឹកដែលសល់អំពី(ហៀរ)ចេញខាងក្រៅ ហើយមិនគ្រប់គ្រាន់ ហើយហៀរចេញទៀត ។

**អប្បិយសម្បយោគទុក្ខ** : ការរួមចូលជាមួយសត្វ និងសង្ខារទាំងឡាយដែលមិនពេញចិត្តឈ្មោះថាអប្បិយសម្បយោគ ។ នោះមានការជួបប្រសព្វជាមួយសត្វ និងសង្ខារដែលមិនប្រាថ្នាជាលក្ខណៈ មានការចង្អៀតចិត្តជារសមានការកើតអនត្ថជាបច្ចុប្បដ្ឋាន ចំណែកអប្បិយសម្បយោគដែលជាទុក្ខ គប្បីជ្រាបថាព្រោះជាទីតាំងនៃទុក្ខ ហេតុនោះទើបអ្នកប្រាជ្ញពោលពាក្យប្រព័ន្ធនេះទុកថា: **ឥស្វា អប្បិយេ ទុក្ខំ ។ល។ អប្បិយេហិ សមាគមោ** ព្រោះជួបមនុស្សដែលស្អប់ ដំបូងទុក្ខក៏មានឡើងក្នុងចិត្ត តទៅទុក្ខដែលកើតអំពីការប្រទូស្ត (ដោយកាយនិងវាចា) ក៏មានឡើងក្នុងកាយ (នៃបុគ្គល) ក្នុងលោកនេះដោយហេតុណាព្រោះហេតុនោះ ការជួបប្រសព្វ វត្ថុដែលស្អប់នោះ គប្បីជ្រាបថាព្រះមហាឥសីត្រាស់ថាជាទុក្ខ ព្រោះថាជាទីតាំងនៃទុក្ខទាំង២ (គឺទាំងតាមផ្លូវចិត្ត និង តាមផ្លូវកាយ)។

**បិយវិប្បយោគទុក្ខ** ៖ ការព្រាត់ប្រាសចាកសត្វ និង សង្ខារទាំងឡាយដែលជាទីស្រឡាញ់ ឈ្មោះថា បិយវិប្បយោគ ។ នោះមានការព្រាត់ប្រាសចាកវត្ថុដែលពេញចិត្តជាលក្ខណៈ មានការញុំាងសេចក្ដីសោកឱ្យកើតឡើងជារស មានការវិនាសទៅជាបច្ចុប្បដ្ឋាន ចំណែកបិយវិប្បយោគទុក្ខ គប្បីជ្រាបថា ព្រោះជាទីតាំងនៃទុក្ខ គឺសេចក្ដីសោក ហេតុនោះទើបអ្នកប្រាជ្ញពោលពាក្យប្រព័ន្ធនេះទុកថា ៖

**ញាតិធនាទិវិយោគោ។បេ។មតោបិយវិប្បយោគោ** មនុស្សល្ងង់ទាំងឡាយដែលពេញដោយសរ គឺសោកព្រោះព្រាត់-ប្រាសចាកសត្វនិងសង្ខារដែលជាទីស្រឡាញ់ មានញាតិនិងទ្រព្យជាដើមរមែងឈឺចាប់ (ចិត្ត) ហេតុណា ព្រោះហេតុនោះទើបបិយវិប្បយាគនេះ ព្រះមានព្រះភាគត្រាស់ថាជាទុក្ខ ។

**ឥច្ឆិតាលាភទុក្ខ** ៖ ក្នុងពាក្យថា **យម្បិច្ឆំ ន លភតិ**...នេះមានវិនិច្ឆ័យថា ការប្រាថ្នាក្នុង (អលព្ភនេយ្យវត្ថុ) វត្ថុដែលមិនមានផ្លូវនឹងបានទាំងឡាយ ដូចប្រាថ្នាថា ឱហ្ន៎ ! យើងទាំងឡាយនឹងមិនជាអ្នកមានការកើតជាធម្មតាជាដើមនុ៎ះឯងដែលព្រះសាស្ដា

ត្រាស់ថា **យម្បិច្ឆំ ន លភតិ តម្បិ ទុក្ខំ** ប្រាថ្នា របស់ណា តែមិនបានរបស់នោះឯណា ការមិនបានវត្ថុដែលជាទីប្រាថ្នានោះក៏ជាទុក្ខ ដូច្នេះ ការប្រាថ្នានោះមានការត្រូវការវត្ថុដែលមិនមានផ្លូវនឹងបានជាលក្ខណៈ មានការស្វែងរកវត្ថុដែលមិនមានផ្លូវនឹងបាននោះជារស មានការមិនបានវត្ថុទាំងនោះជាបច្ចុប្បដ្ឋាន ចំណែកការប្រាថ្នានោះជាទុក្ខ គប្បីជ្រាបថា ព្រោះជាទីតាំងនៃទុក្ខហេតុនោះទើបអ្នកប្រាជ្ញពោលពាក្យប្រព័ន្ធទុកថា :

**តំ តំ បត្ថយមានានំ ។បេ។ឥច្ឆិតាលាភសម្ភវំ** ទុក្ខដែលប្រកបទៅដោយការអាក់អន់ចិត្តណា កើតដល់សត្វទាំងឡាយក្នុងលោកនេះ ព្រោះកាលសត្វទាំងឡាយប្រាថ្នាវត្ថុនោះ ៗនៅតែមិនបានវត្ថុនោះៗ ការប្រាថ្នានូវវត្ថុដែលមិនមានផ្លូវនឹងបានទាំងឡាយនោះ ឯងជាហេតុរបស់ទុក្ខនោះ ដោយហេតុណា ព្រោះហេតុនោះ ទើបព្រះជិនស្រីត្រាស់ថាការមិនបានវត្ថុដែលប្រាថ្នា ថាជាទុក្ខ ។

**បញ្ចុបាទានក្ខន្ធទុក្ខ** : ចំណែកក្នុងពាក្យថា ដោយសង្ខេបឧបាទានក្ខន្ធ ៥ ជាទុក្ខនេះមានវិនិច្ឆ័យថាទុក្ខតាំងអំពីជាតិទុក្ខមក

យ៉ាងណាដែលព្រះមានព្រះភាគជាម្ចាស់ទ្រទ្រង់តាទិគុណ ត្រាស់ទុកក្នុងទុក្ខនិទ្ទេសនេះហើយក្តី ទុក្ខណាដែលមិនទាន់បានត្រាស់ទុកក្នុងទុក្ខនិទ្ទេសនេះក្តី ទុក្ខទាំងពួងនោះវៀរឧបាទានក្ខន្ធ ៥ នោះចេញក៏គ្មាន ដោយហេតុណា ព្រោះហេតុនោះឧបាទានក្ខន្ធទាំងឡាយនេះព្រះមហាឥសីអ្នក បង្ហាញទីបំផុតទុក្ខទើបត្រាស់ថាជាទុក្ខដោយសង្ខេប ។

ពិតហើយទុក្ខធម៌ទាំងឡាយ មានទុក្ខជាដើមដែលបៀតបៀនឧបាទានក្ខន្ធទាំង៥នេះឯង ដោយប្រការផ្សេងៗ ដូចភ្លើងបៀតបៀនពូជគឺឧស ដូចគ្រឿងប្រហារបៀតបៀនក្តារបាំយ ដូច-សត្វល្អិតទាំងឡាយមានរបោម និង មូសជាដើមបៀតបៀនគោ ដូចមនុស្សច្រូតស្រូវទាំងឡាយបៀតបៀនស្រែ ដូចពួកចោរប្លន់អ្នកស្រុក បៀតបៀនអ្នកស្រុក ក៏កើតត្រង់ឧបាទានក្ខន្ធទាំងឡាយនេះឯង ដូចស្មៅនិងវល្លិ៍ជាដើម កើតត្រង់ផែនដី ដូចផ្កាផ្លែនិងពន្លក កើតត្រង់ដើមឈើទាំងឡាយដូច្នោះ ។

មួយ៉ាងទៀតទុក្ខក្នុងខាងដើម របស់ឧបាទានក្ខន្ធទាំងឡាយក៏គឺជាតិទុក្ខ ក្នុងកណ្តាល គឺជរាទុក្ខ ក្នុងទីបំផុត គឺមរណទុក្ខ

គឺការក្តៅចិត្ត ព្រោះប៉ះខ្ទប់មរណន្តិកទុក្ខ (ទុក្ខកាលជិតស្លាប់) ជាសោក ទុក្ខគឺការខ្សឹកខ្សួល ព្រោះទ្រាំចំពោះទុក្ខនោះមិនបាន ជាបរិទេវៈតទៅ ទុក្ខគឺការឈឺកាយ ព្រោះប្រសព្វ អនិដ្ឋផោដ្ឋព្វៈ ពោលគឺការកម្រើកនៃធាតុជាទុក្ខ ទុក្ខគឺការឈឺចិត្ត ព្រោះ-កើតបដិឃៈក្នុងទុក្ខកាយនោះ នៃបុថុជ្ជនទាំងឡាយអ្នកដែល-ត្រូវសេចក្តីឈឺចាប់កាយនោះបៀតបៀន ជាទោមនស្សទុក្ខគឺការអន្ទះអន្ទែងរបស់បុគ្គលទាំងឡាយ អ្នកដែលមានសេចក្តីសោកសង្រេង ដែលជាការបន្ថែមច្រើនឡើង នៃទុក្ខដែលពោលហើយមានសោកជាដើមធ្វើឱ្យកើតឡើង ជាឧបាយាស ទុក្ខគឺការមិនសមប្រាថ្នារបស់បុគ្គលទាំងឡាយ អ្នកបានទទួលការខុសសង្ឃឹមជាឥច្ឆិតាលាភ ព្រោះហេតុនោះឧបាទានក្ខន្ធទាំងឡាយ-នោះឯង កាលដែលពិចារណាមើល ដោយប្រការផ្សេងៗដូចពោលមកនេះ រមែងជាទុក្ខពិតមែន ។

បុគ្គលណាមួយ មិនអាចពោលទុក្ខតែម្យ៉ាងនេះ ដែលព្រះមានព្រះភាគត្រាស់សម្តែង ទុកមិនឱ្យសេសសល់ ដោយកាលសូម្បីច្រើនកប្បបាន ព្រោះហេតុនោះ ព្រះសាស្តាជាម្ចាស់ ទ្រង់

សម្តែងដោយបង្រួញទុក្ខទាំងពួងនោះចូលក្នុងឧបាទានក្ខន្ធ៥ គ្រប់យ៉ាង ដូចបង្រួញទឹកទន្លេទាំងអស់ ជាតំណក់ទឹកមួយតំណក់ ទើបបានត្រាស់ថា ដោយបង្រួញឧបាទានក្ខន្ធ៥ ជាទុក្ខដូច្នេះ ។

**ទុក្ខសមុទយនិទ្ទេស** : ចំណែកក្នុងទុក្ខសមុទយនិទ្ទេស មានវិនិច្ឆ័យថា ពាក្យថា **យាយំ តណ្ហាយ** មានសេចក្តីថា តណ្ហានេះ ពាក្យថា **ពោនោព្ភវិកា** មានសេចក្តីថា កាលសាងភពថ្មីទៀត ឈ្មោះថា **បុនព្ភវៈ** ។ ការសាងភពថ្មីទៀតជាប្រក្រតីរបស់តណ្ហានោះ ហេតុនេះ ទើបតណ្ហានោះ ឈ្មោះថា **ពោនោព្ភវិកា** (មានការសាងភពថ្មីទៀតជាប្រក្រតី) តណ្ហា-នោះឈ្មោះថា នន្ទិរាគសហគតា ព្រោះទៅព្រមជាមួយនន្ទិរាគៈ អធិប្បាយថា ដល់នូវភាពជាមួយគ្នានឹងនន្ទរាគៈ ដោយអត្ថ ។ ពាក្យថា **តត្រតត្រាភិនន្ទិនី** មានសេចក្តីថា តណ្ហាកើតក្នុងអត្តភាពណាមួយ ក៏មានប្រក្រតីត្រេកអរទៅក្នុងអត្តភាពនោះៗ ។ ពាក្យថា **សេយ្យថីទំ** ជានិបាត នេះជាអត្ថរបស់និបាតនោះ គឺបើគេសួរថា តណ្ហានោះដូចម្តេច ធម៌ទាំងឡាយនេះ គឺកាមតណ្ហា ភវតណ្ហា វិភវតណ្ហា នឹងមានច្បាស់ក្នុងបដិច្ចសមុប្បាទនិទ្ទេស

ចំណែកក្នុងទីនេះ តណ្ហាទាំង៣នេះគប្បីជ្រាបថា ព្រះសាស្តាទ្រង់បញ្ចូលជាមួយគ្នា ត្រាស់ថា ជាទុក្ខសមុទយអរិយសច្ចដោយអត្ថថា ជាហេតុញ៉ាំងទុក្ខសច្ចឱ្យកើត ។

**ទុក្ខនិរោធនិទ្ទេស** : ក្នុងទុក្ខនិរោធនិទ្ទេស មានវិនិច្ឆ័យថា ដោយន័យថា **យោ តស្សាយេវ តណ្ហាយ** ជាដើមជាការត្រាស់ការរលត់នៃសមុទ័យ។ បើសួរថា ហេតុអ្វីទើបត្រាស់ ការរលត់នៃសមុទ័យ? គប្បីមានពាក្យឆ្លើយថា ការរលត់នៃទុក្ខរមែងមាន ព្រោះការរលត់នៃសមុទ័យ មែនពិត ទុក្ខរមែងរលត់ ព្រោះការរលត់នៃសមុទ័យ មិនមែនហេតុ ដទៃឡើយ ហេតុនោះទើបត្រាស់ទុក ក្នុងធម្មបទថា :

ដើមឈើ កាលគល់នៅមាំមិនមានឧបទ្រវៈ សូម្បីត្រូវកាត់(ចំណែកខាងលើ)ហើយ ក៏ដុះបានទៀត យ៉ាងណាក្តី សូម្បីទុក្ខនេះក៏ដូច្នោះ កាលតណ្ហានុស័យ ដែលមិនទាន់បានដកចោល ក៏កើតបានទៀតទៅ ។

ព្រោះហេតុដែលទុក្ខរមែងរលត់ ព្រោះការរលត់ទៅនៃសមុទ័យដូចពោលមកនោះ ឯងព្រះមានព្រះភាគកាលទ្រង់ត្រាស់

សម្ដែងការរលត់ ទើបទ្រង់សម្ដែងដោយការរលត់នៃសមុទ័យ-នោះឯង ។ ព្រះតថាគតទាំងឡាយ មានការប្រព្រឹត្តស្មើដូចសីហៈ លោកនឹងរលត់ទុក្ខ និង សំដែងការរលត់នៃទុក្ខ រមែងបដិបត្តិក្នុងហេតុ មិនបានបដិបត្តិក្នុងផល ចំណែកតិរ្ថិយទាំងឡាយ មានការប្រព្រឹត្តស្មើដូចសុនខ គេនឹងរលត់ទុក្ខ និងសម្ដែងការរលត់នៃទុក្ខ រមែងបដិបត្តិក្នុងផល ដោយការសម្ដែងអត្តកិលមថានុយោគជាដើម មិនមែនបដិបត្តិក្នុងហេតុទេ ដោយប្រការដូច្នេះ ។

ប្រយោជន៍បំណងនៃការសម្ដែងការរលត់នៃទុក្ខដោយ អំណាចការរលត់នៃសមុទយៈ បណ្ឌិតគប្បីជ្រាបដោយន័យ ដូច្នេះ ។

**ទុក្ខនិរោធគាមិនីបដិបទានិទ្ទេស** : ធម៌ គឺអរិយមគ្គ ៨ ដែលត្រាស់ទុកក្នុងនិទ្ទេស នៃទុក្ខនិរោធគាមិនីបដិបទា នេះជាក់ច្បាស់ហើយ ក្នុងខន្ធនិទ្ទេសក៏ពិត តែក្នុងទីនេះ ខ្ញុំនឹងពោលដើម្បីឱ្យជ្រាបសេចក្ដីប្លែកគ្នានៃធម៌ទាំង ៨ នោះដែលប្រព្រឹត្តទៅក្នុងខណៈជាមួយគ្នា ។

**សម្មាទិដ្ឋិ** : ពិតហើយ ពោលដោយសង្ខេប បញ្ញាចក្ខុដែលមានព្រះនិព្វានជាអារម្មណ៍ ដកអវិជ្ជានុស័យឡើងបាននៃព្រះ-

យោគីអ្នកបដិបត្តិដើម្បីចាក់ធ្លុះនូវសច្ចៈ៤នោះឯង ឈ្មោះថា **សម្មាទិដ្ឋិ** នោះមានការឃើញប្រពៃ ជាលក្ខណៈ មានការប្រកាសសេចក្ដីពិតជារស មានការទម្លាយភាពងងឹត គឺអវិជ្ជាចេញបាន ជាបច្ចុប្បដ្ឋាន ។

**សម្មាសង្កប្ប** : ការលើកចិត្តឡើងឆ្ពោះកាន់ផ្លូវទៅព្រះនិព្វាន ដែលសម្បយុត្តដោយសម្មាទិដ្ឋិនោះ កម្ចាត់មិច្ឆាសង្កប្បៈចេញបាននៃព្រះយោគី អ្នកមានទិដ្ឋិដែលដល់ព្រមហើយយ៉ាងនេះ ឈ្មោះថា សម្មាសង្កប្បៈ ។ សម្មាសង្កប្បៈនោះ មានការលើកចិត្តឡើងត្រូវផ្លូវ ជាលក្ខណៈ មានអប្បនា (ការត្រិះរិះត្រង់ក្នុងផ្លូវ) ជារស មានការលះមិច្ឆាសង្កប្បៈបាន ជាបច្ចុប្បដ្ឋាន ។

**សម្មាវាចា** : ការវៀរចាកមិច្ឆាវាចាដែលសម្បយុត្ត ដោយសម្មាសង្កប្បៈនោះឯង ដកវចីទុច្ចរិតឡើងចោលបាន នៃព្រះយោគីអ្នកឃើញ (ដោយសម្មាទិដ្ឋិ) និងត្រិះរិះ (ដោយសម្មាសង្កប្បៈ)យ៉ាងនោះឈ្មោះថាសម្មាវាចាៗនោះមានការកំណត់យក (គឺប្រមូលសម្បយុត្តធម៌ទុក) ជាលក្ខណៈ មានការវៀរចាក ជារស មានការលះមិច្ឆាវាចា ជាបច្ចុប្បដ្ឋាន ។

**សម្មាកម្មន្ត** : ការវៀរចាកកាយទុច្ចរិត មានបាណាតិបាត ជាដើម ដែលសម្បយុត្តដោយសម្មាវាចានោះឯង កាត់ផ្ដាច់ មិច្ឆាកម្មន្តៈបាននៃព្រះយោគីអ្នកវៀរចាក ( ដោយសម្មាវាចា ) យ៉ាងនោះ ឈ្មោះថាសម្មាកម្មន្តៈៗ នោះមានការទ្រ (សម្បយុត្ត ) ទុកជាលក្ខណៈ មានការវៀរចាកជារស មានការលះមិច្ឆា-កម្មន្តៈបានជាបច្ចុប្បដ្ឋាន ។

**សម្មាអាជីវ** : ចំណែកការវៀរចាកមិច្ឆាអាជីវៈដែលសម្ប-យុត្តដោយការលះបង់ ដែលជាសភាពល្អស្អាតនៃសម្មាវាចា និង សម្មាកម្មន្តៈនោះ ចូលទៅកាត់ផ្ដាច់បាននូវអនេសនាមានការ ឆបោកជាដើម នៃព្រះយោគីណា ការវៀរចាកនោះឈ្មោះថា សម្មាអាជីវៈ ៗនោះ មានភាពស្អាត(នៃអាជីវៈ)ជាលក្ខណៈ មាន ការញ៉ាំងអាជីវៈដ៏ប្រពៃតាមធម៌ឱ្យប្រព្រឹត្តទៅជារស មានការលះ-បង់មិច្ឆាអាជីវៈបានជាបច្ចុប្បដ្ឋាន ។

**សម្មាវាយាម** : លំដាប់នោះ វីរិយារម្ភៈដែលអនុរូបដល់ សម្មាអាជីវៈនោះ សម្បយុត្តដោយសម្មាអាជីវៈនោះឯង កាត់-បង់កោសជ្ជៈចោលបាននៃព្រះយោគីនោះ អ្នកតាំងមាំហើយ

ក្នុងភូមិនៃសីល ពោលគឺសម្មាវាចា សម្មាកម្មន្តៈ សម្មាអាជីវៈ នោះឯណា វិរិយារម្ភៈនោះ ឈ្មោះថា សម្មាវាយាមៈ ៗ នោះ មានការផ្គងចិត្តទុកជាលក្ខណៈ មានសម្មប្បធាន ៤ ដែលញុំាង អកុសលធម៌ដែលនៅមិនទាន់កើតមិនឱ្យកើតឡើងជាដើមជារស មានការលះ បង់មិច្ឆាវាយាមៈបាន ជាបច្ចុប្បដ្ឋាន ។

**សម្មាសតិ** : ការមិនភ្លេចនៃចិត្តដែលសម្បយុត្តដោយសម្មា-វាយាមៈនោះឯង កម្ចាត់មិច្ឆាសតិចេញបាន នៃព្រះយោគីនោះ អ្នកព្យាយាមយ៉ាងនោះថា ឈ្មោះថា សម្មាសតិ ៗនោះមាន ការតាំងសតិទុកមាំជាលក្ខណៈ មានការមិនភ្លេចជារស មាន-ការលះមិច្ឆាសតិបាន ជាបច្ចុប្បដ្ឋាន ។

**សម្មាសមាធិ** : ឯកគ្គតានៃចិត្តដែលសម្បយុត្តដោយសម្មា-សតិនោះឯង ទម្លាយមិច្ឆាសមាធិចោលបាន នៃព្រះយោគី-នោះអ្នកមានចិត្តដែលសតិថ្នាក់កំពូលនៅរក្សាយ៉ាងនោះឈ្មោះថា សម្មាសមាធិៗនោះមានការមិនរសាត់ទៅនៃចិត្ត ជាលក្ខណៈ មានការតាំងចិត្តទុកមាំ ជារស មានការលះមិច្ឆាសមាធិបាន ជាបច្ចុប្បដ្ឋាន ។

*(នេះជាន័យក្នុងទុក្ខនិរោធគាមិនីបដិបទានិទ្ទេស)*

*(ស្រង់ចាកគម្ពីរវិសុទ្ធិមគ្គ បញ្ញានិទ្ទេសភាគទី១ ច្បាប់ប្រែជាខេមរភាសា)*

**បិដកលេខ ៤៤ ទំព័រ ២៣៨ ថេរសូត្រ**

ម្នាលភិក្ខុទាំងឡាយ ភិក្ខុជាថេរៈ ប្រកបដោយធម៌ ៥ យ៉ាង ឈ្មោះថា ជាអ្នកប្រតិបត្តិមិនបានជាគុណដល់ជនច្រើន មិនបានសុខដល់ជនច្រើន មិនជាប្រយោជន៍ដល់ជនច្រើន មិនជាគុណ ជាទុក្ខដល់ទេវតានិងមនុស្សទាំងឡាយ ។ ធម៌ ៥ យ៉ាង តើអ្វីខ្លះ ។ គឺ ភិក្ខុជាថេរៈ ដឹងរាត្រី បួសយូរ១ មានឈ្មោះល្បីល្បាញ មានយសមានបរិវារច្រើន ទាំងគ្រហស្ថ ទាំងបព្វជិត១ សម្បូរដោយ ចីវរ បិណ្ឌបាត សេនាសនៈ និង គិលានប្បច្ច័យភេសជ្ជបរិក្ខារ១ ជាអ្នកដឹងឮច្រើន ចាំរបស់ដែលឮហើយ ចាំលែងភ្លេចនូវរបស់ដែលឮហើយ។ល។ចាក់ធ្លុះល្អដោយប្រាជ្ញា១ តែជាមិច្ឆាទិដ្ឋិ មានសេចក្តីយល់ដ៏វិបរិត១ ភិក្ខុនោះញុំាងជនច្រើនឱ្យឃ្លាតចាកព្រះសទ្ធម្ម ឱ្យតម្កល់នៅក្នុងអសទ្ធម្ម ភិក្ខុដទៃដល់នូវទិដ្ឋានុគតិ របស់ភិក្ខុនោះថា ភិក្ខុនេះជាថេរៈ បួសយូរខ្លះ ដល់នូវទិដ្ឋានុគតិរបស់ភិក្ខុនោះថា ភិក្ខុនេះជាថេរៈ គេដឹងស្គាល់

ច្រើនជាអ្នកមានយស មានបរិវារច្រើន ទាំងគ្រហស្ថទាំងបព្វជិតខ្លះ ដល់នូវទិដ្ឋានុគតិរបស់ភិក្ខុនោះថា ភិក្ខុនេះជាថេរៈសម្បូរដោយ ចីវរបិណ្ឌបាតសេនាសនៈ និងគិលានប្បច្ច័យភេសជ្ជបរិក្ខារខ្លះ ដល់នូវទិដ្ឋានុគតិរបស់ភិក្ខុ នោះថា ភិក្ខុនេះជាថេរៈជាអ្នកដឹងឮច្រើន ចាំរបស់ដែលឮហើយ ចាំលែងភ្លេចនូវរបស់ដែលឮហើយខ្លះ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុជាថេរៈប្រកបដោយធម៌ ៥ យ៉ាងនេះឯង ឈ្មោះថាប្រតិបត្តិ ដើម្បីមិនបានជាគុណដល់ជនច្រើន មិនបានសុខដល់ជនច្រើន មិនជាប្រយោជន៍ដល់ជនច្រើន មិនជាគុណទេ ជាទុក្ខដល់ទេវតានិងមនុស្សទាំងឡាយ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុជាថេរៈដែលប្រកបដោយធម៌ ៥ យ៉ាង ជាអ្នកប្រតិបត្តិដើម្បីជាគុណដល់ជនច្រើន ដើម្បីសេចក្ដីសុខដល់ជនច្រើន ដើម្បីជាប្រយោជន៍ដល់ជនច្រើន ដើម្បីជាគុណនិងសេចក្ដីសុខដល់ទេវតានិង មនុស្សទាំងឡាយ ។ ធម៌ ៥ យ៉ាង តើអ្វីខ្លះ ។ គឺភិក្ខុជាថេរៈ ដឹងរាត្រីបួសយូរ១ មានឈ្មោះល្បីល្បាញ មានយស មានជនជាបរិវារ-ច្រើន ទាំងគ្រហស្ថ ទាំងបព្វជិត១ ជាអ្នកសម្បូរដោយ ចីវរ

បិណ្ឌបាត សេនាសនៈ និង គិលានប្បច្ច័យភេសជ្ជបរិក្ខារ១ ជាអ្នកដឹងឮច្រើន ចាំរបស់ដែលឮហើយ ចាំលែងភ្លេចនូវរបស់ដែលឮហើយ ។ល។ ចាក់ធ្លុះដោយប្រាជ្ញា១ ជាសម្មាទិដ្ឋិ មានសេចក្ដីយល់មិនវិបរិត១ ភិក្ខុនោះញុំាងជនច្រើនឱ្យឃ្លាតចាកអសទ្ធម្ម ឱ្យតម្កល់នៅក្នុងព្រះសទ្ធម្ម ពួកភិក្ខុដទៃដល់នូវទិដ្ឋានុគតិរបស់ភិក្ខុនោះថា ភិក្ខុនេះជាថេរៈ ដឹងរាត្រីបួសយូរខ្លះ ដល់នូវទិដ្ឋានុគតិរបស់ភិក្ខុនោះថា ភិក្ខុនេះជាថេរៈ គេដឹងស្គាល់ច្រើន មានយស មានជនជាបរិវារច្រើន ទាំងគ្រហស្ថទាំងបព្វជិតខ្លះ ដល់នូវទិដ្ឋានុគតិរបស់ភិក្ខុនោះថា ភិក្ខុនេះជាថេរៈ ជាអ្នកសម្បូរដោយ ចីវរ បិណ្ឌបាត សេនាសនៈ និង គិលានប្បច្ច័យភេសជ្ជបរិក្ខារខ្លះ ដល់នូវទិដ្ឋានុគតិ របស់ភិក្ខុនោះថា ភិក្ខុនេះជាថេរៈ ជាអ្នកដឹងឮច្រើន ចាំរបស់ដែលឮហើយចាំមិនភ្លេចនូវរបស់ដែលឮហើយខ្លះ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុជាថេរៈប្រកបដោយធម៌៥យ៉ាងនេះឯង ឈ្មោះថាប្រតិបត្តិដើម្បីជាគុណដល់ជនច្រើន ដើម្បីសេចក្ដីសុខ ដល់ជនច្រើន

**ដើម្បីជាប្រយោជន៍ ដល់ជនច្រើន ដើម្បីជាគុណនិង សេចក្តីសុខដល់ទេវតា និង មនុស្សទាំងឡាយ ។**

សេចក្តីប៉ុណ្ណោះដែលខ្ញុំព្រះករុណា អារាធនាមកអំពីគម្ពីរព្រះត្រៃបិដកនិងមេរៀនខ្លះៗនៅវត្តសំពៅមាស និងវត្តឧណ្ណាលោមទាំងថ្មីៗនេះទាំងដែលលោកគ្រូ បង្រៀនយូរហើយក៏មាន តាមពិតមេរៀននេះវត្តឧណ្ណាលោម និងវត្តសំពៅមាស ឆ្នាំនេះ *(ព.ស.២៥៥៥-៥៦)* ក៏មាននៅក្នុងសៀវភៅជំនួយសតិភាគទី១៧ដោយច្រើនហើយដែរ តែខ្ញុំ-ព្រះករុណាមានសេចក្តីជ្រះថ្លានឹងសរសេរ ព្រោះបានសិក្សាទៀងទាត់មិនដែល ឈប់ក្នុងឆ្នាំនេះ ។

*-តទៅនេះសូមធម្មញ្ញាតិធម្មមិត្តសិក្សានូវកងធមិខ្លះៗ ដែល ធ្លាប់បានស្តាប់បានសិក្សា ហើយ ដូចយ៉ាង វិជ្ជា ៣ វិជ្ជា ៨ ចរណៈ ១៥ សញ្ញា ១០ អានិសង្សមេត្តា ១១យ៉ាង ជាដើមៈ*

**អធិបតេយ្យ ៣ : អត្តាធិបតេយ្យ** ការមានខ្លួនជាធំ ១**លោ-កាធិបតេយ្យ** ការមានលោកជាធំ ១ **ធម្មាធិបតេយ្យ** ការមានធម៌ជាធំ ១ ។

**អភិសង្ខារ ៣ :** **បុញ្ញាភិសង្ខារ ១ អបុញ្ញាភិសង្ខារ១ អនេ-ញ្ជាភិសង្ខារ ១ ។**

**ទេវតា៣ពួក :សម្មតិទេព ១ ឧបបត្តិទេព ១ វិសុទ្ធិទេព១ ។**

**បាដិហារ្យ ៣ :**ឥទ្ធិប្បាដិហារ្យ១ អាណាទេសនាបាដិហារ្យ ១ អនុសាសនីបាដិហារ្យ ១ ។

**វដ្ដ: ៣ យ៉ាង** : កិលេសវដ្ដ:១ កម្មវដ្ដ:១ វិបាកវដ្ដ:១ ។

**វិជ្ជា ៣** :បុព្វេនិវាសានុស្សតិញ្ញាណ១ ចុតូបបាតញ្ញាណ១ អាសវក្ខយញ្ញាណ១ ។

**វិមោក្ខ ៣** : សុញ្ញតវិមោក្ខ ១ អនិមិត្តវិមោក្ខ ១ អប្បណិ-ហិតវិមោក្ខ១ ។

**កិច្ចក្នុងអរិយសច្ច៤យ៉ាង** : បរិញ្ញាកិច្ច ១ បហានកិច្ច ១ សច្ឆិកា-តព្វកិច្ច ១ ភាវេតព្វកិច្ច ១ ។

**បុគ្គល ៤ ពួក** : ឧគ្ឃដិតញ្ញូ ១ វិបច្ចិតញ្ញូ ១ នេយ្យ: ១ បទបរម: ១ ។

**បដិបទា ៤** : ទុក្ខា បដិបទា ទន្ធាភិញ្ញា ១ ទុក្ខា បដិបទា ខិប្បាភិញ្ញា ១ សុខា បដិបទា ទន្ធាភិញ្ញា ១ សុខា បដិបទា ខិប្បាភិញ្ញា ១ ។

**បដិសម្ភិទា ៤** : អត្ថប្បដិសម្ភិទា ១ ធម្មប្បដិសម្ភិទា ១ និរុត្តិប្បដិសម្ភិទា ១ បដិភាណប្បដិសម្ភិទា ១ ។

**កំណើត ៤** : ជលាពុជៈ ១ អណ្ឌជៈ ១ សំសេទជៈ ១ ឧបបាតិកៈ ១ ។

**ចក្ខុ ៥ យ៉ាង** : មំសចក្ខុ ១ ទិព្វចក្ខុ ១ បញ្ញាចក្ខុ ១ ពុទ្ធចក្ខុ ១ សមន្តចក្ខុ ១ ។

**បីតិ ៥ យ៉ាង** : ខុទ្ទកា បីតិ ១ ខណិកា បីតិ ១ ឱក្កន្តិកា បីតិ ១ ឧព្វេង្គា បីតិ ១ ផរណា បីតិ ១ ។

**មច្ឆរិយៈ ៥ យ៉ាង** : អាវាសមច្ឆរិយៈ ១ កុលមច្ឆរិយៈ ១ លាភមច្ឆរិយៈ ១ វណ្ណមច្ឆរិយៈ ១ ធម្មមច្ឆរិយៈ ១ ។

**មារ ៥ យ៉ាង** : ខន្ធមារ ១ កិលេសមារ ១ អភិសង្ខារមារ ១ មច្ចុមារ ១ ទេវបុត្តមារ១ ។

**វិមុត្តិ ៥ យ៉ាង** : តទង្គវិមុត្តិ ១ វិក្ខម្ភនវិមុត្តិ ១ សមុច្ឆេទវិមុត្តិ ១ បដិប្បស្សទ្ធិវិមុត្តិ១ និស្សរណវិមុត្តិ ១ ។

**សំវរៈ ៥ យ៉ាង** : សីលសំវរៈ ១ សតិសំវរៈ ១ ញាណសំវរៈ ១ ខន្តិសំវរៈ ១ វីរិយសំវរៈ ១ ។

**ព្យសនៈ ៥ យ៉ាង** : ញាតិព្យសនៈ ១ ភោគព្យសនៈ ១ រោគព្យសនៈ ១ សីលព្យសនៈ ១ ទិដ្ឋិព្យសនៈ ១ ។

**អភិញ្ញា ៦**:ឥទ្ធិវិធៈ ១ ទិព្វសោតៈ ១ ចេតោបរិយញ្ញាណ ១ បុព្វេនិវាសានុស្សតិ ១ ទិព្វចក្ខុ ១ អាសវក្ខយញ្ញាណ ១ ។

**ចរិត ៦** : រាគចរិត ១ ទោសចរិត ១ មោហចរិត ១ វិតក្កចរិត ១ សទ្ធាចរិត ១ ពុទ្ធិចរិត ១ ។

**វិសុទ្ធិ ៧** : សីលវិសុទ្ធិ ១ ចិត្តវិសុទ្ធិ ១ ទិដ្ឋិវិសុទ្ធិ ១ កង្ខាវិតរណវិសុទ្ធិ ១ មគ្គាមគ្គញ្ញាណទស្សនវិសុទ្ធិ ១ បដិបទា-ញាណទស្សនវិសុទ្ធិ ១ ញាណទស្សនវិសុទ្ធិ ១ ។

**អវិជ្ជា ៨** : ទុក្ខេ អញ្ញាណ ១ ទុក្ខសមុទយេ អញ្ញាណ ១ ទុក្ខនិរោធេ អញ្ញាណ ១ ទុក្ខនិរោធគាមិនិយា អញ្ញាណ ១ បុព្វន្តេ

អញ្ញាណ ១ អបរន្តេ អញ្ញាណ ១ បុព្វន្តាបរន្តេ អញ្ញាណ ១ បដិច្ចសមុប្បាទេ អញ្ញាណ ១ ។

**វិជ្ជា ៨** : វិបស្សនាញាណ ១ មនោមយិទ្ធិ ១ ឥទ្ធិវិធ ១ ទិព្វសោត ១ ចេតោបរិយញ្ញាណ ១ បុព្វេនិវាសានុស្សតិញ្ញាណ ១ ទិព្វចក្ខុ ១ អាសវក្ខយញ្ញាណ ១ ។

**អស្មិមានះ ៩ យ៉ាង** : **សេយ្យស្ស សេយ្យោហមស្មីតិ មានោ** អ្នកប្រសើរជាងគេ ប្រកាន់ថាអញប្រសើរជាងគេ ១ **សេយ្យស្ស សទិសោហមស្មីតិ** មានោអ្នកប្រសើរជាងគេ ប្រកាន់ថាអញស្មើនឹងគេ ១ **សេយ្យស្ស ហីនោហមស្មីតិ មានោ** អ្នកប្រសើរជាងគេ ប្រកាន់ថាអញថោកទាបជាងគេ ១ **សទិសស្ស សេយ្យោហមស្មីតិ មានោ** អ្នកស្មើនឹងគេ ប្រកាន់ថាអញប្រសើរជាងគេ ១ **សទិសស្ស សទិសោហមស្មីតិ មានោ** អ្នកស្មើនឹងគេ ប្រកាន់ថាអញស្មើនឹងគេ ១ **សទិសស្ស ហីនោហមស្មីតិមានោ**អ្នកស្មើនឹងគេ ប្រកាន់ថា អញថោក ទាបជាងគេ ១ **ហីនស្ស សេយ្យោហមស្មីតិ មានោ** អ្នកថោកទាបជាងគេ ប្រកាន់ថាអញប្រសើរជាងគេ ១ **ហីនស្ស សទិសោហមស្មីតិ មានោ** អ្នកថោកទាបជាងគេ

ប្រកាន់ថាអញស្មើនឹងគេ ១ **ហីនស្ស ហីនោហមស្មីតិ មានោ** អ្នកថោកទាបជាងគេ ប្រកាន់ថាអញថោកទាបជាងគេ ១ ។

**អន្តគ្គាហិកទិដ្ឋិ១០** :ឃើញថា លោកទៀង ១ លោកមិនទៀង ១ លោកមានទីបំផុត ១ លោកមិនមានទីបំផុត១ ជីវិតនិងសរីរៈដូចគ្នា ១ ជីវិតនិងសរីរៈផ្សេងគ្នា ១ សត្វស្លាប់ទៅរមែងកើតទៀត ១ សត្វស្លាប់ទៅ រមែងមិនកើតទៀត១ សត្វស្លាប់ទៅកើតទៀតក៏មាន មិនកើតទៀតក៏មាន ១ សត្វស្លាប់ទៅកើតទៀតក៏មិនមែន មិនកើតទៀតក៏មិនមែន ១ ។

**ព្រះទសពលញ្ញាណ១០** :ឋានាឋានញ្ញាណ ១ វិបាកញ្ញាណ ១ សព្វត្ថ គាមិនីបដិបទាញាណ ១ នានាធាតុញ្ញាណ ១ នានា-ធិមុត្តិញ្ញាណ ១ ឥន្ទ្រិយបរោបរិយត្តិញ្ញាណ ១ ឈានាទិសង្កិលេសាទិញ្ញាណ ១ បុព្វេនិវាសានុស្សតិញ្ញាណ ១ ចុតូបបាតិញ្ញាណ ១ អាសវក្ខយញ្ញាណ ១ ។

**សំយោជនៈ ១០** : សក្កាយទិដ្ឋិ ១ វិចិកិច្ឆា ១ សីលព្វតបរា-មាសៈ ១ កាមច្ឆន្ទៈ ១ ព្យាបាទ ១ រូបរាគ ១ អរូបរាគ ១ មានះ ១ ឧទ្ធច្ចៈ ១ អវិជ្ជា ១ ។

**សញ្ញា ១០** : អនិច្ចសញ្ញា ១ អនត្តសញ្ញា ១ អសុភសញ្ញា ១ អាទីនវសញ្ញា ១ បហានសញ្ញា ១ វិរាគសញ្ញា ១ និរោធសញ្ញា ១ សព្វលោកេ អនភិរតសញ្ញា ១ សព្វសង្ខារេសុ អនិដ្ឋសញ្ញា ១ អនាបានស្សតិ ១ ។

**អានិសង្សនៃមេត្តាភាវនា ១១ យ៉ាង** : **សុខំ សុបតិ** ដេកលក់ស្រួល ១ **សុខំ បដិពុជ្ឈតិ** ភ្ញាក់ឡើងស្រួល ១ **នបាបកំ សុបិនំ បស្សតិ** មិនឃើញសុបិននិមិត្តអាក្រក់ ១ **មនុស្សានំ បិយោ ហោតិ** ជាទីស្រឡាញ់ពេញចិត្តនៃមនុស្សទាំងឡាយ ១ **អមនុស្សានំ បិយោ ហោតិ** ជាទីស្រឡាញ់ពេញចិត្តនៃអមនុស្សទាំងឡាយ ១ **ទេវតា រក្ខន្តិ** ទេវតាទាំងឡាយតែងថែរក្សា ១ **នាស្ស អគ្គិ វា វិសំ វា សត្ថំ វា កមតិ** ភ្លើង ឬ ថ្នាំពិស ឬ គ្រឿងសស្ត្រា រមែងមិនធ្លាក់ត្រូវលើអ្នកចម្រើនមេត្តានោះ ១ **តុវដ្ដំ ចិត្តំ សមាធិយតិ** ចិត្តរបស់អ្នកចម្រើនមេត្តានោះតាំងមាំជាសមាធិយ៉ាងឆាប់ ១ **មុខវណ្ណោ វិប្បសីទតិ** សម្បុរមុខស្រស់បស់ ១ *អសម្មូឡ្ហោ កាលំ ករោតិ មិនវង្វេងស្មារតី ពេលជិតស្លាប់ ១* ឧត្តរឹ អប្បដិវិជ្ឈន្តោ ព្រហ្មលោកូបគោ ហោតិ

*កាលបើមិនទាន់បានសម្រេចមគ្គផលទេ ក៏រមែងទៅកើតក្នុងព្រហ្មលោកមិនខាន ១ ។*

**ធុតង្គធម៌ ១៣ : បំសុកូលិក ១ តេចីវរិក ១ បិណ្ឌបាតិក ១ សបទានចារិក ១ ឯកាសនិក ១ បត្តបិណ្ឌិក ១ ខលុបច្ឆាភត្តិក ១ អារញ្ញិក ១ រុក្ខមូលិក ១ អព្ភោកាសិក ១ សោសានិក ១ យថាសន្ថតិក ១ នេសជ្ជិក ១ ។**

**បាដិបុគ្គលិកទាន ១៤ យ៉ាង :**

១_ទានថ្វាយ ចំពោះព្រះសម្មាសម្ពុទ្ធ

២_ទានថ្វាយ ចំពោះព្រះបច្ចេកពុទ្ធ

៣_ទានថ្វាយ ចំពោះព្រះអរហន្តជាសាវ័ករបស់ព្រះពុទ្ធ

៤_ទានថ្វាយចំពោះបុគ្គលដែលប្រតិបត្តិដើម្បីបានលុះព្រះ_អរហត្តផល

៥_ទានថ្វាយចំពោះព្រះអនាគាមីបុគ្គល

៦_ទានថ្វាយចំពោះបុគ្គលដែលប្រតបត្តិដើម្បីលុះអនាគាមិផល

៧_ទានថ្វាយចំពោះព្រះសកទាគាមិបុគ្គល

៨_ទានថ្វាយចំពោះបុគ្គលដែលប្រតិបត្តិដើម្បី លុះសកទាមិផល

៩_ទានថ្វាយចំពោះព្រះសោតាបន្ន

១០_ទានថ្វាយចំពោះបុគ្គលដែលប្រតិបត្តិដើម្បីលុះសោតា

១១_ឱ្យទានចំពោះបុគ្គលក្រៅព្រះពុទ្ធសាសនាដែលមានសេចក្តីនឿយណាយក្នុងកាម

១២_ឱ្យទានចំពោះបុថុជ្ជនដែលមានសីលបរិសុទ្ធ

១៣_ឱ្យទានចំពោះបុថុជ្ជនដែលទ្រុស្តសីល

១៤_ឱ្យទានដល់សត្វតិរច្ឆាន ។

**ចរណៈ ១៥ ចែកចេញជា ៣ ពួកគឺ សីល ព្រះសទ្ធម្ម និង ឈាន ៖**

**សីល បានដល់ ៖ សីលសំវរៈ ឥន្ទ្រិយសំវរៈ ភោជនេមត្តញ្ញុតា ជាគរិយានុយោគ ។**

**ព្រះសទ្ធម្ម បានដល់ ៖ សទ្ធា ហិរិ ឱត្តប្បៈ ពាហុសច្ចៈ វីរិយៈ សតិ បញ្ញា ។**

**ឈាន បានដល់ ៖ បឋមជ្ឈាន ទុតិយជ្ឈាន តតិយជ្ឈាន ចតុត្ថជ្ឈាន ។**

## អង្គរបស់សិក្ខាបទ

**★ បាណាតិបាតសិក្ខាបទ មានអង្គ ៥**

១. **បាណោ** សត្វមានជីវិត

២. **បាណសញ្ញិតា** ដឹងថាសត្វមានជីវិត

៣. **វធកចិត្តំ** ចិត្តគិតសម្លាប់

៤. **ឧបក្កមោ** ព្យាយាមសម្លាប់

៥. **តេន មរណំ** សត្វស្លាប់ដោយព្យាយាមនោះ ។

ការសម្លាប់ តែមិនមានទោសតាមសេចក្តីក្នុងបិដកលេខ ១ ទំព័រ២៥៦ មនុស្សវិគ្គហសិក្ខាបទមាន ៧ គឺ មិនក្លែង ១ មិនដឹង ១ មិនប្រាថ្នាសម្លាប់ ១ ឆ្កួត ១ មានចិត្តរវើរវាយ ១ មានវេទនាគ្របសង្កត់ ១ ដើមបញ្ញត្តិ ១ ។

**★ បាណាតិបាតមាន ៤ យ៉ាង គឺ**

១. **អត្តនា ច បាណាតិបាតី ហោតិ** ជាអ្នកសម្លាប់សត្វដោយខ្លួនឯង

**២.បរេហ្ស** **បាណាតិបាតេ** **សមាទបេតិ** បបួលអ្នកដទៃក្នុងបាណាតិបាត

**៣.បាណាតិបាតេ** **ច** **សមនុញ្ញោ** **ហោតិ** ពេញចិត្តក្នុងបាណាតិបាត

**៤.បាណាតិបាតស្ស** **ច** **វណ្ណំ** **ភាសតិ** ពោលសរសើរគុណនៃបាណាតិបាត ។

**★ការមិនសម្លាប់សត្វមានអានិសង្សឬមានផល២៣យ៉ាង:**

**១.អង្គបច្ចង្គសមន្នាគតា** បរិបូរដោយអវយវៈតូចធំ (មានរាងកាយល្អសមទ្រង់ មិនវិកលវិការ)

**២.អារោហន** **បរិនាហសម្បត្តិ** ប្រកបដោយកាយខ្ពស់ហើយសមទ្រង់ផង

**៣.ជវនសម្បត្តិ** ជាមនុស្សសម្បូរដោយការវាងវៃល្អ

**៤.សុប្បតិដ្ឋិតបាទតា**ភាពជាមនុស្សមានជើងជាន់ ស៊ប់ល្អ

**៥.ចារុតា**ភាពជាមនុស្សមានសេចក្តីជ្រះថ្លារុងរឿង ល្អផង

**៦.សុចិតា** ភាពជាមនុស្សស្អាតល្អផង

**៧.មុទុតា** ភាពជាមនុស្សទន់ភ្លន់គួរសមផង

៨.**សុខិតា**ភាពជាមនុស្សជួបប្រទះសេចក្តីសុខចម្រើន ផង

៩.**សូរតា** ភាពជាមនុស្សក្លៀវក្លា ក្នុងបរិស័ទផង

១០.**មហព្វលតា** ភាពជាមនុស្សមានកម្លាំងច្រើនផង

១១.**វិសិដ្ឋវចនតា** ភាពជាមនុស្សមានវាចាពីរោះក្បោះក្បាយផង

១២.**អភេជ្ជបរិសតា** ភាពជាមនុស្សមានបរិសទ្យមិនបែកបាក់ពីខ្លួនផង

១៣.**អឆម្ភិតា**ភាពជាមនុស្សមិនតក់ស្លុតភ័យខ្លាចអ្វី ផង

១៤.**អប្បធំសិកតា** ពួកសឹកសត្រូវប្រទូស្តមិនបានផង

១៥.**អបរូបក្កមេនអមរណតា** ជាមនុស្សមិនស្លាប់ដោយក្តីព្យាយាមនៃអ្នកដទៃឡើយ

១៦.**អនន្តបរិវារតា** ជាមនុស្សមានបរិវារច្រើនមិនមានទីបំផុត

១៧.**សុរូបតា** ភាពជាអ្នកមានរូបល្អស្រស់

១៨.**សុសណ្ឋានតា** ភាពជាអ្នកមានទ្រង់ទ្រាយល្អផង

១៩.**អប្បាពាធតា** ភាពជាមនុស្សមានជម្ងឺតិចផង

២០.**អសោកិតា** ភាពជាមនុស្សមិនខ្វល់ចិត្តដោយសេចក្តីសោក

២១.**លោកបិយតា** ភាពជាអ្នកជាទីស្រឡាញ់នៃលោក គឺសព្វសត្វទាំងពួង

២២.**បិយេហិ មនាបេហិ សន្ធិអវិប្បយោគតា** មិនបានព្រាត់ ប្រាសនិរាសចោលសត្វ ព្រមទាំងសង្ខារដែលជាទីស្រឡាញ់ និងជាទីពេញចិត្ត ។

២៣.**ទីឃាយុកតា** ភាពជាមនុស្សមានអាយុវែងទៅតាមកាល ។

**អទិន្នាទានសិក្ខាបទ មានអង្គ ៥**

១**បរបរិគ្គហិតំ** ទ្រព្យដែលមានបុគ្គលដទៃហួងហែងថែរក្សា

២.**បរបរិគ្គហិតសញ្ញិតា** ដឹងថាទ្រព្យដែលគេហួងហែង ថែរក្សា

៣.**ថេយ្យចិត្តំ** មានចិត្តចង់លួច

៤.**ឧបក្កមោ** ព្យាយាមនឹងលួច

៥.**តេន ហរណំ** លួចបានដោយការព្យាយាមនោះ។

**★ហេតុដែលមិនត្រូវទោសមាន ៨ យ៉ាង គឺ:**

កាន់យកដោយសម្គាល់ថាជារបស់ខ្លួន ១ កាន់យកដោយសេចក្ដីស្និទ្ធស្នាល ១ កាន់យកជារបស់ខ្ចីគ្នា ១ កាន់យករបស់ដែលពួកប្រេតហួងហែងរក្សា ១ កាន់យករបស់ដែលពួកសត្វតិរច្ឆានហួងហែងរក្សា ១ កាន់យកដោយសម្គាល់ថាជារបស់បំសុកុល ១ បុគ្គលឆ្កួត ១ បុគ្គលដើមបញ្ញត្តិ ១ ។

★**អទិន្នាទានមាន ៤ យ៉ាងគឺ :**

១.**អត្តនោ ច អទិន្នាទាយី ហោតិ** ជាអ្នកកាន់យកទ្រព្យដែលអ្នកដទៃគេមិនបានឱ្យដោយខ្លួនឯង ។

២.**បរញ្ច អទិន្នាទានេ សមាទបេតិ** បបួលអ្នកដទៃក្នុងអទិន្នាទាន ។

៣.**អទិន្នាទានេ ច សមនុញ្ញោ ហោតិ** ពេញចិត្តក្នុងអទិន្នាទាន ។

៤.**អទិន្នាទានស្ស ច វណ្ណំ ភាសតិ** ពោលសរសើរគុណនៃអទិន្នាទាន ។

★**ការមិនលួចទ្រព្យអ្នកដទៃមានអានិសង្ស ១១ យ៉ាង :**

១.**មហទ្ធនតា** ភាពជាមនុស្សមានទ្រព្យច្រើន ។

២.**បហុតធនធញ្ញតា** ជាមនុស្សមានរបស់របរ និងធញ្ញាហារដ៏សំបូរស្តុកស្តម្ភ ។

៣.**អនន្តភោគតា** ជាមនុស្សមានភោគទ្រព្យមិនមានទីបំផុត ។

៤.**អនុប្បន្នភោគុប្បត្តិតា** ភោគទ្រព្យដែលមិនទាន់កើតក៏កើតឡើងដោយលំដាប់។

៥.**ឧប្បន្នភោគថាវរតា** ទ្រព្យដែលកើតឡើងហើយក៏តាំងនៅខ្ជាប់ខ្ជួន ។

៦.**ឥច្ឆិតានំ លាភានំ ខិប្បដិ លាភាតា** រកទ្រព្យដែលប្រាថ្នាបានដោយឆាប់រហ័ស (មិនលំបាក) ។

៧.**អសាធារណភោគតា** មានទ្រព្យសម្បត្តិ មិនអន្តរាយទៅដោយរាជភ័យ, ចោរភ័យ, ឧទកភ័យ, អគ្គិភ័យ , ឬញាតិឆបោកឡើយ ។

៨.**អសាធារណធនបដិលាភតា** រកទ្រព្យបានហើយមិនខ្ជះខ្ជាយសាយភាយទៅ ផ្តេសផ្តាសឡើយ ។

៩_**លោភុត្តរបដិលាភតា** សមរម្យជាអ្នកគួរបានលោកុត្តរ-ទ្រព្យ

១០_**នត្ថិ ភាវស្ស អជាននតា អសវនតា** ភាពជាអ្នកមិនធ្លាប់ដឹង ធ្លាប់ឮដោយគ្រាន់តែពាក្យថាគ្មាននោះឡើយ ។

១១_**សុខវិហារតា** ទៅកន្លែងណាក៏ជួបប្រទះតែសេចក្ដីសុខ ។

★ **កាមេសុមិច្ឆាចារមានអង្គ ៤**

១_**អគមនីយវត្ថុ** វត្ថុដែលមិនគួរគប់រកគឺស្ត្រីដែលមានគេ-ហួងហែងរក្សា ឬបុរស ដែលមិនមែនជាស្វាមីរបស់ខ្លួន ។

២_**តស្មិំ សេវនចិត្តំ** ចិត្តចង់សេពនឹងវត្ថុដែលមិនគួរគប់រកនោះ ។

៣_**សេវនប្បយោគោ** ព្យាយាមនឹងសេព ។

៤_**មគ្គេន មគ្គប្បដិបាទនំ** ញ៉ាំងមគ្គនិងមគ្គឱ្យដល់គ្នា ។

★ **ស្ត្រី ២០ ពួកដែលគេថែរក្សា**

១_**មាតុរក្ខិតា** ស្ត្រីដែលមានមាតាថែរក្សា ។

២_**បិតុរក្ខិតា** ស្ត្រីដែលមានបិតាថែរក្សា ។

៣_**មាតាបិតុរក្ខិតា** ស្ត្រីដែលមានមាតាបិតាថែរក្សា ។

៤.**ភាតុរក្ខិតា** ស្ត្រីដែលមានបងប្អូនប្រុសគ្រប់គ្រងរក្សា

៥.**ភគិនីរក្ខិតា** ស្ត្រីដែលមានបងប្អូនស្រីគ្រប់គ្រងរក្សា

៦.**ញាតិរក្ខិតា** ស្ត្រីដែលមានញាតិគ្រប់គ្រងរក្សា ។

៧.**គោត្តរក្ខិតា** ស្ត្រីដែលមានគោត្រជាមួយគ្រប់គ្រងរក្សា

៨.**ធម្មរក្ខិតា** ស្ត្រីដែលមានអ្នកប្រព្រឹត្តធម៌ត្រូវគ្នាគ្រប់គ្រងរក្សា ។

៩.**សារក្ខា** ស្ត្រីដែលប្រកបដោយកិរិយា គឺស្ត្រីដែលគេប្រកាន់ទុករួចហើយ

១០.**សបរិទណ្ឌា** ស្ត្រីដែលប្រកបដោយអាជ្ញា គឺស្ត្រីដែលព្រះរាជាដាក់អាជ្ញា មិនឱ្យអ្នកណាប្រព្រឹត្តកន្លងតាមអំពើចិត្ត ឬមិនឱ្យបុរសណាមួយទៅប្រព្រឹត្តកន្លង ។

១១.**ធនក្កីតា** ស្ត្រីដែលគេទិញ ឬលោះដោយទ្រព្យ ទោះ-តិចក្តីច្រើនក្តីយកមកធ្វើជាភរិយា ឬត្រឹមតែលោះយកមកប៉ុណ្ណោះគេមិនបានយកទៅធ្វើជាភរិយាក៏ដោយ ។

១២.**ឆន្ទវាសិនី** ស្ត្រីដែលរត់តាមទៅនៅធ្វើជាភរិយាដោយសេចក្តីពេញចិត្តរបស់ខ្លួន ហើយបុរសទទួលផង ។

១៣. **ភោគវាសិនី** ស្ត្រីដែលទៅនៅជាភរិយារបស់បុរស ព្រោះតែភោគៈ គឺស្ត្រីដែលបានភោគៈ យ៉ាងហោចត្រឹមតែអង្រែ និងត្បាល់ជាដើម អំពីបុរសណា ក៏ទៅធ្វើជាភរិយា របស់បុរសនោះ ។

១៤. **បដវាសិនី** ស្ត្រីដែលទៅធ្វើជាភរិយារបស់បុរស ព្រោះតែសំពត់ គឺស្ត្រីទ័លក្រ គ្រាន់តែសំពត់ស្លៀកឬសំពត់ ដណ្ដប់ក៏ក្រដែរ ទើបសុខចិត្តចូលទៅធ្វើភរិយាគេ ។

១៥. **ឱទបត្តកិនី** ស្ត្រីដែលគេផ្ដោបដៃជាមួយបុរស ជ្រលក់ទៅក្នុងផ្ដិលទឹកមួយ ហើយគេពោលថាអ្នកនាងទាំងឡាយ ចូរប្រឡំគ្នា, ចូរកុំបែកបាក់គ្នាឱ្យដូចជាទឹកនេះ គឺស្ត្រីដែលគេផ្សំផ្គុំ ឱ្យជាភរិយារបស់បុរសដោយវិធីនេះ ។

១៦. **ឱភតចុម្ពដា** ស្ត្រីដែលគេដាក់ទ្រនូលចុះអំពីក្បាល គឺស្ត្រីដែលរកឧសជាដើម ដែលបុរសណាជួយដាក់ទ្រនូល ចុះពីក្បាល ហើយនាំយកទៅធ្វើជាភរិយា ។

១៧.**ទាសី ច ភរិយា ច** ស្ត្រីដែលជាទាសីផងជាភរិយាផង គឺស្ត្រីដែលជាទាសីរបស់ បុរសណាមួយ ហើយបុរសនោះយកទៅធ្វើជាភរិយា ។

១៨.**កម្មការី ច ភរិយា ច** ស្ត្រីដែលជាកូនឈ្នួលផងជាភរិយាផង គឺស្ត្រីដែលចូលទៅ នៅធ្វើការស៊ីឈ្នួលបុរសណាមួយ ហើយបុរសនោះយកធ្វើជាភរិយា ។

១៩.**ធជាហដា** ស្ត្រីដែលសេនានាំមកដោយទង់ជ័យ គឺស្ត្រីដែលកងសេនាតំឡើងទង់ជ័យ លើកទ័ពទៅច្បាំងដណ្តើមដែនរបស់ស្តេចដទៃ កៀរយកមកបាន ហើយបុរសណាមួយយកមកធ្វើជាភរិយា ។

២០.**មុហុត្តិកា** ស្ត្រីដែលមានបុរសគប់ប្រសព្វតែមួយស្របក់ គឺស្ត្រីដែលជាសាហាយស្មន់របស់បុរសណាមួយ ។

ស្ត្រីទាំង ២០ ជំពូកនេះ ជាអគមនីយដ្ឋានរបស់បុរស បើបុរសណាទៅគប់រកដោយអស្សទ្ធម្មត្រូវដាច់កាមេសុមិច្ឆាចារ។

ស្ត្រី ៨ ជំពូកខាងដើម **មាតុរក្ខិតា** រហូតដល់ **ធម្មរក្ខិតា** បើទៅគប់រកបុរសណាស្ត្រីនោះមិនដាច់កាមេសុមិច្ឆាចារឡើយ

ព្រោះមាតាជាដើមនោះ គ្រាន់តែរក្សានូវកេរ្តិ៍ឈ្មោះ ប៉ុណ្ណោះ មិនមែនរក្សានូវសម្ផស្សឡើយ ។

ឯស្ត្រី ១២ ជំពូកខាងចុង **សារក្ខា** រហូតដល់ **មុហុត្តិកា** បើទៅគប់រកបុរសណាមួយ ត្រូវដាច់កាមេសុមិច្ឆាចារ ព្រោះស្ត្រីនោះមានស្វាមីថែរក្សាសម្ផស្សហើយ ។

**★ ហេតុដែលមិនត្រូវទោសមាន ៥ យ៉ាងគឺ :**

មិនដឹង ១ ឆ្កួត ១ មានចិត្តរវើរវាយ ១ ទុក្ខវេទនាគ្របសង្កត់ ១ មិនត្រេកអរ ១ ។

កាមេសុមិច្ឆាចារ មាន ៤យ៉ាង ដោយន័យដូចគ្នានឹងសិក្ខាបទ ២ ខាងដើមដែរ...។

**★អព្រហ្មចរិយសិក្ខាបទមានអង្គ ៤ :**

១.**អេនេនវត្ថុ** វត្ថុជាទីទម្លាយនូវសីល គឺទ្វារទាំង ៣០ ទ្វារណាមួយ

២.**សេវនចិត្តំ** ចិត្តគិតនឹងសេព

៣.**តជ្ជោវាយាមោ** ព្យាយាមនឹងសេពនូវមេថុនធម្មនោះ

៤.**មគ្គេន មគ្គប្បដិបាទនំ** ញុំាងមគ្គនិងមគ្គឱ្យដល់គ្នា ។

★ ហេតុដែលមិនត្រូវទោសមាន ៥ យ៉ាងគឺ :

មិនដឹង ១ ឆ្កួត ១ មានចិត្តរវើរវាយ ១ ទុក្ខវេទនាគ្របសង្កត់ ១ មិនត្រេកអរ ១ ។

**★ ផលឬអានិសង្សនៃការរក្សាកាមេសុមិច្ឆាចារសិក្ខាបទ និង អព្រហ្មចរិយៈ**

១.**វិគតបច្ចត្ថិកតា** សឹកសត្រូវបៀតបៀនមិនបាន ។

២.**សព្វជនស្ស បិយតា** ជាទីស្រឡាញ់នៃជនទាំងពួង ។

៣.**អន្នបានវត្ថសយនាទីនំបដិលាភតា** រកបាយ ទឹកសំពត់ស្លៀកដណ្តប់ និងទីកន្លែងដេកនៅបានដោយងាយ (មិនលំបាក) ។

៤.**សុខសយនតា** ដេកលក់ក៏សុខស្រួល ។

៥.**សុខបដិពុជ្ឈនតា** ភ្ញាក់ឡើងក៏ជាសុខស្រួល ។

៦.**អបាយភយវិនិមុត្តតា** ផុតភ័យក្នុងអបាយ ។

៧.**អភព្វតា** មិនត្រឡប់កើតជាស្រី ឬខ្ទើយឡើយ ។

៨.**អក្កោធនតា** ជាមនុស្សមិនងាយនឹងក្រោធខឹងភ្លាមៗ។

៩.**សក្កច្ចការិតា** ធ្វើអ្វីៗ ក៏សុទ្ធតែរៀបរយល្អ ។

១០.**បច្ចក្ខការិតា** ធ្វើអ្វីៗក៏ប្រាកដមិនដាក់ធុរៈចោល ។

១១.**អបតិខន្ធតា** មិនឱន ក សំយុងចុះ ។

១២.**អនធោមុខតា**មិនមានមុខឱនជ្រប់(ក្នុងទីប្រជុំឡើយ)

១៣.**អញ្ញមញ្ញបិយតា** មានមិត្តភក្តិសុទ្ធតែស្រឡាញ់គ្នា (រាប់អានគ្នា) ។

១៤.**បរិបុណ្ណិន្ទ្រិយតា** មានឥន្ទ្រិយពេញល្អ ។

១៥.**បរិបុណ្ណលក្ខណតា** មានលក្ខណៈគ្រប់គ្រាន់ល្អ ។

១៦.**និរាសង្កតា** មិនមានអ្នកណារង្កៀស ។

១៧.**អប្បោស្សុក្កតា** មានការខ្វាយខ្វល់តិចក្នុងអំពើឥតប្រយោជន៍ ។

១៨.**សុខវិហារតា** ទៅទីណាក៏ជួបតែសេចក្តីសុខ ។

១៩.**អកុតោភយា** មិនមានភ័យមកពីណាឡើយ ។

២០.**បិយវិប្បយោគភាវនា** មិនសូវមានការព្រាត់ប្រាសចាករបស់ជាទីស្រឡាញ់ ។

★**មុសាវាទសិក្ខាបទ មានអង្គ ៤ :**

១.**អតថំ វត្ថុ** វត្ថុមិនពិត

២.**វិសំវាទនចិត្តំ** គិតនឹងពោលឱ្យខុស

៣.**តជ្ជោ វាយាមោ** ព្យាយាមនឹងពោលឱ្យខុសនោះ

៤.**បរស្ស តទត្ថ វិជាននំ** ញុំាងអ្នកដទៃឱ្យដឹងច្បាស់នូវសេចក្តីនោះ ។

★**ហេតុដែលមិនត្រូវទោសមាន ៣ យ៉ាង** :

១.**ទវាយ ភណតិ ទវាយ ភណតិ នាម សហសា ភណតិ** បុគ្គលពោលដោយញាប់ គឺពោលដោយរហ័ស ឈ្មោះថា ពោលដោយញាប់មាត់ ។

២.**ទវាយ ភណតិ ទាវាយ នាម អញ្ញំ ភណិស្សាមីតិ អញ្ញំ ភណតិ** បុគ្គលពោលដោយភ្លាត់មាត់ គឺ គិតថា អញនឹងពោលពាក្យដទៃ ហើយត្រឡប់ជាពោលពាក្យដទៃក្រៅអំពីគិតនោះទៅវិញ ឈ្មោះថា ពោលដោយភ្លាត់មាត់ ។

៣.**ឧម្មត្តកស្ស** បុគ្គលឆ្កួត ។

★**ផលនៃការវៀរចាកការនិយាយកុហក**(មុសាវាទ) :

១.**វិប្បសន្និន្ទ្រិយតា** មានឥន្ទ្រិយទាំង ៥ ជ្រះថ្លា ។

២.**វិស្សិដ្ឋវិភោណតា** មានវាចាពិរោះក្បោះក្បាយផង

៣.**សមសិតសុទ្ធទន្តោ** មានធ្មេញត្រឹមស្មើជិតបរិសុទ្ធល្អ។

៤.**នាតិថូលគោ** មានរាងជាមនុស្សសមទ្រង់មិនធាត់ធំពេក។

៥.**នាតិកីសគោ** ជាមនុស្សមិនស្គមពេក សមរូប សមរាង

៦.**នាតិទីឃគោ** ជាមនុស្សល្មមមិនខ្ពស់ពេក ។

៧.**នាតិរស្សគោ** ជាមនុស្សមិនទាបពេក ។

៨.**សុខសម្ផស្សគោ** បាននូវសម្ផស្សដ៏សុខស្រួល ។

៩.**ឧប្បលគន្ធមុខគោ** មានមាត់ផ្លុំក្លិនដូចផ្កាឧប្បលជាតិផង

១០.**សុស្សូសកបរិជនតា** មានបរិសទ្យជាបរិវារសុទ្ធតែមានសេចក្ដីឧស្សាហ៍ ។

១១.**អាទេយ្យវចនគោ** មានសេចក្ដីគួរជឿស្ដាប់បានផង ។

១២.**មុខលោហិតតម្ពជិវ្ហតា** មានអណ្ដាតស្ដើង ឡើងក្រហមដូចជាត្របកឈូក ។

១៣.**អនុទ្ធតា** មានចិត្តមិនរសាត់អណ្ដែតផ្ដេសផ្ដាស់ ។

១៤.**អចបលតា** មិនមែនជាមនុស្សល្ងង់ខ្លៅ ។

★ **សុរាមេរយសិក្ខាបទមានអង្គ ៤ :**

១.**មជ្ជនីយវត្ថុ** វត្ថុជាទីតាំងនៃសេចក្តីស្រវឹង គឺសុរា និងមេរ័យ ។

២.**ធាតុកម្យតាចិត្តំ** គិតបម្រុងនឹងផឹក ។

៣.**តជ្ជោវាយាមោ** ព្យាយាមនឹងផឹកនូវទឹកស្រវឹងនោះ

៤.**តស្ស បានំ** បានផឹកនូវទឹកស្រវឹងនោះ កន្លងបំពង់កចូលទៅ ។

**★ហេតុដែលមិនត្រូវទោសមាន ៧ យ៉ាងគឺ :**

១.**អមជ្ជញ្ច ហោតិ មជ្ជវណ្ណំ មជ្ជគន្ធំ មជ្ជរសំ តំ បិវតិ** ផឹកទឹកមិនស្រវឹង តែទឹកនោះមានពណ៌ដូចទឹកស្រវឹង មានក្លិនដូចទឹកស្រវឹង មានរសដូចទឹកស្រវឹង ។

២.**សូបសំបាកេ** ទឹកស្រវឹងដែលគេចម្អិនលាយនឹងសម្ល

៣.**មំសសំបាកេ** ទឹកស្រវឹងដែលគេចម្អិនលាយនឹងសាច់

៤.**តេលសំបាកេ** ទឹកស្រវឹងដែលគេចម្អិនលាយនឹងប្រេង

៥.**អាមលកផាណិតេ** ទឹកអំពៅដែលត្រាំលាយនឹងទឹកកន្ទួតព្រៃ ។

៦.**អមជ្ជំ អរិដ្ឋំ បិវតិ** ផឹកថ្នាំអរិដ្ឋមិនស្រវឹង ។

៧.**ឧម្មត្តកស្ស** ឆ្កួត ។

★ **ផលនៃការមិនផឹកសុរា និងមេរ័យមាន ៣៥ យ៉ាងគឺ :**

១.**កិច្ចករណីយេសុ ខិប្បំ បដិជាននតា** ជាមនុស្ស ដឹងស្គាល់កិច្ច ដែលគួរធ្វើក្នុងអតីត អនាគត បច្ចុប្បន្នបាន យ៉ាងឆាប់ភ្លាមៗ ។

២.**សទា ឧបដ្ឋិតសតិតា** ជាអ្នកមានសតិនៅតម្កល់ខ្ជាប់ខ្ជួនសព្វៗកាល ។

៣.**អនុម្មត្តកតា** ជាមនុស្សល្អ មិនមែនជាមនុស្សឆ្កួត

៤.**ញាណវន្តតា** មានញាណជាគ្រឿងដឹងច្រើនប្រការ

៥.**អនេឡតា** ជាមនុស្សមិនញាប់ញ័រផ្ដេសផ្ដាស់ ។

៦.**អជឡតា** ជាមនុស្សមិនសស្វាក់សស្វើតស្ទុះស្ទារ ។

៧.**អមូគតា** ជាមនុស្សមិន គ ត្រជិត ។

៨.**អមទតា** ជាមនុស្សមិនស្រវឹងជ្រប់ក្នុងអារម្មណ៍ ។

៩.**អប្បមត្តតា** ជាមនុស្សមិនមានប្រមាទក្នុងកុសលធម៌

១០.**អសម្មោហតា** ជាមនុស្សមិនវង្វេងផ្ដេសផ្ដាស់ ។

១១.**អឆម្ភិតា** ជាមនុស្សមិនងាយនឹងតក់ស្លុតភ័យខ្លាច

១២_**អសារម្ភិតា** ជាមនុស្សមិនមានសេចក្ដីរំខាន ។

១៣_**អនិស្សុកិតា** ជាមនុស្សមិនច្រណែនឫស្យា ។

១៤_**អប្បោស្សុក្កតា** ជាមនុស្សមានសេចក្ដីខ្វល់ខ្វាយតិច

១៥_**សុខីគតា** ជាមនុស្សមានសេចក្ដីសុខស្រួលច្រើន ។

១៦_**អភិសម្មតតា** មានមនុស្សឯទៀតរាប់អានច្រើន ។

១៧_**សច្ចវាទិតា** ពោលពាក្យសុទ្ធតែជាសច្ចវាចាផង ។

១៨_**អបិសុណតា**មិនពោលពាក្យស៊កសៀតអ្នកណា អ្នក-ដទៃក៏មិនពោលមក ។

១៩_**អផរុសតា** មិនពោលពាក្យទ្រគោះបោះបោក ។

២០_**អសម្ផប្បលាបវាទិតា** មិននិយាយពាក្យរោយរាយ-ឥតប្រយោជន៍ ។

២១_**រត្តិន្ទិវមតន្ទិតតា** ជាមនុស្សមិនខ្ជិលច្រអូសក្នុងយប់និងថ្ងៃ ។

២២_**កតញ្ញូតា** ជាមនុស្សដឹងឧបការគុណដែលអ្នកដទៃធ្វើហើយ ។

២៣_**កតវេទិតា**ជាមនុស្សដឹងគុណហើយធ្វើតបនូវគុណ

២៤. **អមិច្ឆរិតា** ជាមនុស្សមិនកំណាញ់ស្វិតស្វាញខុសទំនង

២៥. **ចាគវន្តតា** ជាអ្នកមានការបរិច្ចាគតាមកាល ។

២៦. **សីលវន្តតា** ជាមនុស្សមានសីលល្អតាមកាល ។

២៧. **ឧជុកតា** ជាមនុស្សមានចិត្តត្រង់ ។

២៨. **អក្កោធនតា** ជាមនុស្សមិនងាយនឹងក្រោធខឹង ។

២៩. **ហិរិមនតា** ជាមនុស្សមានចិត្តខ្មាសបាប ។

៣០. **ឱត្តប្បិតា** ជាមនុស្សមានសេចក្តីតក់ស្លុតនឹងបាប

៣១. **ឧជុទិដ្ឋិតា** ជាមនុស្សមានទិដ្ឋិត្រូវត្រង់តាមព្រះធម៌ព្រះវិន័យ ។

៣២. **មហាបញ្ញតា** ជាមនុស្សមានបញ្ញាទូលំទូលាយ ។

៣៣. **មេធាវីតា** ជាបណ្ឌិតមានប្រាជ្ញា ។

៣៤. **បណ្ឌិតា** ភាពជាអ្នកមានញាណគតិសព្វប្រការ ។

៣៥. **អត្ថានត្ថកុសលតា** ឈ្លាសវៃ យល់ដឹងក្នុងការងារមានប្រយោជន៍ និងក្នុងការងារមិនមានប្រយោជន៍ទាំងពួង ។

★ **ទោសរបស់អ្នកផឹកសុរា :**

១.**ខុម្មានីទា** ជាមនុស្សឆ្កួតក៏មាន ។

២.**ខិត្តចិត្តោ ទា**ជាមនុស្សខូចចិត្តក្រឡុកចិត្តលីលាក៏មាន

៣.**ឯឡម្មុត្តោ ទា ហោតិ**ជាមនុស្សតំឡាន់គល្វើល្វើ ក៏មាន ។

★**ទោស ៦ យ៉ាងដទៃទៀត :**

១.**សន្ទិដ្ឋិកា ធនជានី** ឱ្យទោសជាក់ស្តែង ឃើញហីន ហោច វិនាសសាបសូន្យទ្រព្យសម្បត្តិទាំងពួង ។

២.**កលហប្បវឌ្ឍនី** ជាមេនាំឱ្យចម្រើនដោយការឈ្លោះ ប្រកែក ។

៣.**រោគានំ អាយតនំ** ជាខេត្តនៃរោគទាំងឡាយមាន រោគភ្នែកជាដើម ។

៤.**អកិត្តិសញ្ជននី** មានកេរ្តិ៍ឈ្មោះអាក្រក់ផ្សាយទៅគ្រប់ ទិសទី ។

៥.**កោបិននិទំសនី** ជាមនុស្សឥតខ្មាស ហ៊ានបង្ហាញ កេរ្តិ៍ខ្មាសឱ្យគេមើល ។

៦.**បញ្ញាយ ទុព្វលីករណី** ធ្វើឱ្យបញ្ញាឱ្យមានកម្លាំង

ខ្សោយចុះ ។

★**ន គេវលំ** មិនតែប៉ុណ្ណោះឡើយ អ្នកផឹកសុរា មានទោសច្រើនប្រការទៀត **ភាយចាលន សមត្ថំ** បើផឹកច្រើនរហូតដល់អាចញ៉ាំងកាយឱ្យក្រទិក្រទា ព្រហើនហ៊ានធ្វើបាណាតិបាត អទិន្នាទាន កាមេសុមិច្ឆាចារ មុសាវាទតទៅទៀត។

★**សុរាមាន ៥ យ៉ាង គឺ :**

១.**បិដ្ឋសុរា** សុរាដែលធ្វើអំពីម្សៅ

២.**បូវសុរា** សុរាដែលធ្វើអំពីនំ

៣.**ឱទនសុរា** សុរាដែលធ្វើអំពីបាយ

៤.**កិណ្ណបក្ខិត្តា** សុរាដែលគេដាក់ពូជសុរា

៥.**សម្ភារសំយុត្តា** សុរាដែលគេប្រកបព្រមដោយគ្រឿងផ្សំផ្សេងៗ ។

★**មេរ័យមាន ៥ យ៉ាង គឺ :**

១.**បុប្ផាសវោ** ទឹកត្រាំដែលគេធ្វើដោយផ្កាឈើ

២.**ផលាសវោ** ទឹកត្រាំដែលគេធ្វើដោយផ្លែឈើ

៣.**មធ្វាសវោ** ទឹកត្រាំដែលគេធ្វើដោយផ្លែចន្ទន៍

៤.**គុឡាសវោ** ទឹកត្រាំដែលគេធ្វើដោយទឹកអំពៅ

៥.**សម្ភារសំយុត្តា**ទឹកត្រាំដែលធ្វើដោយគ្រឿងផ្សំផ្សេងៗ

★**វិកាលភោជនាសិក្ខាបទមានអង្គ ៣ គឺ :**

១.**វិកាលោ** កាលខុស

២.**យាវកាលិកំ** របស់ដែលគួរបរិភោគបានក្នុងកាល គឺចាប់តាំងអំពីអរុណរះឡើង ដរាបដល់ថ្ងៃត្រង់ ។

៣.**អជ្ឈោហរណំ** បានលេបចូលទៅកន្លងបំពង់ក ។

★**ហេតុដែលមិនត្រូវទោសមាន ២ យ៉ាង : យាមកាលិកំ សត្តាហកាលិកំ យាវជីវំ សតិ បច្ចយេ បរិភុញ្ជតិ** បរិភោគនូវត្ថុដែលជាយាមកាលិក សត្តាហកាលិកនិង យាវជីវិក ដែលមានហេតុគួរបរិភោគបាន ១ **ឧម្មត្តកស្ស** ឆ្កួត ១

★**នច្ចគីតៈ មានអង្គ ៣ គឺ :**

១.**នច្ចគីតានិ** ការល្បែង មានច្រៀង និងរាំជាដើម

២.**កត្តុកម្យតាចិត្តំ** ចិត្តប្រាថ្នាដើម្បីនឹងធ្វើ

៣.**សុតឧស្សុនត្តាយគមនំ** ទៅដើម្បីនឹងស្តាប់ ឬមើល ហើយបានស្តាប់ ឬមើល ។

(គប្បីឱ្យពិស្តារក្នុងគម្ពីរសមន្តបាសាទិកា)

★ **មាលាគន្ធវិលេបនមានអង្គ ៣ គឺ :**

១.**មាលាទិ** វត្ថុសម្រាប់ប្រដាប់កាយ មានផ្កាកម្រង ជាដើម

២.**ធារណច្ឆន្ទតា** សេចក្តីប្រាថ្នានឹងប្រដាប់តាក់តែង

៣.**តស្ស ធារណំ** បានប្រដាប់តាក់តែងនូវវត្ថុ សម្រាប់ប្រដាប់កាយ មានផ្កាកម្រង ជាដើមនោះ ។

★ **ឧច្ចាសយនៈមានអង្គ ៣ គឺ :**

១.**ឧច្ចាសយនមហាសយនំ** ទីដេកទីអង្គុយដ៏ខ្ពស់ ប្រសើរហួសប្រមាណ

២.**បរិភោគចិត្តំ** គិតនឹងដេក ឬអង្គុយ

៣.**បរិភោគករណំ** បានដេក ឬអង្គុយ ។

*(ការសម្តែងអង្គសិក្ខាបទដោយសង្ខេប ចប់តែត្រឹមនេះ ស្រង់ចាកគម្ពីរព្រះវិន័យ)*

# ប្រយោជន៍នៃការសិក្សាព្រះធម៌ ស្តាប់ព្រះធម៌

ធម្មសិក្ខា គឺការសិក្សាព្រះធម៌ ឬស្តាប់ព្រះធម៌ ជាគុណគាប់ដ៏ឧត្តមក្រៃលែងណាស់ ទាំងជាប្រយោជន៍បច្ចុប្បន្ន ទាំងជាប្រយោជន៍អនាគត ដែលគួរនឹងពណ៌នា ។ ការសិក្សាព្រះធម៌ដែលជាព្រះពុទ្ធដីកា ព្រះអដ្ឋកថា ដែលព្រះសម្មាសម្ពុទ្ធ បរមលោកនាថទ្រង់ត្រាស់សម្តែងហើយ ជាគុណនាំឱ្យរួចផុតចាកទុក្ខ ជាគុណនាំឱ្យផុតកង្វល់ នាំឱ្យមានចិត្តផុតស្រឡះ ដឹងច្បាស់ ស្គាល់ច្បាស់នូវលោកនេះតាមសេចក្តីពិតហើយ រមែងដល់នូវវិបុលសុខ គឺសេចក្តីសុខដ៏ធំទូលាយ ដែលអ្នកណាៗក៏មិនអាចប្រមាណបាននូវសេចក្តីសុខនោះ ។

ការសិក្សាដែលជាគុណនេះ មានគោលសំខាន់ៗ ដែលលើកមកពណ៌នាក្នុងទីនេះ គឺ

១.ការសិក្សាព្រះធម៌ ស្តាប់ព្រះធម៌នាំឱ្យមានចិត្តបានសុខក្សេមក្សាន្ត ក្នុងពេលកំពុងសិក្សាក្នុងពេលកំពុងស្តាប់ទទួលយកនូវរសនៃព្រះធម៌ហើយធ្វើឱ្យចិត្តត្រជាក់ដូចដែលព្រះអង្គទ្រង់

ត្រាស់ព្រះគាថាប្រារព្ធព្រះមហាកប្បិនត្ថេរក្នុងគាថាធម្មបទបណ្ឌិតវគ្គទី ៦ ថា :

**ធម្មប្បីតិ សុខំ សេតិ វិប្បសន្នេន ចេតសា**
**អរិយប្បវេទិតេ ធម្មេ សទា រមតិ បណ្ឌិតោ ។**

បុគ្គលដែលមានសេចក្តីឆ្អែតក្នុងធម៌ មានចិត្តជ្រះថ្លាហើយ រមែងដេកជាសុខ បណ្ឌិតរមែងត្រេកអរក្នុងធម៌ដែលព្រះអរិយៈប្រកាសទុកហើយគ្រប់ពេល (សព្វៗកាល) ។

២_ការសិក្សាព្រះធម៌ រមែងបាននូវចំណេះដឹងពិតប្រាកដ គឺថាចំណេះដឹងដែលរួចផុតចាកលោកនេះ ព្រោះមិនចាប់ប្រកាន់ ព្រោះមិនហួងហែងនូវរបស់ក្នុងលោក ដែលជារបស់ប្រព្រឹត្ត ដោយសេចក្តីទុក្ខ សេចក្តីចង្អៀតចង្អល់ចិត្ត កាលដែលបានទទួលយកព្រះធម៌ មកសិក្សាអប់រំហើយចិត្តរមែង តាំងស៊ប់នៅក្នុងភាពសុខ ដោយមិនមានសុខដទៃមកប្រៀបបានឡើយ ។

៣_ការសិក្សាព្រះធម៌ រមែងញ៉ាំងប្រយោជន៍ឱ្យដល់ព្រម

៤_ការសិក្សាព្រះធម៌ រមែងមិនមានពៀរវេរា ក្នុងបុគ្គលទាំងឡាយ ។

៥_ការសិក្សាព្រះធម៌ រមែងបាននូវធម្មញាតិ ធម្មមិត្តដែលប្រកបដោយគុណ ។

៦_ការសិក្សាព្រះធម៌ គឺបានធ្វើជីវិតឱ្យមានពន្លឺដ៏រុងរឿងដោយព្រះធម៌ ។

៧_ការសិក្សាព្រះធម៌ រមែងបានចូលដល់នូវការឃើញសច្ចធម៌ ។

៨_ការសិក្សាព្រះធម៌ ធម៌រមែងទ្រទ្រង់នូវដំណើរជីវិតឱ្យសុខក្នុងព្រះធម៌ ។

៩_ការសិក្សាព្រះធម៌ ធម៌តែងជួយអប់ឧណ្ហចិត្តឱ្យធំដោយភាពស្រឡះស្រឡូន ។

១០_ការសិក្សាព្រះធម៌ គឺចេះធ្វើដំណើរទៅរកផ្លូវនៃព្រះនិព្វាន ។

**សេចក្តីព្រះធម៌លោកគ្រូអារាធនាអំពីគម្ពីរអដ្ឋកថាអដ្ឋសាលិនី**

*(ថ្ងៃអាទិត្យ ៨រោច ខែ ស្រាពណ៍ ព.ស.២៥៥៦ ទិវាសន្ទនាព្រះធម៌)*

១-អលោភៈជាសត្រូវដល់មន្ទិល គឺសេចក្ដីកំណាញ់, អទោសៈ ជាសត្រូវដល់មន្ទិល គឺការទ្រុស្តសីល, អមោហៈជាសត្រូវដល់ការដែលមិនចម្រើននៅក្នុងកុសលធម៌ទាំងឡាយ។

២-អលោភៈ ជាហេតុនៃទាន អទោសៈ ជាហេតុនៃសីល អមោហៈ ជាហេតុនៃភាវនា ។

៣-បណ្ដាគុណធម៌ទាំងនោះ បុគ្គលមានការមិនលោភ រមែងកាន់យកមិនច្រើន បុគ្គលដែលលោភទើបកាន់យកច្រើន បុគ្គលដែលមិនមានទោសៈ រមែងកាន់យកបន្តិចបន្តួច ព្រោះបុគ្គលដែលមានទោសៈប្រទូស្តហើយ ទើបមានការកាន់យកច្បិចច្បើម បុគ្គលមិនមានការវង្វេងរមែងកាន់យកមិនវិបរិត ព្រោះបុគ្គលវង្វេងទើបកាន់យកវិបរិត ។

៤-ក្នុងបណ្ដាគុណធម៌ទាំងអស់នោះ បុគ្គលចាំនូវទោសដែលមានក្នុងសភាពដែលជាទោស រមែងបើកបង្ហាញនូវទោស-ទាំងឡាយឱ្យប្រព្រឹត្តទៅ ព្រោះដែលមិនមានលោភៈ ព្រោះថាបុគ្គលលោភៈ រមែងបិទបាំងនូវទោស បុគ្គលដែលចាំនូវគុណដែលមានជាតួគុណ រមែងប្រកាសគុណទាំងឡាយ ឱ្យប្រព្រឹត្តទៅ

ព្រោះការដែលមិនមានទោសៈ ព្រោះបុគ្គល ដែលមានទោសៈប្រទូសរាយហើយ រមែងលុបបំបាត់នូវគុណ របស់អ្នកដទៃ (អលោភៈ បើកទោសខ្លួនឯង អទោសៈប្រកាសគុណអ្នកដទៃ) បុគ្គលចាំទុកនូវសភាវៈតាមសេចក្តីពិត ដោយសភាវៈតាមសេចក្តីពិតរមែងប្រកាសនូវសភាវៈតាមសេចក្តីពិតឱ្យប្រព្រឹត្តទៅ ព្រោះការមិនវង្វេង ព្រោះថាបុគ្គលវង្វេងរមែងកាន់យកនូវរបស់តាមសេចក្តីពិត ថាជារបស់មិនពិត កាន់យករបស់ដែលមិនពិតថាជារបស់ពិត ដោយអំណាចនៃការវង្វេង ។

៥_សេចក្តីទុក្ខ មានការព្រាត់ចាកនូវរបស់ដែលជាទីស្រ_ឡាញ់ ជាទីពេញចិត្ត រមែងមិនមាន ព្រោះការដែលមិនមានលោភៈ ព្រោះបុគ្គលដែលមានលោភៈមាននូវសភាវៈដែលប្រកាន់នូវរបស់ដែលជាទីស្រឡាញ់ ជាទីពេញចិត្ត និងព្រោះអត់ធន់នឹងរបស់ដែលជាទីស្រឡាញ់ ជាទីពេញចិត្តមិនបាន ទុក្ខព្រោះជួបប្រសព្វនឹងសត្វសង្ខារដែលមិនជាទីស្រឡាញ់ មិនជាទីពេញចិត្តរមែងមិនមានព្រោះគុណធម៌គឺអទោសៈ ព្រោះបុគ្គលដែលមាន_ទោសៈប្រទូសរាយហើយ មានសភាពប្រកាន់នូវរបស់ដែលមិន

ជាទីស្រឡាញ់ មិនជាទីពេញចិត្ត និងព្រោះអត់ធន់ចំពោះការជួប ប្រសព្វនូវរបស់ដែលមិនជាទីស្រឡាញ់ មិនជាទីពេញចិត្តហ្នឹងមិន បានទុក្ខមានការមិនបាននូវរបស់ដែលជាទីប្រាថ្នា រមែងមិនមាន-ដល់បុគ្គលដែលមិនវង្វេងដោយអំណាចនៃគុណធម៌ គឺអមោហៈ ព្រោះបុគ្គលដែលមិន វង្វេងមានការចម្រើនពិចារណាយ៉ាងនេះ ថា ពួកយើងគប្បីបាននូវរបស់នោះអំពីទីណា ។

៦-ក្នុងបណ្តាគុណធម៌ទាំងអស់នោះ ជាតិទុក្ខ រមែងមិន មានព្រោះអលោភៈ ពីព្រោះ អលោភៈបដិបក្ខដល់តណ្ហា (ជាតិ ទុក្ខមានតណ្ហាជាមូល) ជរាទុក្ខ រមែងមិនមាន ព្រោះ អទោសៈ ព្រោះបុគ្គលដែលមាននូវទោសៈខ្លាំងក្លា ជាបុគ្គលមានសភាវៈគឺ សេចក្តីជរាដោយឆាប់ (**ខឹងច្រើនឆាប់ចាស់**) មរណទុក្ខ រមែង មិនមានព្រោះ អមោហៈ ព្រោះការស្លាប់របស់បុគ្គលដែលវង្វេង គឺជាទុក្ខ តែទុក្ខនោះរមែងមិនមានដល់បុគ្គលដែលមិនវង្វេង ។

៧-ការនៅរួមគ្នាជាសុខរបស់គ្រហស្ថទាំងឡាយ ព្រោះ-ការមិនលោភ ការនៅរួមគ្នាជាសុខរបស់បព្វជិតទាំងឡាយ ព្រោះមិនវង្វេង ការនៅរួមគ្នាជាសុខរបស់គ្រហស្ថ និង បព្វ-

ជិតទាំងអស់ ព្រោះការដែលមិនមានទោសៈ ។

៨_បណ្ដាគុណធម៌ទាំងនោះ ពោលដោយពិសេសការកើតឡើងនៃបិត្តិវិស័យ គឺកំណើតប្រេត រមែងមិនមានព្រោះអលោភៈ ពិតណាស់ សត្វទាំងឡាយដោយច្រើនរមែងចូលដល់កំណើតប្រេត ព្រោះតណ្ហា (អលោភៈ ជាបដិបក្ខដល់ តណ្ហា ) ការកើតក្នុងនរក រមែងមិនមាន ព្រោះមិនមានទោសៈ ពិតណាស់សត្វទាំងឡាយរមែងចូលដល់នរក ដោយអំណាចនៃទោសៈ ព្រោះការដែលប្រទូសរាយដោយអំណាចនៃទោសៈ (អទោសៈជាបដិបក្ខដល់ទោសៈ) ការកើតក្នុងកំណើតតិរច្ឆាន រមែងមិនមានព្រោះដោយអំណាចនៃអមោហៈ ពិតណាស់បុគ្គលទាំងឡាយដែលវង្វេងដោយមោហៈ រមែងចូលដល់កំណើតតិរច្ឆាន (អមោហៈ ជាបដិបក្ខដល់មោហៈ) ។

៩_បណ្ដាគុណធម៌ទាំងអស់នេះអលោភៈរមែងមិនធ្វើនូវអ្វីដែលទាក់ទងដោយរាគៈ អទោសៈរមែងមិនធ្វើនូវអ្វីដែលទាក់ទងដោយទោសៈ អមោហៈរមែងមិនធ្វើនូវអ្វីដែលទាក់ទងដោយអំណាចនៃមោហៈ ។

១០_គុណធម៌ទាំង ៣ នេះ រមែងបានទូវសញ្ញាទាំង ៣ តាមលំដាប់លំដោយ គឺថាបានទូវនេក្ខម្មសញ្ញា ដោយអលោភៈ អព្យាបាទសញ្ញា ដោយអទោសៈ អវិហិង្សាសញ្ញា ដោយអមោហៈ និង សញ្ញា ៣ ទាំងនេះអសុភសញ្ញា ដោយអលោភៈ អប្បមាណសញ្ញា ដោយ អទោសៈ ធាតុសញ្ញា ដោយអមោហៈ

១១_វៀរធម៌ដែលជាទីបំផុត គឺវៀរទូវកាមសុខល្លិកានុ - យោគ ដោយគុណធម៌ គឺ អលោភៈ វៀរទូវធម៌ដែលជាទីបំផុតម្ខាងទៀត គឺអត្តកិលមថានុយោគ ដោយអំណាចនៃ អទោសៈ ការដែលប្រព្រឹត្តទៅក្នុងចំណុចដែលបដិបត្តិដោយ មជ្ឈិមាដិបទា ដោយអមោហៈ។

១២_ការទម្លាយអភិជ្ឈាកាយគន្ថៈ ព្រោះអលោភៈ ការទម្លាយព្យាបាទកាយគន្ថៈ ព្រោះ អទោសៈ ការទម្លាយសីលព្វតបរាមាសកាយគន្ថៈ និង ឥទំសច្ចាភិនិវេសកាយគន្ថៈ ព្រោះ អមោហៈ ។

*(សេចក្តីនេះមិនមែនមានត្រឹមតែប៉ុណ្ណោះទេនៅមានទៀតតែខ្ញុំព្រះករុណាសរសេរបានប៉ុណ្ណឹង)*

# លោកគ្រូ អគ្គបណ្ឌិត របស់ខ្ញុំ

លោកគ្រូឧត្តមសមនាមពិសិដ្ឋ **អគ្គបណ្ឌិត** កាយចិត្តថ្លៃថ្លា
កបគុណគួរគាប់បវរបញ្ញា កបចិត្តមេត្តាករុណាចិត្តព្រហ្ម ។
ព្រះពុទ្ធដីកាវាចាបរមត្ថ បរិបូណ៌ដោយអត្ថបទបាឋឧត្តម
អដ្ឋកថាសេចក្ដីបរម លោកគ្រូរួមផ្សំចែកទានដោយធម៌ ។
ធម៌ជ្រៅន័យជ្រះស្រឡះសេចក្ដី ដីកាបាលីសេចក្ដីបវរ
លោកគ្រូអធិប្បាយដោះស្រាយដោយល្អ ចែកក្រសែធម៌លំអ ធម្មទាន ។
ជីវិតស្ងប់ស្ងាត់ចិត្តស្អាតស្រឡះ ពិតជាបុត្រព្រះសម្ពុទ្ធទ្រង់ញាណ
មិនខ្លាចនឿយកាយក្នុងការធម្មទាន ញុំាងមនុស្សរាប់លានឲ្យរៀនធម៌ព្រះ ។
សម្ដែងព្រះធម៌ បង្រៀនព្រះធម៌ ទូន្មានដោយល្អព្រះពុទ្ធតម្រាស់
លោកគ្រូព្យាយាមអត់ធ្មត់ខ្លាំងណាស់ ពាក្យណាមិនច្បាស់លោកគ្រូដោះស្រាយ ។
ខ្ញុំកើតមិនទាន់ព្រះពុទ្ធគង់នៅ តែបុណ្យនាំផ្លូវតម្រង់ចិត្តកាយ
មកជួបព្រះធម៌ល្អសព្វសុះសាយ បានលោកគ្រូស្រាយសេចក្ដីឲ្យយល់ ។
សូមបុណ្យកុសលដែលខ្ញុំបានសាង ដំណាង់កាយចិត្តដែលជាមង្គល
សូមបូជាគុណឧត្តមសោតសល់ មានដល់លោកគ្រូ **អគ្គបណ្ឌិត** ។

ជាតិនេះជាតិមុខគ្រប់ជាតិទាំងអស់ សូមសច្ចាស្មោះសូមបាននៅនិត្យ
នៅក្បែរលោកគ្រូ**អគ្គបណ្ឌិត** ទាំងកាយទាំងចិត្តនៅជិតសិក្សា ។
**លោកគ្រូ**បានឃើញធម៌ព្រះសម្ពុទ្ធ ជាធម៌វិសុទ្ធហើយរួចទុក្ខា
ខ្ញុំសូមបានដល់បានគាល់សាស្ដា បានដល់ត្រើយមហាដូចលោកគ្រូផង។

ភិក្ខុ បញ្ញាបជ្ជោតោ ទេព បញ្ញា

## នាមអ្នកមានឧបការៈ ក្នុងការចេញជាធម្មទាននេះ

| | |
|---|---|
| ១_ភិក្ខុ ញាណសារោ សំ បុរី | ២_ភិក្ខុ យ៉ែម សុខហេង |
| ៣_លោកគ្រូ ធម្មាចារ្យ ជឹម ជំនិត | ៤_ឧបាសក សោម រតនៈ |
| ៥_ឧបាសក សុខ លាងហ៊ាប | ៦_ឧបាសិកា ដួង សាមឿន |
| ៧_ឧបាសិកា នេត ឡាយ | ៨_ឧបាសិកា គី វណ្ណហាក់ |
| ៩_ភិក្ខុ នន់ ចាន់ថាត | ១០_ភិក្ខុ ប៉ែន សេដ្ឋា |

# នាមពុទ្ធបរិស័ទជួយឧបត្ថម្ភប្រាក់បោះពុម្ពសៀវភៅនេះ

- សមាគមធម្មទានភិក្ខុ យ៉ែម សុខហេង .....................
- សមាគមធម្មទានភិក្ខុ ប៉ែន សេដ្ឋា កំពង់ឆ្នាំង.................
- សមាគមធម្មទានព្រះភិក្ខុ ញាណសារោ សំ ប៊ុរី កំពង់ឆ្នាំ.....
- សមាគមធម្មទានលោកម្ចាស់ ខេង សំប៊ុន កំពត..........
- សមាគមធម្មទាន ម្ចាស់គ្រូ ជួន ណោម ព្រៃគោ..........
- ពុទ្ធបរិស័ទវត្តកល្យាណមិត្តជ្រោយម្ទេស ស្រុកថ្មគោល.....
- ឧបាសិកា វ៉ាង ចាន់ធី និង ស្វាមី ព្រមទាំងបុត្ត........... ១០០ដុល្លារ
-ឧបាសិកា សំ វឿន និង ស្វាមីព្រមទាំងបុត្រ................. ៥០ដុល្លារ
-ឧបាសក សុខ អួន ឧបាសិកា ហុង ហេង..................៣០ដុល្លារ
-ភិក្ខុ ប៉ែន សេដ្ឋា..........................................៣០ដុល្លារ
- លោកម្ចាស់ ញាណសារោ សំ ប៊ុរី.......................... ១០ដុល្លារ
- ឧបាសិកា ចៀង សឿង ឧបាសក ប្រាជ្ញ វ៉ាង និង បុត្ត......១០ដុល្លារ
- ឧបាសិកា ដួង សាមឿន បុត្ត.............................. ១០ដុល្លារ
- សាមណេរ ឡុង សុងសាយ និង ញោមប្រុសស្រី............១០ដុល្លារ

-ឧបាសិកា ស៊ឹម ណាត និងអ្នកម្តាយ............................១០ដុល្លារ



**អញ្ញា ហិ លាភូបនិសា អញ្ញា និព្វានគាមិនី**
**ឯវមេតំ អភិញ្ញាយ ភិក្ខុ ពុទ្ធស្ស សាវកោ**
**សក្ការំ នាភិនន្ទេយ្យ វិវេកមនុព្រូហយេ ៕**

បដិបទា អាស្រ័យនូវលាភផ្សេង បដិបទា ជាដំណើរទៅកាន់ព្រះនិព្វានផ្សេង ភិក្ខុជាសាវ័ករបស់ព្រះពុទ្ធដឹងច្បាស់នូវហេតុនោះយ៉ាងនេះហើយ មិនគួរត្រេកអរចំពោះសក្ការៈឡើយ គប្បីញ៉ាំងវិវេកឲ្យចម្រើនដោយលំដាប់។

(ទ្រង់ប្រារព្ធព្រះតិស្សត្ថេរ មានប្រក្រតីនៅក្នុងព្រៃ)